00799572 E1/62.1

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 11-Apr-2012, 13:59
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

# ជំនុំជម្រះក្តីនៅដំណាក់កាលដំបូង

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី១០ ខែមេសា ឆ្នាំ២០១២**

**ម៉ោង ០៩:០១ នាទី**

**សវនាការលើកទី៥០**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍
*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង)
*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

លោក ឌុច ផារី

លោក រ៉ូជឺ ហ្វីលីព *(Mr.Roger PHILLIP)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក សេង ប៊ុនឃាង

លោក វីល្លៀម ស្មីត *(Mr. William SMITH)*

លោក ពេជ្រ សម្បត្តិ

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

លោក អៀង សារី

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក ម៉ៃខល ផេសមិន
*(Mr. Michiel PESTMAN)*

លោក ហ្សាស្ពើ ប៉ៅ*(Mr Jasper PAUW)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

លោក អាកទួរ វែកគែន

*(Mr. Arthur VERCKEN)*

**មេធាវីការពារជនជាប់ចោទ អៀង សារី៖**

លោក អាង ឧត្តម

លោក ម៉ៃខល កាណាវាស

*(Mr.Michael KARNAVAS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត

*(Ms. Elisabeth SIMONNEAU-FORT)*

លោក ឡៅ ជុនធី

លោក ហុង គឹមសួន

លោកស្រី ជេត វណ្ណលី

លោកស្រី ទី ស្រ៊ីនណា

កញ្ញា លី ម៉ាញៀន *(Ms.Lyma NGUYEN)*

លោក បាណាបេ ណេគ្វី

*(Mr. Barnabé NEKUIE)*

លោកស្រី ម៉ារី ហ្គីរ៉ូដ

*(Ms. Marie GUIRAUD)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក វីល្លៀម ស្មីត | អង់គ្លេស |
| លោក សុន អរុណ | ខ្មែរ |
| លោក ម៉ៃខល ផេសមិន | អង់គ្លេស |
| លោក អាង ឧត្តម | ខ្មែរ |
| លោក ម៉ៃខល កាណាវាស | អង់គ្លេស |
| លោក គង់ សំអុន | ខ្មែរ |
| លោក អាកទួរ វែកគែន | បារាំង |
| លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត | បារាំង |
| លោក កាំង ហ្គេកអ៊ាវ | ខ្មែរ |

# ឧបសម្ព័ន្ធ

## ការសួរសំណួរទៅសាក្សី៖ លោក កាំង ហ្កេកអ៊ាវ ហៅ ឌុច

សួរដោយលោក អាកទួរ វែកគែន ផ្ដើមពី៖ ..................................................................... ទំព័រ ០១
សួរដោយលោក សុន អរុណ ផ្ដើមពី៖ ..................................................................... ទំព័រ ៦២

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០១:២៣]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរនីតិវិធីសវនាការ។ តាមកាលវិភាគដែលបានគ្រោងទុកនៅថ្ងៃនេះ អង្គជំនុំជម្រះនឹងស្ដាប់សក្ខីកម្មរបស់សាក្សីឈ្មោះ កាំង ហ្កេកអ៊ាវ ហៅ ឌុច ដែលនឹងតាំងសំណួរដេញដោលដោយក្រុមមេធាវីការពារក្ដីលោក ខៀវ សំផន។ អង្គជំនុំជម្រះសូមផ្ដល់វេទិកាជូនទៅក្រុមមេធាវីការពារក្ដីលោក ខៀវ សំផន ដើម្បីមានឱកាសក្នុងការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។ សូមអញ្ជើញ!

[០៩:០២:១២]

**លោក អាកទ្វូរ វែកគែន៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរភាគីទាំងអស់ដែលមានវត្តមាននៅទីនេះ។

**ការតាំងសំណួរដោយសហមេធាវីការពារក្ដី**

**សួរដោយលោក អាកទ្វូរ វែកគែន៖**

ជម្រាបសួរលោក ឌុច។ នៅពេលដែលខ្ញុំសួរសំណួរលោកនោះ ខ្ញុំនឹងព្យាយាមកម្រិតត្រឹមតែការសួរសំណួរអំពីព័ត៌មាន ដែលលោកបានអះអាងថាលោកបានដឹងនៅពេលដែលកើតឡើងរឿងហេតុនោះ។ ខ្ញុំជឿថា គ្មានអ្នកណាម្នាក់នៅទីនេះបានបន្ទោសលោកថា លោកបានអាន ឬក៏បានសិក្សាសៀវភៅ--ឯកសារពាក់ព័ន្ធទៅនឹងសម័យកម្ពុជាប្រជាធិបតេយ្យ ហើយនិងព្យាយាមការពារខ្លួននៅចំពោះមុខតុលាការនេះ ដែលបានចោទប្រកាន់លោកនោះទេ។

[០៩:០៣:១៥]

ខ្ញុំនិយាយអំពីគោលការណ៍ដែលថា លោកមិនមែនជាអ្នកប្រវត្តិវិទូ ឬក៏អ្នកជំនាញការអីដែរ។ ដូច្នេះនៅទីនេះលោកមិនមានឧបនិស្ស័យក្នុងការអត្ថាធិប្បាយទៅលើឯកសារ ដែលលោកមិនដឹងអំពីអត្ថិភាពនៅសម័យនោះ នៅសម័យកម្ពុជាប្រជាធិបតេយ្យនោះទេ។ ហើយឯកសារនោះ គឺនិយាយអំពីបញ្ហាដែលលោកមិនមែនជាអ្នក ជាសាក្សីដោយផ្ទាល់នៅសម័យនោះទេ។

ដូច្នេះខ្ញុំនឹងចាប់ផ្តើមតាមរយៈការសួរសំណួរតូចៗមួយចំនួនជាទូទៅ មុននឹងចូលទៅដល់ចំណុចជាក់លាក់មួយចំនួនពាក់ព័ន្ធទៅនឹងសេចក្តីថ្លែងការណ៍របស់លោក ដែលខ្ញុំបានជ្រើសរើសសម្រិតសម្រាំងយកមក។ ពីព្រោះខ្ញុំគិតថា វាចូលទៅក្នុងនិយមន័យដែលខ្ញុំបានកំណត់នៅក្នុងបុព្វកថាដែលខ្ញុំបានលើកឡើងអម្បាញ់មិញនេះ។

**ស៖** មុននឹងកិច្ចប្រជុំនៅថ្ងៃទី០៦ មករា ឆ្នាំ៧៩ នោះខ្ញុំនឹងនិយាយលើកក្រោយ។ តើលោកមានពាក់ព័ន្ធ ឬក៏មានទំនាក់ទំនងអ្វីជាមួយនឹងលោក ខៀវ សំផន ដែរឬទេ?

[០៩:០៥:៣៦]

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ថ្ងៃ០៦ មករា សូមទុកដោយឡែក។ ឯចំណែករឿងដែលខ្ញុំឆ្លើយ គឺមុនថ្ងៃ០៦ មករា។ មុនថ្ងៃ០៦ មករា ខ្ញុំគ្មានការពាក់ព័ន្ធអីជាមួយនឹងបង ខៀវ សំផន ទេ។ គ្រាន់តែឃើញគាត់ពីចម្ងាយនៅក្នុងពិធីបុណ្យខួប ១៧ មេសា ១៩៧៨។ នេះ ច្បាស់លាស់ មិនមែនបង អៀង សារី ទេថ្ងៃនុង គឺពិតជាបង ខៀវ សំផន។

**ស៖** នៅពេលដែលលោកត្រូវបានស្តាប់ចម្លើយដោយចៅក្រមស៊ើបអង្កេត នៅខែសីហា ឆ្នាំ២០០៧ គឺលេខឯកសារ D86/4 នៅទំព័រទី៣ ERN ជាភាសាបារាំង 00147929 ERN ជាភាសាខ្មែរ 00146551 លោកបានបញ្ជាក់ជូនចៅក្រមស៊ើបអង្កេតថា នៅសម័យកម្ពុជាប្រជាធិបតេយ្យលោកមិនមានសិទ្ធិក្នុងការជួបជាមួយនឹង ខៀវ សំផន នោះទេ។ តើលោកនៅរក្សានូវសេចក្តីប្រកាសនេះដដែល ឬក៏យ៉ាងណា?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ក្នុងរយៈកាលនេះ ខ្ញុំគ្មានសិទ្ធិអីនឹងទៅជួប បងហែម ទេ បង ខៀវ សំផន ទេ។

**ស៖** តើអ្នកណាជាអ្នកដាក់ការហាមឃាត់នេះ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន នេះគឺជាគោលការណ៍បក្ស។ មេណាមួយ គឺយើងត្រូវតែជួបមេនោះ រាយការណ៍ជូនមេនោះ។ ដូច្នេះ ខៀវ សំផន បង ខៀវ សំផន មិនមែនជាមេរបស់ខ្ញុំទេ។

**ស៖** ចំពោះចៅក្រមស៊ើបអង្កេតដដែលនោះ ប៉ុន្តែនៅថ្ងៃផ្សេងមួយទៀត គឺនៅថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៨ ឯកសារ-- ERN ជាភាសាបារាំង 00197983, ERN ជាភាសាអង់គ្លេស 00198222 ហើយជាភាសាខ្មែរ 0019--

[០៩:០៧:៥៣]

**អ្នកបកប្រែ៖**

លោកប្រធាន ERN ជាភាសាអង់គ្លេសអំមិញ អ្នកបកប្រែតាមអត់ទាន់។ សូមឲ្យម្តងទៀត លោកប្រធាន។

**សួរដោយលោក អាកឡូរ វែកគែន៖**

**ស៖** 00197973។ លោកបានបញ្ជាក់ថា សុន សេន មិនដែលបាននិយាយអំពីលោក ខៀវ សំផន ទេ។ តើលោកនៅរក្សាការអះអាងនេះដដែល ឬក៏យ៉ាងណា?

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន បង សុន សេន ដូចគ្មាននិយាយអីពីរឿងបង ខៀវ សំផន ទេ។ មិនមានរឿងអីទាក់ទងគ្នានឹងនិយាយអំពីគាត់។

[០៩:០៨:៥២]

**ស៖** កាលពីម្សិលមិញ នៅក្នុងសវនាការនេះ លោកបានបញ្ជាក់ថា លោកមិនដឹងទេ ថាតើចម្លើយសារភាពដែលលោកផ្ញើជូនទៅមេរបស់លោកនោះ តើនឹងត្រូវបញ្ជូនទៅណាទៀត? តើលោកនៅតែរក្សានូវអ្វីដែលលោកបាននិយាយចំពោះចៅក្រមស៊ើបអង្កេត នៅថ្ងៃទី១៩ វិច្ឆិកា ឆ្នាំ២០០៨ ដែលនៅក្នុងឯកសារលេខ D217 ERN ជាភាសាបារាំង 00239823, ERN ជាភាសាអង់គ្លេស 00242875 ជាភាសាខ្មែរ 00239833។ លោកបានបញ្ជាក់ជូនចៅក្រមស៊ើបអង្កេតថា ដកស្រង់ជាសង្ខេប៖ "គ្មានអ្វីដែលអាចបញ្ជាក់បានថា ខៀវ សំផន អាននូវចម្លើយសារភាពនោះទេ"។ នេះជាអ្វីដែលលោកបាននិយាយនៅក្នុងសេចក្តីប្រកាសនោះ តើលោកនៅតែរក្សាការប្រកាសនេះដដែល ឬក៏យ៉ាងណា?

[០៩:១០:២៨]

**ឆ៖** ខ្ញុំស្តាប់មិនច្បាស់ទេ។ សូមលោកមេធាវីបញ្ចាំងលើអេក្រង់ ពាក្យដែលខ្ញុំបានជម្រាបចៅក្រមស៊ើបអង្កេត។

**ប្រធានអង្គជំនុំ៖**

មេធាវីរៀបចំនូវឯកសារដើម្បីផ្តល់ជូនទៅសាក្សីដើម្បីពិនិត្យផ្ទៀងផ្ទាត់មុនពេលតាំងសំណួរចំពោះគាត់ដូចអ្វីដែលភាគីដទៃទៀតធ្លាប់បានធ្វើប៉ុន្មានថ្ងៃនេះ កន្លងមកហើយ ហើយអង្គជំនុំជម្រះក៏បានជម្រាបជូនរួចហើយដែរ។ ហើយជាការងាយស្រួលគួរតែត្រូវបានរៀបចំដូចគ្នានឹងមេធាវីការពារក្តី

លោក អៀង សារី ដែលបានធ្វើកាលពីម្សិលមិញនោះជាការរួមចំណែកនៅក្នុងការបង្កើនល្បឿនពេលវេលាកុំឲ្យវាបាត់បង់ពេលវេលាដែលលោកមានពេលវេលាខ្លីសម្រាប់សួរដេញដោលនេះ។

[០៩:១១:៣៣]

លោកមានឯកសារជាក្រដាសទេ? ប្រគល់មកឲ្យខាងផ្នែកមន្ត្រីរដ្ឋបាលតុលាការ ដើម្បីគ្រប់គ្រងទៅ ហើយនិងហុចជូនគាត់ដើម្បីពិនិត្យមើលឯកសារជាក្រដាស ហើយដោយឡែកឯកសារដែលនៅក្នុងសំណុំរឿងដែលអាចបញ្ចាំងនៅលើអេក្រង់កុំព្យូទ័រនេះ អង្គជំនុំជម្រះអនុញ្ញាតឲ្យមន្ត្រី បុគ្គលិកជំនួយការរបស់លោកដាក់បញ្ចាំងនៅលើអេក្រង់ទូរទស្សន៍បន្ទាប់ពីពេលលោកត្រូវការបង្ហាញ ឬក៏ដាក់នូវឯកសារណាមួយដេញដោលចំពោះសាក្សីរូបនេះ។

ដូចគ្នានេះដែរ មន្ត្រីរដ្ឋបាលតុលាការគឺទទួលមក ហើយនិងរៀបចំចាត់ចែងដូចម្សិលមិញអ៊ីចឹងគឺបានបញ្ជូនទៅឲ្យសាក្សីពិនិត្យភ្លាមៗ នៅពេលណាដែលមេធាវីត្រូវការសួរដេញដោលលើឯកសារណាមួយ។

[០៩:១២:៣៤]

**លោក អាកទួរ វែកគែន៖**

លោកប្រធាន ខ្ញុំមានឯកសារហើយ ខ្ញុំគ្រាន់តែចង់គូសបញ្ជាក់ដើម្បីកុំឲ្យខាតពេល។ ហើយខ្ញុំអាចបង្ហាញជូនឯកសារនេះបានដើម្បីកុំឲ្យខាតពេល។ ខ្ញុំគិតថា ឯកសារនេះបានបញ្ចាំងរួចហើយ។

លោកក្រឡាបញ្ជី តើអាចអញ្ជើញមកទីនេះបានទេ? ខ្ញុំនឹងផ្តល់ឯកសារជូន។

**ប្រធានអង្គជំនុំ៖**

មន្ត្រីរដ្ឋបាលតុលាការទៅទទួលឯកសារមករក្សាទុក!

តែមួយទេ ដាក់ជូនសាក្សីតែម្តងទៅ!

[០៩:១៣:៣៦]

**លោក កាំង ហ្គេកអ៊ាវ៖**

ជម្រាបប្រសាសន៍លោកប្រធាន សូមឲ្យមេធាវីសួរសំណួរម្តងទៀតមក ខ្ញុំភ្លេចបាត់ទៅហើយ។

**ប្រធានអង្គជំនុំ៖**

មេធាវីរៀបចំការតាំងសំណួរឲ្យជាក់លាក់ ចំពោះឯកសារដែលលោកដាក់ចំពោះមុខសាក្សីនេះសាជាថ្មីម្តងទៀត ពីព្រោះយូរ-- រយៈពេលយូរហើយគាត់ភ្លេច មិនចងចាំនូវសំណួរដែលលោកសួរទេ។

[០៩:១៤:០៣]

**សួរដោយលោក អាកទួរ វែកគែន៖**

**ស៖** កាលពីម្សិលមិញនៅចំពោះមុខតុលាការនេះ លោកបានបញ្ជាក់ថា លោកមិនដឹងថាតើចម្លើយសារភាពនៅមន្ទីរស-២១ ដែលលោកផ្ញើទៅឲ្យមេរបស់លោកនុំង នឹងត្រូវបញ្ជូនទៅអ្នកណាទៀតទេ? ហើយកាលពីមុននោះលោកបានប្រកាសថា ជាសង្ខេប "គ្មានអ្វីដែលអាចបញ្ជាក់ថាលោក ខៀវ សំផន អានចម្លើយសារភាពនោះទេ"។ ដូច្នេះ ខ្ញុំគ្រាន់តែចង់សួរលោកថា តើលោកនៅតែរក្សាចម្លើយនេះដដែលឬក៏យ៉ាងណា?

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំនៅតែរក្សាថា ខ្ញុំអត់ដឹងទេ។ តើឯកសារស-២១ ខាងលើយកទៅធ្វើអីខ្លះ? ទីពីរៗ ខ្ញុំនៅតែរក្សាគោលគំនិតថា បងហែម អត់បានមើលឯកសារនេះមុនគេមុនឯងដូចបង សុន សេន ទេ។ ខ្ញុំសូមបញ្ជាក់ម្ដងទៀត ការបកប្រែហ្នឹងមិនត្រូវទេ។ ខ្ញុំសូមបញ្ជាក់ថា ខ្ញុំមិនទទួលស្គាល់ថា បងហែម បានឯក-- អានឯកសារនេះមុនគេមុនឯងដូចបង សុន សេន ទេ។ គឺបង សុន សេន តែម្នាក់គត់ដែលអានឯកសារនេះមុនគេមុនឯង។

[០៩:១៦:០១]

**ស៖** ឥឡូវនេះខ្ញុំចូលទៅសំណួរមួយទៀត។ នៅក្នុងអំឡុងពេលស៊ើបអង្កេតក្នុងរយៈពេលប៉ុន្មានថ្ងៃកន្លងទៅនេះ លោកបានអះអាងថា បន្ទាប់ពីការចាប់ខ្លួន ជូ ជេត លោកបានទទួលនូវការសម្ងាត់អំពីប៉ង់ ដែលបញ្ជាក់ថា ប៉ុល ពត បានបញ្ជាក់-- បានបញ្ជាកុំឲ្យគាត់កោះហៅ វន វ៉េន មកចូលរួមនៅក្នុងកិច្ចប្រជុំ។ ហើយនៅក្នុងកិច្ចប្រជុំនោះ មានការសម្រេចអំពីការចាប់ខ្លួន ជូ ជេត ប៉ុន្តែគឺឲ្យកោះហៅលោក ខៀវ សំផន វិញមកចូលរួមក្នុងកិច្ចប្រជុំនោះ។ ដូច្នេះសំណួរទីមួយរបស់ខ្ញុំ ពាក់ព័ន្ធទៅនឹងប្រធានបទនេះ គឺខ្ញុំចង់ដឹងថា បើតាមលោកដឹង តើ ប៉ង់ ចូលរួមនៅក្នុងកិច្ចប្រជុំរបស់គណៈអចិន្ត្រៃយ៍ដែរឬទេ?

**ឆ៖** ជម្រាប្រសាសន៍លោកប្រធាន បញ្ហានេះខ្ញុំចង់ដែរ ចង់ឲ្យលោកមេធាវីបញ្ចាំងឯកសារនេះនៅលើអេក្រង់ ដើម្បីឲ្យសាធារណជនដឹង ថ្វីត្បិតតែបញ្ហានេះខ្ញុំឆ្លើយជូនបានភ្លាម។ ដូច្នេះ សូមលោកប្រធានពិចារណា តើឲ្យបញ្ចាំង ឬក៏ឲ្យខ្ញុំឆ្លើយភ្លាម?

**ប្រធានអង្គជំនុំ៖**

មេធាវីផ្អែកលើមូលដ្ឋាននៃឯកសារជាក់លាក់ណាមួយទេក្នុងការសួរ ឬក៏ជាសំណួរទូទៅទេ?

**លោក អាកទូរ វែកគែន៖**

ជាដំបូងនេះ ខ្ញុំមិនមានឯកសារអីទេ លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

ជាសំណួរទូទៅ លោកសាក្សីអាចឆ្លើយៗនឹងសំណួរហ្នឹងបាន ហើយបើសិនជាលោកអាចឆ្លើយបានណ៎ា!

[០៩:១៨:៣៣]

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន សំណួរនេះគឺលោកមេធាវីចង់ដឹងថា តើ ប៉ង់ មានសិទ្ធិចូលប្រជុំជាមួយនឹងគេដែរឬអត់? ប៉ង់ ជាអ្នករៀបចំកន្លែង រៀបចំតុកៅអី រៀបចំអី ហើយនិងដើរអញ្ជើញសមាជិកអចិន្ត្រៃយ៍ឲ្យចូលប្រជុំ។ តាមគោលការណ៍ ខ្ញុំជឿថា ប៉ង់ មិនមានសិទ្ធិចូលប្រជុំជាមួយនឹងគេទេ។

**ស៖** តើមានន័យថា ប៉ង់ មិនអាចបញ្ជាក់ជូនលោកបានទេថា តើលោក ខៀវ សំផន មានវត្តមាននៅក្នុងកិច្ចប្រជុំនោះឬក៏អត់នោះ? តើអ៊ីចឹងមែនទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ប៉ង់ ជាអ្នកដើរអញ្ជើញ ថ្ងៃណោះ ប៉ង់ អត់បានអញ្ជើញបងវន ទេ គឺអញ្ជើញ បងហែម។ នេះតាមសម្ដី ប៉ង់ ដែលជាអ្នកអនុវត្តបញ្ជារបស់ បងប៉ុល។

[០៩:២០:៣០]

**ស៖** តើពិតដែរឬទេ ដែលក្នុងការនិយាយថា ព័ត៌មានតែមួយគត់ដែលបានផ្ដល់ ដែល ប៉ង់ បានផ្ដល់ជូនលោកនៅថ្ងៃនោះនោះ គឺថា មានការផ្លាស់ប្ដូរក្នុងការអញ្ជើញមនុស្សមកចូលរួមកិច្ចប្រជុំ។ តើអ៊ីចឹងទេ? គឺមានការជំនួស វន វ៉េត ដោយ ខៀវ សំផន?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន វន វ៉េត-- ជម្រាបប្រសាសន៍លោកប្រធាន វន វ៉េត សមាជិកអចិន្ត្រៃយ៍មជ្ឈិម។ ឯចំណែកបង ខៀវ សំផន អត់ទេ គាត់ជាសមាជិកមជ្ឈិមពេញសិទ្ធិតែប៉ុណ្ណឹង។ ដូច្នេះការដែល--

**ស៖** លោកសាក្សី ប្រហែលជាមានបញ្ហាការបកប្រែឬក៏មិនដឹង? អ្វីដែលខ្ញុំចង់ឲ្យលោកបញ្ជាក់នោះ គឺថាខ្លឹមសារនៃព័ត៌មានដែលលោកបានបញ្ជាក់ថា ប៉ង់ បានជម្រាបលោកនោះ គឺនៅថ្ងៃនុ៎ង តើ ប៉ង់ បាននិយាយអ្វីផ្សេងទេ ក្រៅពីថា ខៀវ សំផន បានត្រូវបាន-- គេបានឲ្យខ្ញុំកោះហៅ ខៀវ សំផន

ជំនួស វន វ៉េត វិញនោះ?

[០៩:២២:០៩]

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន សំណួរលើកក្រោយនេះប្លែកពីមុនបន្តិច។ ដូច្នេះ ខ្ញុំសូមអនុញ្ញាតឆ្លើយសំណួរលើកក្រោយនេះ។ មុនដំបូង ប៉ង់ ប្រាប់ខ្ញុំថា ថ្ងៃនោះ បងវ៉ន នៅកន្លែង តែបងប៉ុល ឲ្យទៅអញ្ជើញ បងហែម វិញ។ រួចបានបន្តទៅទៀត ប៉ង់ គាត់ពន្យល់ខ្ញុំថា វន វ៉េត លំបាកធ្វើការណាស់។ ពេលប្រជុំម្តងៗគាត់មុខក្រញូវ ជួនអីអង្គុយក្រញូវអត់និយាយឆ្លើយឆ្លងនឹងគេ។ នេះ ប៉ង់ពន្យល់អ៊ីចឹង។

**ស៖** តើអស់ហើយដែលអ្វីដែលគាត់បាន-- ដែល ប៉ង់ បានប្រាប់លោកនោះ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ពេលនុ៎ង ប៉ង់ ពន្យល់ខ្ញុំតែប៉ុននុ៎ង។

**ស៖** តើមកដល់សព្វថ្ងៃនេះ ប៉ង់ នៅរស់ដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ឈឹម សំអោក ហៅ ប៉ង់ ត្រូវចាប់ចូលស-២១ គ្នាស្លាប់បាត់ទៅហើយ។

**ស៖** តើមានអ្នកណាផ្សេងទៀតទេ ដែលបានចូលរួមនៅក្នុងពេលដែលលោកពិភាក្សាជាមួយ ប៉ង់ នោះ?

[០៩:២៤:០២]

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ការសន្ទនាជាមួយនឹងមេនៅក្នុងអង្គភាពមួយ ជាមួយនឹងមេពីខាងលើមកទៀត គ្មានអ្នកណាហ៊ានទៅនៅជិតទេ។

**ស៖** ជាការពិតអ៊ីចឹងមែន។ ក៏ប៉ុន្តែប្រសិនបើការសន្ទនានេះប្រព្រឹត្តទៅនៅពេលដែល ប៉ង់ តើ ប៉ង់ ត្រូវបានឃុំខ្លួននៅមន្ទីរ ស-២១ នោះ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន នៅពេលដែល ប៉ង់ ចូលទៅជាប់នៅស-២១ ខ្ញុំមិនមែនសួរចម្លើយ ប៉ង់ ទេ។ ខ្ញុំមិនបានទៅអើត ប៉ង់ មួយភ្លែតសោះ។

**ស៖** តើវាយ៉ាងម៉េច អាចកើតឡើងយ៉ាងម៉េចទៅកើតដែរនៅក្នុងប្រតិចារិកនៃខ្សែអាត់សំឡេងនៃកិច្ចសម្ភាសន៍របស់លោកជាមួយនឹងឧត្តមស្នងការនៃអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួននោះ លោកបានបញ្ជាក់ថា ប៉ង់ បានប្រាប់ការសម្ងាត់នេះដល់លោកក្រោយពីគាត់បានបញ្ចប់ការសរសេរចម្លើយសារភាពរបស់គាត់ លេខយោង IS20.19 ទំព័រ២ និង៣ ERN ជាភាសាបារាំង 00160722,

ERN ជាភាសាអង់គ្លេស 00002507, ERN ជាភាសាខ្មែរ 00160890។

[០៩:២៦:២៩]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ!

**លោក វីណ្ឌៀម ស្មីត៖**

សូមជម្រាបសួរលោកប្រធាន ខ្ញុំចង់ឲ្យបង្ហាញឯកសារនេះជូនទៅសាក្សី ហើយខ្ញុំចង់ដឹងថា តើសហភាតាគាត់មានឯកសារហ្នឹងជាភាសាអង់គ្លេស ហើយអាចផ្តល់ ERN បានដែរឬទេ?

សូមអរគុណ។

**លោក អាកទ្វូរ វែកគែន៖**

បាទ ខ្ញុំអាចផ្តល់ជូនបាន។ 00002507 ខ្ញុំមានឯកសារជាក្រដាស លោកប្រធាន!

**ប្រធានអង្គជំនុំ៖**

មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារពីមេធាវីជូនទៅសាក្សីពិនិត្យ។

**លោក អាកទ្វូរ វែកគែន៖**

ខ្ញុំសូមការអនុញ្ញាតពីលោកប្រធានដើម្បីបញ្ចាំងឯកសារនេះនៅលើអេក្រង់។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។ សូមអញ្ជើញ!

[០៩:២៨:១០]

**សួរដោយលោក អាកទ្វូរ វែកគែន៖**

**ស៖** សូមអភ័យទោស អម្បាញ់មិញនេះខ្ញុំអត់បានបើកមីក្រូ។ ក្នុងការបកប្រែជាភាសាបារាំងនោះមានការសរសេរ នៅក្នុងឯកសារនោះថា បន្ទាប់ពី ប៉ង់ បានបញ្ចប់ការសរសេរចម្លើយសារភាព ខ្ញុំបាននិយាយជាមួយគាត់ ហើយនៅពេលសន្ទនាជាមួយ ប៉ង់ នោះ ប៉ង់ បានប្រាប់ខ្ញុំថា វន វ៉េត ទោះបីជាមិនទៅបានហៅមកកន្លែងផ្សេងក៏ដោយ ក៏មិនបានកោះហៅទេនៅពេលប្រជុំនោះ។ តើលោកអាចពន្យល់បានទេ ថាមានភាពខុសគ្នារវាងអ្វីដែលលោកបាននិយាយនៅថ្ងៃនេះ ហើយនិងលោកអ្វីដែលលោកបាននិយាយនៅឆ្នាំ៩៩?

**លោក កាំង ហ្កេកអ៊ាវ៖**

**ឆ៖** ជម្រាបប្រសាសន៍លោក កំណត់ដៃថ្ងៃ៤, ថ្ងៃ៥, ថ្ងៃ៦ របស់ យូ.អ៊ិន.អេច.អេច.អ័រ ខ្ញុំបដិសេធម្តងហើយម្តងទៀត។ ដោយឡែក១ករណីដែលលោកចោទសួរខ្ញុំនេះ គឺជារឿងដែលខ្ញុំសួរ ប៉ង់ នៅពេលដែល ប៉ង់ មានអំណាចពេញទី ចុះមកដឹកនាំ ស-២១។

[០៩:២៩:៥៦]

ទីពីរ ដោយឡែកដែរ ប៉ង់ មានស្តីឲ្យខ្ញុំនៅពេលដែល មិត្តហ៊ី ចាប់ ខ្ញុំនៅនុំងមុខហ្នឹង ថាប្រវត្តិរូបដូចស-២១ ឯងហ្នឹងណា បើកុំតែធ្វើការផ្ទាល់ជាមួយនឹងខាងលើ គេចាប់យូរណាស់ទៅហើយ។

**ស៖** សូមអភ័យទោសលោកសាក្សី។ ប្រហែលជាលោកយល់ច្រឡំអំពីខ្លឹមសារនៃសំណួររបស់ខ្ញុំហើយ។ ខ្ញុំមិនបានសួរលោកអំពីចំណុចពីរដែលលោកបានលើកឡើងអម្បាញ់មិញនេះទេ។ ខ្ញុំសួរលោកអំពីការផ្លាស់ប្តូរ ឬក៏កែប្រែចម្លើយរបស់លោក។ គឺនៅឆ្នាំ៩៩ លោកបាននិយាយថា លោកបានពិភាក្សាជាមួយ ប៉ង់ ក្រោយពីគាត់បានបញ្ចប់ការសរសេរចម្លើយសារភាព។ គឺនិយាយអំពីដំណើរការមន្ទីរស-២១ បន្ទាប់ពីគាត់ត្រូវបានគេធ្វើទារុណកម្ម។ ហើយអម្បាញ់មិញនេះ លោកបាននិយាយថា លោកមិនបាននិយាយជាមួយ ប៉ង់ ទេ នៅពេលដែលគាត់ត្រូវបានឃុំនៅមន្ទីរស-២១នោះ។ ដូច្នេះកម្មវត្ថុនៃសំណួររបស់ខ្ញុំនោះ គឺចង់ដឹងថា ហេតុអ្វីបានមានភាពខុសគ្នារវាងចម្លើយទាំងពីរនេះ រវាងឆ្នាំ៩៩ ហើយនិងថ្ងៃនេះ? តើការពិតនៅឯណា?

[០៩:៣១:២៦]

**ឆ៖** ជម្រាបប្រសាសន៍ប្រធាន នេះហើយជាសេចក្តីពិតដែលខ្ញុំនិយាយអម្បាញ់មិញហ្នឹង គឺប៉ង់និយាយឲ្យខ្ញុំនៅពេលដែល ប៉ង់ មានអំណាច។ ខ្ញុំសួរ ប៉ង់ នៅពេលដែល ប៉ង់ មានអំណាច។ ដែលខ្ញុំសួរហ្នឹង ប្រហែលជាក្នុងខែ៤ ឆ្នាំ១៩៧៨ មុនពេល-- នៅក្រោយពេលចាប់ ជូ ជេត បន្តិច។

**ស៖** តើលោកមានចាំអំពីកាលបរិច្ឆេទចាប់ខ្លួន ជូ ជេត-- អឺ! ប៉ង់ ដែរឬទេ?

**ឆ៖** ខ្ញុំមិនចាំទេ កាលបរិច្ឆេទចាប់ ប៉ង់ តែកាលបរិច្ឆេទចាប់ ជូ ជេត ខ្ញុំចាំ។

**ស៖** *(គ្មានការបកប្រែ)*

**ឆ៖** ខ្ញុំជម្រាបបញ្ជាក់ម្តងទៀត ការបកប្រែអំមិញដូចវង្វេងហើយ។ ខ្ញុំមិនចាំទេ ថ្ងៃខែចាប់ ប៉ង់ តែខ្ញុំចាំច្បាស់កាលបរិច្ឆេទនៃការចាប់ ជូ ជេត។

[០៩:៣៣:២៨]

**ស៖** បាទគឺ លោកបាន១ បញ្ជាក់ថា ខែមេសា ឆ្នាំ៧៨ សូមទោស គឺខ្ញុំច្រឡំទេ ខ្ញុំច្រឡំជាមួយនឹងការសន្ទនាគ្នា។ តើលោកអាចរំឭកឡើងវិញបានទេ អំពីកាលបរិច្ឆេទនៃការចាប់ខ្លួនហ្នឹង? ខ្ញុំមិនដឹងថាតើលោកបាន--

**ឆ៖** ការចាប់ខ្លួន ជូ ជេត ក្នុងខែមេសា ១៩៧៨។

[០៩:៣៤:១២]

**ស៖** ខ្ញុំចង់និយាយអំពីការចាប់ខ្លួន ប៉ង់។ លោកបាននិយាយថា លោកមិនបានចាំអំពីកាលបរិច្ឆេទចាប់ខ្លួន ប៉ង់ ទេ។ តើលោកមានលទ្ធភាពអាចបញ្ជាក់បានទេថា តើវាយូរ កើតឡើងយូរបន្ទាប់ពីចាប់ខ្លួន ជូ ជេត ឬក៏គ្រាន់តែប៉ុន្មានសប្តាហ៍ក្រោយពីការចាប់ខ្លួន ជូ ជេត នោះ?

**ឆ៖** ក្រោយ១! គឺចន្លោះ១ ការចាប់ ជូ ជេត និងចន្លោះការចាប់ សោ ភឹម បោសសម្អាតបូព៌ា។ បោសម្អាតបូព៌ា១ ខែមិថុនា ១៩៧៨។ ដូច្នេះ ចន្លោះនុ៎ង។

**ស៖** ដូច្នេះបើតាមការលោកចាំនោះ គឺប្រហែលជាពីរខែបន្ទាប់ពីការចាប់ខ្លួន ជូ ជេត តើមែនឬទ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ប្រហែលជានៅក្នុងអំឡុងនុ៎ង ជិតពីរខែ។

**ស៖** នៅក្នុងចម្លើយសារភាពរបស់ ប៉ង់ នៅ-- សូមទោស ជូ ជេត នៅក្នុងចម្លើយសារភាពនៅមន្ទីរស-២១ នោះ ជូ ជេត បានឆ្លើយដាក់ ប៉ង់។ តើអ៊ីចឹងទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំចាំមិនច្បាស់ទេ។ ដូចជាអត់ច្រើនជាងមាន។

**ស៖** មុនពេលចាប់ខ្លួន ជូ ជេត តើ ប៉ង់ ត្រូវបានគេឆ្លើយដាក់នៅក្នុងចម្លើយសារភាពផ្សេងទៀតដែរឬទេ? គឺមុនពេលចាប់ខ្លួន ជូ ជេត។

[០៩:៣៧:៣០]

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:៣៧:៤៦]

**ប្រធានអង្គជំនុំ៖**

សាក្សីមិនបាច់ឆ្លើយតបទៅនឹងសំណួររបស់មេធាវី ដែលសួរចំពោះលោកចុងក្រោយអម្បាញ់មិញទេ។ ដោយហេតុមេធាវីផ្អែកលើលទ្ធផលនៃការធ្វើទារុណកម្ម សួរចម្លើយយកមកដេញដោល។ មេធាវីរៀបចំនូវសំណួរឡើងវិញ ចៀសវាងនូវការផ្អែកទៅលើលទ្ធផលនៃការធ្វើទារុណកម្ម ហើយយក

ទៅដេញដោលសាក្សី។

**លោក អាកឡូរ វ៉េកគែន៖**

លោកប្រធាន ខ្ញុំមិនប្រើប្រាស់ព័ត៌មានដែលមាននៅក្នុងចម្លើយសារភាពដែលទទួលបានក្រោមការធ្វើទារុណកម្មនោះទេ។ ខ្ញុំមិនបានចាត់ទុកព័ត៌មាននេះថាជាព័ត៌មានពិតនោះទេ។ ប៉ុន្តែយោងទៅតាមរបៀបនៃការធ្វើការនៅមន្ទីរស-២១ និងរបបខ្មែរក្រហមនោះ លោក ឌុច បានបញ្ជាក់រួចមកហើយថា ទាល់តែមានការឆ្លើយដាក់នៅក្នុងចម្លើយសារភាព ទើបអាចមានការចាប់ខ្លួន ឬក៏តាមដាន។ នេះគឺជាខ្សែគំនិតនៃខ្លឹមសារនៃសំណួររបស់ខ្ញុំ គឺខ្ញុំមិនបានចង់ផ្ទៀងផ្ទាត់ភាពពិតប្រាកដនៃព័ត៌មាននៅក្នុងចម្លើយសារភាពនោះទេ។ ខ្ញុំគ្រាន់តែចង់ដឹងថា តើនៅក្នុងប្រវត្តិរបស់មន្ទីរស-២១ តើមុននឹងពេលការចាប់-- មុនពេលចាប់ខ្លួន ជូ ជេត នោះ តើមានចម្លើយសារភាពណាផ្សេងទៀត ដែលបានឆ្លើយដាក់ ជូ ជេត ដែរឬទេ? សូមទោស ឆ្លើយដាក់ ប៉ង់ ដែរឬទេ? ហើយប្រសិនបើជាករណីនេះមែន ខ្ញុំនឹងសួរសំណួរផ្សេងទៀត។

[០៩:៤០:០២]

អ៊ីចឹង ដូច្នេះ ជាថ្មីម្តងទៀត គឺព័ត៌មាននេះ មិនពាក់ព័ន្ធទៅនឹងភាពពិតប្រាកដនៃព័ត៌មានដដែលទទួលបាននៅក្នុងចម្លើយសារភាពក្រោមទារុណ្ឌកម្មនោះទេ។ ខ្ញុំគិតថា ខ្ញុំហាក់ដូចជាឃ្លាតចេញពីក្រឹត្យក្រមបន្តិច គឺខ្ញុំមិនចង់ដឹងអំពីខ្លឹមសារនៃព័ត៌មាននៅក្នុងចម្លើយសារភាពនោះទេ។ ដូច្នេះ ខ្ញុំសូមការអនុញ្ញាតពីអង្គជំនុំជម្រះមេត្តាពិនិត្យមើលនូវការសម្រេចរបស់ខ្លួនឡើងវិញ ពាក់ព័ន្ធទៅនឹងសេចក្តីពន្យល់របស់ខ្ញុំនេះ ហើយអនុញ្ញាតឲ្យសួរសំណួរអម្បាញ់មិញនេះ ហើយនិងពន្យល់បន្ថែមផង។ សូមអរគុណ។

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:៤១:៥៧]

**ប្រធានអង្គជំនុំ៖**

មេធាវីអាចតាំងសំណួរមានលក្ខណៈជាទូទៅបាន ប៉ុន្តែមេធាវីមិនត្រូវបង្ហាញថា ខ្លួនផ្អែកលើកំណាត់ហេតុចម្លើយសារភាពនៃអ្នកទោសដែលបានធ្វើទារុណកម្ម រួចកម្ទេចនៅក្នុងស-២១ ធ្វើជាមូលដ្ឋានក្នុងការសួរសាក្សីទេ។

**សួរដោយលោក អាកឡូវ វ៉ែកគែន៖**

ខ្ញុំនឹងព្យាយាម-- ខ្ញុំព្យាយាមរៀបសំណួរនេះឡើងវិញ។

**ស៖** លោកសាក្សីបើតាមលោកដឹង មុនពេលចាប់ខ្លួន ជូ ជេត តើមានការឃ្លាំមើល ប៉ង់ ដែរឬទេ ពីរដ្ឋអំណាច?

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន បើតាមខ្ញុំចាំ គឺចាំនៅពេលដែលធ្វើការជាមួយនឹងបង សុន សេន។ បង សុន សេន អនុញ្ញាតឱ្យអ្នកទោសឆ្លើយដាក់ ប៉ង់ តាំងពីគាត់នៅជាមួយខ្ញុំ។

[០៩:៤៣:៤៨]

**ស៖** តើការអនុញ្ញាតក្នុងការចោទ ប៉ង់ នេះ កើតឡើងមុនពេលចាប់ខ្លួន ជូ ជេត ដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ច្បាស់ជាមុន ពីព្រោះបង សុន សេន បែកចេញពីខ្ញុំនៅថ្ងៃ១៥។ ពីព្រោះបង សុន សេន បែកពីខ្ញុំនៅថ្ងៃ១៥ ខែសីហា ១៩៧៧។ ដូច្នេះ--

**ស៖** តើ សុន សេន បាននិយាយប្រាប់លោកដោយផ្ទាល់ដែរឬទេ ថាគាត់ចង់ឱ្យឈ្មោះ ប៉ង់ ស្ថិតនៅក្នុងចម្លើយសារភាពនោះ? តើនេះជាអ្វីដែលលោកនិយាយ ឬក៏ម៉េច?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន រឿងនេះវែង ពីរលើក។ ដូច្នេះ ខ្ញុំសូមនិយាយតែអាលើកចុងក្រោយបានហើយ។ នៅថ្ងៃមួយហ្នឹងបង សុន សេន សួរខ្ញុំ "ថាបុគ្គលម្នាក់ដែលគាត់បញ្ជូនទៅឱ្យ ស-២១ សួរចម្លើយណ៎ា ម៉េចក៏មិនឃើញឆ្លើយដាក់ ប៉ង់?"។ ខ្ញុំជម្រាបគាត់ថា "មានគេឆ្លើយដាក់ ប៉ង់ ពីលើកមុន។ ប៉ុន្តែដែលខ្ញុំរាយការណ៍ជម្រាបបងៗ ចំអកឱ្យខ្ញុំនៅនឹងមុខ ប៉ង់ ចេញទឹកភ្នែក-- បងសើចចេញទឹកភ្នែកណ៎ា"។ ដល់ពេលនុ៎ងហើយដែលមេខ្ញុំបង សុន សេន គាត់ថា "អឺៗ អញខុសហើយ ឥឡូវនេះស្ដាប់ហើយ វាឆ្លើយថាម៉េច? ឱ្យសរសេរមកអញស្ដាប់"។ នេះជាព្រឹត្តិការណ៍ចុងក្រោយ។

[០៩:៤៧:០៩]

**ស៖** តើសម្ដីរបស់មេរបស់លោក សុន សេន នៅថ្ងៃនោះ ដែលទាមទារឱ្យមានការឆ្លើយដាក់ ប៉ង់ នៅក្នុងចម្លើយសារភាព? តើចំពោះលោកនោះ តើមានន័យថា ប៉ង់ កំពុងតែត្រូវបានឃ្លាំមើលដោយរដ្ឋអំណាចមែនទេ?

**ឆ៖** ច្បាស់ហើយ។ ការតាមដាន គេតាមដានហូរហែមក។ ក៏ប៉ុន្តែនេះជាជំហានមួយថ្មីទៀត ដែលគេស្ដាប់ចម្លើយអ្នកដែលឆ្លើយដាក់ ប៉ង់។

**ស៖** កាលពីម្សិលមិញនៅពេលដែលលោកឆ្លើយទៅនឹងលោកមេធាវី កាណាវាស លោកបានប្រាប់ថា សភាពភ័យខ្លាចរបស់លោកនៅសម័យនោះ គឺថានៅសម័យកម្ពុជាប្រជាធិបតេយ្យនោះ។ ខ្ញុំសួរថា យោងទៅហេតុដែល ការណ៍ដែលថា ប៉ង់ ត្រូវទទួលការឃ្លាមើលដែល-- ហើយនិងការដែល សុន សេន ថាសុំឲ្យគេឆ្លើយដាក់ទៅ ប៉ង់ នោះ តើចំពោះលោកនោះ តើលោកដើម្បីសុវត្ថិភាពរបស់លោកផ្ទាល់នោះ តើលោកត្រូវចោទ-- អង្កាល់នោះ ប៉ង់ គាត់នៅកាន់តំណែងគាត់នៅឡើយ តើជាការមានសុវត្ថិភាពចំពោះរូបលោកផ្ទាល់ដែរឬទេ ដែលក្នុងការអនុញ្ញាតសួរសំណួរទៅ ប៉ង់ ទាក់ទងទៅនឹងដំណើរការនៃគណៈអចិន្ត្រៃយ៍នៅសម័យនោះ នោះ?

[០៩:៤៩:១៩]

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន នេះហើយរបៀបៗរបបធ្វើការ មានក្នុង មានក្រៅ។ ការសម្ងាត់ៗនីមួយៗគេទុកត្រឹមៗកម្រិតណា? ហើយគេមិនឲ្យធ្លាក់ក្រោមដឹង។

**ស៖** ខ្ញុំយល់អ្វីដែលលោកបាននិយាយ ក៏ប៉ុន្តែខ្ញុំមិនច្បាស់ថាលោកយល់នូវអ្វីដែលខ្ញុំបានជម្រាបជូនលោកអម្បាញ់មិញនេះទេ។ លោកដឹងថា ប៉ង់ មានការឃ្លាំមើលគាត់កាលណោះ មុនពេលដែល ជូ ជេត ត្រូវបានគេចាប់ខ្លួន។ តើអ៊ីចឹងមែនទេ? ហើយបន្ទាប់មកទៀត បន្ទាប់ពីការចាប់ខ្លួនរបស់លោក ជូ ជេត លោកបានពិភាក្សា និងចោទសំណួរទាក់ទងទៅនឹងគណៈអចិន្ត្រៃយ៍ជាមួយបុគ្គលម្នាក់ដែលលោកដឹងច្បាស់ណាស់ថា គាត់យ៉ាងហោចណាស់ក៏គាត់ស្ថិតនៅក្រោមការឃ្លាំមើលពីរដ្ឋអំណាចដែរ។ តើការធ្វើបែបនេះ គឺថាជាការប្រុងប្រយ័ត្នដែរឬទេចំពោះលោករូបលោកផ្ទាល់នេះ ការប្រុងប្រយ័ត្នទាក់ទងនឹងសមត្ថភាពរបស់លោក-- សុវត្ថិភាពរបស់លោកក្នុងការពិភាក្សាជាមួយបុគ្គលដែលមានតំណែងយ៉ាងដូច្នេះ --ដែលស្ថិតនៅក្រោមការឃ្លាំមើលនេះ?

[០៩:៥១:២០]

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន បុគ្គលម្នាក់ៗ ដែល ប៉ុល ពត, នួន ជា មិនទុកចិត្ត អត់ដឹងខ្លួនទេ គ្មាននរណាដឹងខ្លួនទេ។ ដូច្នេះ ធ្វើការទាំងអស់គ្នាដដែល។

**ស៖** លោកសាក្សី ខ្ញុំសូមបញ្ឈប់លោកនៅពេលនេះ ពីព្រោះថាខ្ញុំមិនឲ្យ-- ខ្ញុំមិននិយាយពីអ្នកដទៃទេ ខ្ញុំនិយាយអំពីលោកផ្ទាល់។ លោកបានជម្រាបថា លោកបានដឹងអំពីការដែលថា ប៉ង់ ត្រូវស្ថិតនៅក្រោមការឃ្លាំមើល ហើយសំណួរខ្ញុំចេញពីចំណុចនេះឯង។ លោកបានទទួលដំណឹងពីការដែលថា ប៉ង់ ត្រូវបានគេឆ្លើយដាក់ ហើយនិងមានការឃ្លាំមើល ហើយ ជូ ជេត ត្រូវបានចាប់ខ្លួន ហើយលោក

បានពិភាក្សាជាមួយ ប៉ង់ អំពីដំណើរការនៃគណៈអចិន្ត្រៃយ៍។ តើលោកមិនយល់ឃើញថា នេះជាគ្រោះថ្នាក់មួយចំពោះរូបលោកទេឬ?

[០៩:៥២:៥០]

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន សំណួររបស់លោកមេធាវី ខ្ញុំយល់ តែខ្ញុំសូមឆ្លើយជាដំណាក់ឱ្យច្បាស់លាស់មួយៗអ៊ីចឹង។

ដរាបណាអចិន្ត្រៃយ៍មិនទាន់ប្រកាសថា ប៉ង់ ត្រូវចាប់ខ្លួនទេ ដរាបនោះ ប៉ង់ នៅតែមានតួនាទីមកដឹកនាំស-២១។ នាំពាក្យ ប៉ុល ពត មកដឹកនាំ ស-២១។ ស-២១ ត្រូវតែគោរពការចាត់តាំងនេះ។ ស-២១ ធ្វើឱ្យបែកការណ៍ដល់ ប៉ង់ ស-២១ ត្រូវមានទោស។ ទីបី រឿងដែលខ្ញុំសួរ ប៉ង់ អំពីករណីគឺនៅក្នុងករណីដែលអចិន្ត្រៃយ៍មិនឱ្យខ្ញុំបែកការណ៍ មិនធ្វើអាកប្បកិរិយាអីឱ្យបែកការណ៍ដល់ ប៉ង់។

**ស៖** អំមិញនេះ ខ្ញុំមិនយល់ឃ្លាចុងក្រោយរបស់លោកអម្បាញ់មិញនេះជាភាសាបារាំង។

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំសូមសង្ខេបខ្លីៗ។ រឿងដែលមានអ្នកទោសឆ្លើយដាក់ប៉ង់ ជាការសម្ងាត់ដែល ស-២១ ត្រូវតែធានាកុំឱ្យបែកការណ៍ដល់ ប៉ង់។ មិនមែនបែកការណ៍ទៅខាងក្រៅទេ គឺបែកការណ៍ដល់ ប៉ង់ ហ្នឹងតែម្តង។ មិនឱ្យបែកការណ៍ដល់ ប៉ង់។

**ស៖** បាទ ខ្ញុំយល់លោកសាក្សី។ ខ្ញុំយល់បាន--

**អ្នកបកប្រែ៖**

បាទ លោកប្រធានស្តាប់អត់ឮគាត់--។

**សួរដោយលោក អាកទួរ វែកគែន៖**

**ស៖** បាទគាត់ អង្កាល់នោះលោក ប៉ង់ នោះ គាត់នៅកាន់តំណែងគាត់នៅឡើយ។ ហើយនៅពេលដែលលោកប្រព្រឹត្តបែបនេះ គឺថាលោកដឹងច្បាស់ណាស់ ថាគាត់ស្ថិតនៅក្រោមការឃ្លាំមើល។ ហើយលោកដឹងថា ផលវិបាកនោះវាធ្ងន់ធ្ងរណាស់ តើលោកមិនប្រថុយប្រថានថានៅថ្ងៃដែលគាត់នោះចាប់ខ្លួន ហើយគាត់នឹងអាចឆ្លើយដាក់លោកនៅក្នុងបណ្តាញរបស់គាត់ ដូចថាគាត់ថា លោកជាអ្នកព្យាយាមទទួលយកព័ត៌មានស្តីអំពីគណៈអចិន្ត្រៃយ៍នោះ។ តើការធ្វើបែបនេះមិនមែនជាការប្រថុយប្រថានទេឬ? លោក ខ្លួនលោកផ្ទាល់នោះ មិនមែនអ្នក-- ខ្ញុំមិននិយាយពីអ្នកដទៃទេ គឺថារូបលោកផ្ទាល់តែម្តងនោះ?

[០៩:៥៧:០៩]

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន បញ្ហានេះទៅមិនរួចទេ។ តើបុគ្គលិក ស-២១ ដែលគេសួរចម្លើយ ប៉ង់ គេអនុញ្ញាតឲ្យ ប៉ង់ ឆ្លើយដាក់ខ្ញុំទេ? ហ្នឹងទីមួយ។ ទីពីរ បើសិនជា ប៉ង់ ប៊ានឆ្លើយ តើខាងលើជឿទេ?

**ស៖** ប៉ុន្តែអ្នកដែលកាន់តំណែងមុនលោកនោះ ជាប្រធាន ស-២១ គឺលោក ណាត ខ្លួនគាត់រូបគាត់ផ្ទាល់ហ្នឹង ក៏ត្រូវបានគេចាប់ខ្លួនដែរ ហើយទទួលរងទារុណកម្ម ហើយសម្លាប់នៅមន្ទីរ ស-២១ផ្ទាល់តែម្តង។ ហើយឥឡូវនេះលោកបែរជាមកនិយាយថា លោកមានអារម្មណ៍ថា លោកនៅខ្ពស់ជាងគេ ហើយមានទទួលការគាំពារ អ៊ីចឹងអារម្មណ៍ស្ងប់ស្ងាត់នៅក្នុងប្រព័ន្ធមួយ ដែលប្រព័ន្ធកម្ពុជាប្រជាធិបតេយ្យ ដោយហេតុដែលថា គាត់ ដែលថាលោកជាប្រធានមន្ទីរស-២១។ នេះជាអ្វីដែលលោកនិយាយអ៊ីចឹងមែនទេ?

[០៩:៥៨:៤៧]

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ណាត នេះ ដំបូងមិនមែនចេញពីឯកសារស-២១ ទេ។ ខ្ញុំសូមបញ្ជាក់។ ចម្លើយដែលឆ្លើយដាក់ ណាត នេះដំបូងគឺមិនចេញពីស-២១ ទេ។ បញ្ហានេះវាចេញពីសេចក្តីសម្រេចរបស់ បងប៉ុល ផ្ទាល់តែម្តង។ លោកមេធាវីទៅមើលឯកសារថ្ងៃ២១ មេសា ១៩៧៦ ដែលបង ប៉ុល គាត់--

**ស៖** បាទ សូមអរគុណលោកសាក្សី បាទ ខ្ញុំសូមកាត់លោកបន្តិច។ ដើម្បីឆ្លើយទៅនឹងអ្វីដែលលោកបានលើកឡើងអម្បាញ់មិញនេះ ខ្លួនលោកផ្ទាល់នៅក្នុងឯកសារ E3/106 ទំព័រទី៥ នៃសំណុំឯកសារយើង-- សំណុំរឿងយើងនេះ។ លោកបានជម្រាបទៅសហចៅក្រមស៊ើបអង្កេតថាលោក វន វ៉េត បានឆ្លើយដាក់រូបលោកនៅក្នុងចម្លើយសារភាពរបស់គាត់នោះ។ អ៊ីចឹងគឺថា វាផ្ទុយស្រឡះពីអ្វីដែលលោកបានលើកឡើងអ្វី-- អម្បាញ់មិញនេះគឺថាៗលោកជាប្រធានស-២១ គឺថាមិនមែនដែលថាលោកមិនមានគ្រោះថ្នាក់អីនោះទេ។ ថាវាអាចមានគ្រោះថ្នាក់ដែរ ដោយសារមានការឆ្លើយដាក់។ នៅក្នុងចម្លើយសារភាពនោះ ដែលយើងវ៉ៃគេដើម្បីឲ្យគេឆ្លើយយកចម្លើយនោះ។ អ៊ីចឹងបានន័យថា ទោះបីជាប្រធានក៏ដោយក៏មិនមែនថាយើងមិនមែនទទួលការគាំពារ មិនអាចមានអ្នកណាឆ្លើយដាក់នោះទេ។

[១០:០១:០៥]

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ត្រឹមត្រូវ។ ទីមួយ វន វ៉េត ឆ្លើយដាក់ខ្ញុំ ពិតជាឆ្លើយមែន! ទីពីរ គាត់ឆ្លើយហ្នឹងដាច់ដោយឡែកនៅក្នុងបញ្ជីឈ្មោះជនទាក់ទងនឹងគាត់។ ទីបី ខាងអ្នកសួរគេប្រាប់ខ្ញុំ

ដែរ។ ខ្ញុំថាឲ្យឆ្លើយ-- ឲ្យគាត់ឆ្លើយដាក់ខ្ញុំចុះ។ ហើយទីបួន ឯកសារហ្នឹង ខ្ញុំរាយការណ៍ជូន បងនួន យកទៅបង្ហាញជូន បងនួន ដែលវន វេត ឆ្លើយដាក់ខ្ញុំ។ បើ បងនួន គាត់ចាប់ខ្ញុំ គាត់ចាប់ទៅ។

**ស៖** ដូច្នេះគោលជំហររបស់លោកថ្ងៃនេះគឺថា នៅពេលដែលលោកសន្ទនាជាមួយ ប៉ង់ នៅខែមេសា ឆ្នាំ១៩៧៨ លោក-- កាលណោះលោកមិនមានការព្រួយបារម្ភអ្វីទេក្នុងការចោទសំណួរទៅគាត់នោះ នៅថ្ងៃនោះ។ តើអ៊ីចឹងមែនទេ?

**ឆ៖** ត្រឹមត្រូវហើយ ខ្ញុំគ្មានព្រួយបារម្ភនឹងបញ្ហានេះទេ។

**ស៖** ខ្ញុំសូមត្រឡប់មកនិយាយ អំពីប្រតិចារឹកនៃការសម្ភាសលោកដោយស្ទង់ការសិទ្ធិមនុស្ស។ គឺឯកសារ IS20.19 នៅក្នុងប្រតិចារឹកនេះ ប្រតិចារឹកជាសំឡេង គឺលោកបាននិយាយថា ប៉ង់ បាននិយាយការសម្ងាត់មកប្រាប់លោក បន្ទាប់ពីគាត់បានសារភាពហើយ។ តើលោកបដិសេធខ្លឹមសារនៃប្រតិចារឹកនេះដែរឬទេ?

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

[១០:០៤:១៥]

**លោក វីល្លៀម ស្មីត៖**

លោកប្រធាន ខ្ញុំចង់ឲ្យមេធាវីសួរជាក់លាក់ថា សាក្សីនិយាយអ្វីនៅក្នុងកិច្ចសម្ភាសន៍នោះ ហើយខ្ញុំគិតថាអ្វីដែលលើកឡើងមិនបានកំណត់ឡើងត្រឹមត្រូវនោះទេ។ ការពិភាក្សានៅក្នុងកិច្ចសម្ភាសន៍នោះមានលក្ខណៈទូទៅ វាមិនមែនការពិភាក្សាជាក់លាក់ពាក់ព័ន្ធទៅនឹងការចាប់ខ្លួន ជូ ជេត នោះឡើយ។ ដូច្នេះហើយ វាហាក់ដូចជាធ្វើឲ្យយើងយល់ច្រឡំទៅលើចំណុចនេះ។ ប្រហែលជាមេធាវីអាចលើកឡើងចំណុចត្រង់ណា ឬអត្ថបទត្រង់ណាយកមកសួរតែម្តង។

**លោក អាកឡូវ វែកកែន៖**

ឥឡូវដើម្បីសម្រួល ខ្ញុំចូលទៅឯកសារមួយទៀតដែលខ្ញុំចង់ដាក់ជូនទៅសាក្សីនោះ ដែលខ្ញុំយល់ថា វាមិន-- ឯកសារនេះ វាមិនធ្វើឲ្យមានការបកស្រាយជាយថាហេតុពីសំណាក់សហព្រះរាជអាជ្ញា គឺថាកំណត់ហេតុចម្លើយសារភាពរបស់លោក កាំង ហ្គេកអ៊ាវ ហៅ ឌុច ចុះថ្ងៃទី០៩ មិថុនា ឆ្នាំ១៩៩៩ ចំពោះតុលាការយោធា ដែលមានលេខ D298/655/4.25 នៅក្នុងឯកសារនេះ គឺលោកសាក្សីបានជម្រាបថា ជួនកាលខ្ញុំមានការសន្ទនាជាមួយអ្នកដែលត្រូវបានគេចោទសួរចម្លើយហើយ ដូចជាឈ្មោះ

តុក ពួន (ស៊ីក), ឈឹម សំអោក ហៅ ប៉ង់។ ប្រធានបទនោះ គឺថាខ្ញុំ-- ទាក់ទង-- ខ្ញុំចង់បានព័ត៌មានពី ប៉ុល ពត, អៀង សារី, សុន សេន, ខៀវ សំផន នៅពេលដែលគាត់នៅប្រទេសបារាំង។ ហើយទាក់ទងទៅនឹង ប៉ង់, ជួ ជេត ហៅ ស៊ី ហើយនិង វន វ៉ត នេះ កាលណោះខ្ញុំចង់ដឹងអំពីរចនាសម្ព័ន្ធរបស់បក្សប្រវត្តិបក្ស បក្សកុម្មុយនីស្តបដិវត្តន៍កម្ពុជា។ ហើយចំណុចមួយទៀត គឺថាទាក់ទងទៅនឹងការសួរចម្លើយនោះ គឺខ្ញុំធ្វើការដោយសហការជាមួយអ្នកដទៃ ហើយដោយស្ថិតនៅក្រោមការបង្គាប់បញ្ជារបស់លោក សុន សេន។ ឥឡូវនេះ ខ្ញុំចង់ជូនឯកសារនេះមួយច្បាប់ ហើយសុំការអនុញ្ញាតពីតុលាការ ហើយសុំដាក់បញ្ចាំងឯកសារនេះ។

[១០:០៧:០៣]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។ មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារពីមេធាវីយកទៅជូនសាក្សីពិនិត្យ!

**សួរដោយលោក អាកទូរ វែកគែន៖**

**ស៖** លោកសាក្សី តើលោកអាចពិនិត្យឯកសារនេះបានទេ?

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** លោកសួរមក ខ្ញុំចាំអាទិ-- នែ៎ ចំណុចនេះ លោក។

**ស៖** លោកសាក្សី អ្វីដែលលោកបានជម្រាប នៅតុលាការយោធានេះ នៅថ្ងៃទី០៩ មិថុនា ឆ្នាំ ១៩៩៩ នេះ វាហាក់ដូចជា វាផ្ទុយពីអ្វីដែលលោកបានលើកឡើងនៅទីនេះ ដែលលោកបានស្បថហើយនេះ ពីរបីនាទីមុននេះ។ តើលោកអាចពន្យល់ពីផ្ទុយគ្នានេះបានដែរឬទេ?

[១០:០៨:១៥]

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ការកត់ត្រានេះមានលក្ខណៈសង្ខេប។ ព្រឹត្តិការណ៍បីបួនបញ្ចូលគ្នា ហើយប្រើកិរិយាស័ព្ទនិងគុណស័ព្ទតែមួយម៉ាត់។ សូមបញ្ជាក់ថា ខ្ញុំសួរបង តូច ភឿន ក្រោយដែលចប់ៗសេចក្តីសារភាពច្រើនខែ ដំបៅគាត់សះស្បើយអស់ហើយ គេបានបំប៉នគាត់ស្រួលបួលហើយ ខ្ញុំឲ្យគេរៀបចំបន្ទប់មួយឲ្យខ្ញុំទៅជួបគាត់។ ពេលនុ៎ងហើយ ដែលខ្ញុំសួរអំពីជីវិត ជីវិតនែ៎ លោកគ្រូ អៀង សារី, អ្នកបង ធីរិទ្ធ, បង សុន សេន--

**ស៖** លោកសាក្សី ខ្ញុំសុំកាត់ផ្តាច់ ប៉ុន្តែលោកកំពុងនិយាយបុគ្គលផ្សេងទៀត ប៉ុន្តែខ្ញុំនិយាយអំពីបុគ្គលដែលបានរៀបរាប់នៅក្នុងកំណត់ហេតុនេះ គឺថាលោកដូច ឈឹម សំអោក ហៅ ប៉ង់ នៅក្នុង

កំណត់ហេតុនេះ គឺវាច្បាស់ណាស់ ដែលថាលោកបាននិយាយជាមួយគាត់ បន្ទាប់ពីគាត់ត្រូវបានសួរចម្លើយ បើជាលោកពិនិត្យមើលទំព័រចុងក្រោយនៃឯកសារនេះ ក្រៅពី-- សុំ--

[១០:១០:២៥]

**ប្រធានអង្គជំនុំ៖**

លោកឲ្យ អាចឲ្យសាក្សីឆ្លើយឲ្យចប់ទៅ ពីព្រោះនេះ ជាសំណួររបស់លោក។ លោកមេធាវីមិនអាចតាំងសំណួរហើយ លុះត្រាតែសាក្សីឆ្លើយតប តាមគំនិតចង់របស់ខ្លួន ទើបអនុញ្ញាតនោះទេ។ ឥឡូវនេះ អង្គជំនុំជម្រះត្រូវការស្តាប់នូវត្រង់ចំណុចនៃការឆ្លើយតបរបស់សាក្សី ចំពោះសំណួររបស់លោក ដើម្បីស្រាយបំភ្លឺឲ្យបានច្បាស់លាស់ រវាងចំណុចវិវាទគ្នា រវាងសំណួរដែលលោកសួរលើកមុនហើយនិងសួរលើកនេះ។

**លោក អាកឡូវ វែកគែន៖**

បាទ លោកប្រធានៗ យោបល់លោកប្រធានត្រឹមត្រូវហើយ ក៏ប៉ុន្តែមានអារម្មណ៍ថា សាក្សីនោះគឺថាវាដូចជាឃ្លាតឆ្ងាយចេញពីអ្វីដែលខ្ញុំចង់និយាយ ប្រធានបទរបស់ សំណួររបស់ខ្ញុំ គឺថាខ្ញុំនិយាយទាក់ទងនឹង ប៉ង់។ អ៊ីចឹងហើយ ខ្ញុំអាចទុកឲ្យគាត់និយាយឲ្យបានលម្អិតបាន។

[១០:១១:២៤]

**សួរដោយលោក អាកឡូវ វែកគែន៖**

**ស៖** អ៊ីចឹង សូមឲ្យគាត់ឆ្លើយនឹងសំណួរ សូមអញ្ជើញលោកសាក្សី!

**លោក កាំង ហ្កេកអ៊ាវ៖**

**ឆ៖** សូមបញ្ជាក់មកវិញ ជាមួយបង តូច ភឿន ខ្ញុំសួរគាត់ក្រោយគេធ្វើទារុណកម្មមែន ប៉ុន្តែដាច់ប៉ុន្មានខែមកហើយ ដាច់ពីរបី-- យ៉ាងតិចណាស់មួយខែ។ ជាមួយប៉ង់, ប៉ង់ និយាយជាមួយនឹងខ្ញុំនៅពេលដែល មិត្តហ៊ី ចាប់ ហើយខ្ញុំបញ្ជាឲ្យ មិត្តហ៊ី ចាប់ តាមការបញ្ជាពីលើមក គឺបងនួន។ ដោយឡែក ជូ ជេត ហៅ ស៊ី ក្រោយដែលសួរហើយចប់សព្វគ្រប់ច្រើនខែដែរ ខ្ញុំទៅជួបគាត់ ដើម្បីសួរគាត់អំពី--

[១០:១២:១៨]

**ប្រធានអង្គជំនុំ៖**

ឈប់ៗ មានបញ្ហាអីទៅ? មានបញ្ហាបកប្រែ? ភាសាបារាំង? បកប្រែទេ?

ពិនិត្យមើលបញ្ហាបកប្រែភាសាបារាំងយ៉ាងម៉េច? មន្ត្រីរដ្ឋបាលតុលាការវាយការណ៍ភ្លាម!

[១០:១៣:១៤]

**លោក អាកឡូរ វែកគែន៖**

លោកប្រធាន ដូចដំណើរការធម្មតាវិញហើយ ខ្ញុំស្តាប់ឮការបកប្រែជាភាសាបារាំងវិញហើយ។

**ប្រធានអង្គជំនុំ៖**

និយាយឡើងវិញ ត្រង់ចំណុចតអម្បាញ់មិញ ដែលមានបញ្ហាជំទាស់ ហើយអង្គជំនុំជម្រះបានសម្រេចនោះ លោកចាប់ផ្តើមពីចំណុចហ្នឹងឡើងវិញ ព្រោះអំមិញអត់បានមានការបកប្រែជាភាសាបារាំង។

[១០:១៣:៥៤]

**លោក អាកឡូរ វែកគែន៖**

តើលោកចង់ឲ្យខ្ញុំនិយាយឡើងវិញ? សំណួរឡើងវិញ ឬលោកចង់-- ចង់ឲ្យខ្ញុំចោទសំណួរឡើងវិញ ឬយ៉ាងម៉េច?

**ប្រធានអង្គជំនុំ៖**

លោកចាប់បន្តនូវការចម្លើយរបស់លោក តពីអ្វីដែលមានការអាក់ខាន ដោយសារការរំខានពីមេធាវីអម្បាញ់មិញ ហើយអង្គជំនុំជម្រះសម្រេចឲ្យលោកតនូវការឆ្លើយតបទៅនឹងសំណួរដែលអង្គជំនុំជម្រះចាំបាច់ត្រូវការស្តាប់នូវសក្ខីកម្មរបស់លោកតបនឹងសំណួរនេះ។

[១០:១៤:២៧]

ដោយសារអម្បាញ់មិញ វារអាក់រអួលគឺផ្នែកដែលចុងក្រោយ។ បានន័យថា ការចាប់ផ្តើមសាជាថ្មីបន្តទៅទៀតនោះ គឺមានបញ្ហា។ អ៊ីចឹងសូមបកប្រែ-- អំ សូមឆ្លើយតបទៅនឹងសំណួរបន្តពីមុន។

**លោក កាំង ហ្កេកអ៊ាវ៖**

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន បើនិយាយអំពីដែលខ្ញុំជួបបង តូច ភឿន នោះ គឺពិតជាជួប ក្រោយគាត់ត្រូវទារុណកម្មប្រហែលជាងមួយខែប៉ុនន៉ុង។ ជាងមួយខែយ៉ាងតិច។ ទីមួយ ខ្ញុំបានសួរគាត់អំពីជីវិតរស់នៅរបស់អ្នកបដិវត្តន៍ស្រុកបារាំង។ បង តូច ភឿន និយាយអំពីបងប៉ុល, បងវ៉ាន់, អ្នកបងធីរិទ្ធ។ ហើយបង តូច ភឿន បានបញ្ជាក់ថាបង សុន សេន ត្រូវបានបង ធីរិទ្ធ ហើយនិង បងវ៉ាន់អូសទាញមកចូលបដិវត្តន៍។ ដោយឡែក បង ខៀវ សំផន ខ្ញុំសួរគាត់ថា ហេតុដូចម្តេចបានជា

បង ខៀវ សំផន គោរព បងប៉ុល ខ្លាំងម្ល៉េះ?

[១០:១៥:០៤]

**ប្រធានអង្គជំនុំ៖**

ផ្អាកសិនសាក្សី! មានបញ្ហាអីទេលោកមេធាវី?

**លោក អាកទ្វូរ វ៉ែកកែន៖**

លោកប្រធាន ខ្ញុំដូចពិបាកតាមនឹងការចោទសំណួរទៅសាក្សីនេះណាស់ ព្រោះថាលោកប្រធានមិនអនុញ្ញាតឲ្យខ្ញុំគ្រប់គ្រងការចោទសំណួរនេះទៅសាក្សីនេះ។ គឺថាខ្ញុំវាឃ្លាតពីបន្ទាត់នៃការចោទសំណួររបស់ខ្ញុំ ហើយខ្ញុំសួរទៅលើ ប៉ង់ ហើយគាត់ចេញទៅផ្លូវផ្សេងទៀត ទៅបញ្ហាដែលគាត់និយាយទាក់ទងទៅនឹងបុគ្គលផ្សេងទៅវិញ។ ខ្ញុំគិតថា ដូចជាមិនពាក់ព័ន្ធអ្វីទេទៅនឹងប្រធានបទដែលយើងពិភាក្សាឥឡូវនេះ។ អ៊ីចឹងហើយបានខ្ញុំពិបាកៗគោរពកាលពេលវេលាកំណត់ ដែលអង្គជំនុំជម្រះកំណត់ឲ្យខ្ញុំណាស់។

[១០:១៦:៥៩]

ប្រសិនជាថាឲ្យ បើសិនជាអង្គជំនុំជម្រះអនុញ្ញាតឲ្យសាក្សីគឺថាទៅផ្លូវពាសវាលពាសកាលនេះដូចពិបាកណាស់។ អ៊ីចឹង សូមឲ្យអង្គជំនុំជម្រះអនុញ្ញាតឲ្យខ្ញុំសួរទៅ-- សូមឲ្យសាក្សីឆ្លើយមកសំណួរដោយផ្ទាល់តែម្តង។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះបានស្តាប់នូវចម្លើយរបស់សាក្សី បានបញ្ជាក់ច្បាស់លាស់ណាស់នូវការប្រើពាក្យពេចន៍ជាភាសាខ្មែរ ជាកិរិយាស័ព្ទ ជាគុណនាម នៅក្នុងប្រយោគដែលលោកតាំងសំណួរហ្នឹងមានពាក់ព័ន្ធមនុស្សច្រើន! ដែលអ្នកធ្វើកំណត់ហេតុនៅក្នុងតុលាការយោធានោះ បានធ្វើការសង្ខេប។ អ៊ីចឹងហើយបានជាគាត់និយាយឲ្យបានច្បាស់លាស់ ញែកឲ្យបានច្បាស់លាស់រវាងអ្វីដែលជាប្រយោគដែលលោកសួរហ្នឹង មិនអាចក្តោបយកតែម្នាក់មកធ្វើឲ្យយល់បានទេ ពីព្រោះវាពាក់ព័ន្ធទៅនឹងមនុស្សច្រើន។

[១០:១៨:០១]

នេះដែលជាបំណងប្រាថ្នារបស់អង្គជំនុំជម្រះ ថាបើលោកតាំងសំណួរហ្នឹង ដែលពាក់ព័ន្ធនឹងកថាខណ្ឌដែលលោកយោងមកហ្នឹងគឺ ឲ្យឆ្លើយឲ្យចប់ទៅ ដើម្បីឲ្យវាយល់ច្បាស់។ មិនមែនលោកតាំងសំណួរហើយ បើសាក្សីឆ្លើយតាមបំណងដែលលោកចង់ បានឲ្យឆ្លើយ បើឆ្លើយទៅខុសពីបំណងដែលលោកខ្លួនចង់ ខ្លួនយល់ គឺលែងឲ្យឆ្លើយ។ នេះ អង្គជំនុំជម្រះក្តាប់វាអត់ទាន់។

ឥឡូវលោកតាំងសំណួរឲ្យបានច្បាស់លាស់ ហើយខ្លីទៅបានហើយ ដើម្បីឲ្យគេយល់។ សាក្សីហ្នឹងគាត់យល់បាន ពីព្រោះលោកដកស្រង់នូវព័ត៌មានដែលវានិយាយពាក់ព័ន្ធនឹងមនុស្សច្រើន យកមកសួរដេញដោលនេះ មិនមែនសួរឃ្លាដែលពាក់ព័ន្ធជាមួយនឹងបុគ្គលតែម្នាក់ទេ។

[១០:១៩:00]

**លោក អាកទួរ វែកតែន៖**

បាទលោកប្រធាន ខ្ញុំយល់ ក៏ប៉ុន្តែប្រហែលជាមានបញ្ហាបកប្រែក៏មិនដឹង ដែលធ្វើឲ្យយើងមិនយល់គ្នារវាងភាគីការពារក្តី ហើយនិងលោកប្រធាននេះ។ ខ្ញុំគិតថា យើងអាចដោះស្រាយបានឆាប់រហ័សទេ។ បាទខ្ញុំអានវគ្គហ្នឹង ការសួរចម្លើយនៅឆ្នាំ១៩៩៩ នុំងទាំងស្រុង ហើយនៅក្នុងវគ្គនេះសាក្សីបានឲ្យឧទាហរណ៍ទាក់ទងនឹងបុគ្គលជាច្រើនដែលគាត់បានពិភាក្សាជាមួយនោះ។ គឺថាបុគ្គលទាំងអស់នោះសុទ្ធតែត្រូវបានទទួលទារុណកម្មនៅមន្ទីរស-២១ ក៏ប៉ុន្តែកម្មវត្ថុនៃសំណួររបស់ខ្ញុំ មិនមែនទាក់ទងទៅបុគ្គលនោះទាំងអស់នោះទេ។ គឺទៅលើលោក ប៉ង់ តែម្នាក់គត់។ លើការដែលថា អ្វីដែលទាក់ទងនឹងលោក ប៉ង់ នេះ ចម្លើយរបស់-- សេចក្តីប្រកាសរបស់លោក ឌុច នៅឆ្នាំ១៩៩៩ នេះវាផ្ទុយអ្វីដែលគាត់បានឆ្លើយនៅចំពោះមុខតុលាការនេះ ដែលគាត់បានស្បថទៀតផង គឺថាគាត់បាននិយាយអម្បាញ់មិញនេះ គាត់មិនដែលបាននិយាយជាមួយ ប៉ង់ នៅពេលដែលគាត់ឃុំខ្លួននៅមន្ទីរស-២១ នោះទេ ក៏ប៉ុន្តែនៅឆ្នាំ១៩៩៩ គាត់បានផ្តល់ឧទាហរណ៍ទាក់ទងនឹងបុគ្គលជាច្រើនដែលគាត់ធ្វើការជាមួយ ហើយដែលបុគ្គលទាំងអស់នោះត្រូវបានឃុំខ្លួននៅមន្ទីរស-២១ ហើយក្នុងចំណោមអ្នកទាំងអស់នោះ គាត់បានរៀបរាប់អំពី ប៉ង់ នេះជាកម្មវត្ថុនៃសំណួររបស់ខ្ញុំ ហើយគ្មានអ្វីលើសពីហ្នឹងទេ។ ហើយបើសិនជាសាក្សីជ្រើសរើសយកនិយាយពីបុគ្គលផ្សេងៗទៀត ក្រៅពី ប៉ង ដែលមាននៅក្នុងកំណត់ហេតុនៅឆ្នាំ១៩៩៩ នេះ ខ្ញុំមិនជាបញ្ហាអីទេ។ ក៏ប៉ុន្តែអ្វីដែលខ្ញុំចាប់អារម្មណ៍នៅក្នុងខ្សែគំនិតរបស់ខ្ញុំនោះ ខ្ញុំគិតថាលោកសាក្សីលោកប្រហែលនឹងត្រឡប់មកនិយាយអំពី ប៉ង់ វិញ។ អ៊ីចឹងថាទាក់ទងនឹង ប៉ង់ នេះ តើលោកមានមូលហេតុអ្វីដើម្បីពន្យល់អំពីភាពផ្ទុយគ្នារវាងកំណត់ហេតុឆ្នាំ១៩៩៩ នេះចំពោះមុខចៅក្រមកម្ពុជា នៅពេលដែលលោកអមដោយមេធាវីរបស់លោកដែរនៅពេលនោះ។ ហើយនិងពាក្យពេចន៍ដែលលោកបានរៀបរាប់ក្រោមសម្បថនៅចំពោះមុខតុលាការនេះ។ តើលោកអាចពន្យល់ពីភាពខុសគ្នានេះបានដែរទេ? ហើយតាមរបៀបណា?

[១០:២១:៥៤]

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន បើសិនជាមេធាវីចង់សួរតែករណី ប៉ង់ ម្នាក់ឯង សូមឲ្យមេធាវីដកឯកសារនេះចេញពីអេក្រង់ ហើយដកពីខ្ញុំចេញ ហើយសួរដោយឡែកតែពីករណី ប៉ង់ កុំឲ្យសំអាងលើឯកសារនេះ។ បើលោកសំអាងលើឯកសារនេះ គឺជាប់មនុស្សច្រើនណាស់ ដែលខ្ញុំត្រូវតែសុំបញ្ជាក់។

**ស៖** តើលោកបដិសេធកំណត់ហេតុសំណួរចម្លើយនៅថ្ងៃទី០៩ មិថុនា ឆ្នាំ១៩៩៩ នេះ ឬក៏យ៉ាងម៉េច? លោកបដិសេធខ្លឹមសារនេះ ឬក៏យ៉ាងម៉េច?

**ឆ៖** ឥឡូវលោកដកឯកសារនេះសិន ឥឡូវលោកដកឯកសារនេះពីខ្ញុំសិន ហើយលោកសួរឲ្យចំតែករណី ប៉ង់ បានហើយ។ កុំយកឯកសារមកភ្ជាប់ ហើយសួរតែម្នាក់ លោកសរុបទាំងអស់ឥឡូវហ្នឹង។

[១០:២៣:០៦]

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះលោកតាំងសំណួរចាស់ជាថ្មីជាក់លាក់ឲ្យបានច្បាស់លាស់ទៅ ហើយដកឯកសារចេញបានន័យថា លោកអាចតាំងសំណួរជាទូទៅតាមគំនិតលោកចង់ លោកមានបំណង លោកយល់ថាសំណួរនោះ គឺមានប្រយោជន៍សម្រាប់ការពារក្តីកូនក្តីរបស់លោក ដោយមិនបាច់មើលឯកសារទេពីព្រោះមើលឯកសារនេះ វាមានឈ្មោះច្រើននៅក្នុងនោះមានឈ្មោះ ប៉ង់ ដែរ។

បញ្ហាទីពីរ ចម្លើយរបស់សាក្សីរូបនេះបានឆ្លើយបញ្ជាក់ដល់ឈ្មោះ ប៉ង់ យ៉ាងច្បាស់លាស់អម្បាញ់មិញនេះ គ្រាន់តែមានការរអាក់រអួលលើការបកប្រែភាសាប៉ុណ្ណោះ ដល់ពេលតទៅវាអត់មានដោយស្តាប់អាការតហ្នឹងវាមិនបាន។ ឥឡូវលោកយល់ទេបញ្ហា គឺបញ្ហាលោកសំអាងលើឯកសារក្នុងមួយកថាខណ្ឌដែលមានមនុស្សច្រើននាក់ ដែលនាំឲ្យការបញ្ជាក់ហ្នឹងឲ្យបានច្បាស់លាស់។ តែបើសិនជាលោកតាំងសំណួរតែចំពោះ ប៉ង់ ទេ មិនបាច់ផ្អែកលើឯកសារដែលលោកយកបង្ហាញនេះទេ។ លោកអាចពិនិត្យមើលទៅ ហើយតាំងសំណួរយ៉ាងដូចម្តេចដែលលោកយល់ថា បច្ចេកទេសនៅក្នុងនៅក្នុងតាំងសំណួរនុ៎ងគឺបានជាក់លាក់ច្បាស់ និងបានប្រយោជន៍នៅក្នុងបច្ចេកទេសក្នុងការតាំងសំណួរចំពោះសាក្សីរូបនេះ។ បើពុំដូច្នោះទេ គាត់នឹងបកស្រាយដដែលទេ។

[១០:២៤:២៨]

**លោក ម៉ៃខល កាណាវាស៖**

លោកប្រធាន ខ្ញុំសង្កេតឃើញថាការសម្រេច គឺថាវាធ្វើឲ្យយើងនឹងជាប់នៅជាមួយនឹងការ

សម្រេចនៅពេលក្រោយតទៅទៀត។ ដូច្នេះការសម្រេចនេះគឺខ្ញុំសូមនិយាយថា ការសម្រេចនេះមិនត្រឹមត្រូវនោះទេ។ ជាដំបូង លោកបានជម្រាបឲ្យយើងផ្តល់នូវឯកសារបន្ទាប់មកបដិសេធ សាក្សីបដិសេធទៅលើឯកសារនេះ។ ដូច្នេះវាមិនសំខាន់ថាតើឯកសារហ្នឹងវាឈ្មោះ ឬក៏អត់នោះទេ ប៉ុន្តែគាត់ត្រូវប្រឈមជាមួយអ្វីដែលគាត់បានឆ្លើយជាមួយនឹងស្ថាប័នដទៃទៀត។

ឧទាហរណ៍ដូចជាថា ថ្ងៃនេះគាត់និយាយរឿងមួយ ចំណែកពេលក្រោយគាត់និយាយរឿងផ្សេងទៀត។ ដូច្នេះអានេះគឺជាការដែលយើងត្រូវប្រឈមមុខគ្នា។ ដូចជាថ្ងៃនេះអ៊ីចឹង គាត់ស្ថិតក្រោមសម្បថ ហើយគាត់និយាយថា គាត់មិនធ្លាប់និយាយជាមួយ ប៉ង់ ប៉ុន្តែថ្ងៃក្រោយ ដោយស្ថិតក្រោមសម្បថដូចគ្នា គាត់និយាយថា គាត់ធ្លាប់និយាយជាមួយ ប៉ង់។ ដូច្នេះ អ្វីដែលយើងអាចនិយាយបាន គឺថាគាត់កំពុងតែនិយាយកុហក គឺថា គាត់កំពុងតែបដិសេធ ហើយម្យ៉ាងទៀត វាជាការ-- ប្រសិនបើយើងបដិសេធមិនឲ្យមេធាវីការពារក្តីដើម្បីបង្ហាញថា សាក្សីហ្នឹងគាត់បដិសេធ ឬក៏គាត់និយាយកុហកហ្នឹង គឺជាការបដិសេធនូវសិទ្ធិ។ ដូច្នេះគួរតែអនុញ្ញាតឲ្យមេធាវីការពារក្តីបំពេញការងារទៅតាមបែបធម្មតា ទៅតាមអ្វីដែលបានធ្វើ។ ហើយដើម្បីឲ្យគាត់អាចបង្ហាញថា ពេលមួយគាត់និយាយរឿងមួយ ចំណែកពេលមួយទៀត ដែលគាត់ស្ថិតក្រោមសម្បថ គាត់និយាយរឿងមួយផ្សេងទៀត។

[១០:២៦:០២]

ដូច្នេះហើយ ខ្ញុំសង្ឃឹមថា យើងអាចដំណើរការនីតិវិធីបានដោយស្រួល។ ដូច្នេះ យើងៗចង់ជម្រាបថា លោក ឌុច គាត់មិនមែនជាប្រធានស-២១ ទេនៅទីនេះ។ ដូច្នេះ គាត់មិនមានសិទ្ធិក្នុងការប្រាប់ថាយើងត្រូវដំណើរការនីតិវិធីបែបនេះ ឬបែបនោះឡើយ។ ដូច្នេះ អានេះគឺអ្វីដែលខ្ញុំចង់ជម្រាប។ សូមអរគុណ។

[១០:២៦:២៧]

*(ចៅក្រមពិភាក្សាគ្នា)*

[១០:២៩:៤៩]

**ប្រធានអង្គជំនុំ៖**

បាទសូម-- អង្គជំនុំជម្រះសូមប្រគល់ភារៈជូនទៅចៅក្រម ហ្សង់ម៉ាក ដើម្បីបញ្ជាក់បញ្ហានេះឲ្យច្បាស់ ហើយនិងដោះស្រាយឲ្យបានជ្រះស្រឡះ។

សូមអញ្ជើញចៅក្រម!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

នេះខ្ញុំមិនមែនផ្តាច់ការសួរចម្លើយរបស់លោកទេ ក៏ប៉ុន្តែខ្ញុំចង់រៀបរយសណ្តាប់ធ្នាប់ឡើងវិញ ព្រោះថាមានបញ្ហាការមិនយល់គ្នា ការបកប្រែ។ អ៊ីចឹងដូច្នេះ ខ្ញុំសូមត្រឡប់និយាយអំពីសារៈសំខាន់នៃសំណួររបស់លោកវិញ។

លោកសាក្សី យើងបានស្តាប់គាត់ព្រឹកមិញហើយ យើងយល់ច្បាស់ហើយថា ទាក់ទងទៅនឹង ប៉ង់ នេះ គឺថា លោកសាក្សីបានប្រកាសថា គឺថាខ្លួនមិនដែលបានជួប ប៉ង់ នោះទេ មិនដែលបានពិភាក្សាជាមួយ ប៉ង់ នៅមន្ទីរស-២១ នោះទេ។ តើនេះជាអ្វីដែលលោកបាននិយាយ តើមែនឬទេ?

**លោក កាំង ហ្គេកអ៊ាវ៖**

ជម្រាបប្រសាសន៍លោកចៅក្រម ខ្ញុំមិនជួប ប៉ង់ នៅពេលពេញក្នុងរយៈពេលក្រោយពី ប៉ង់ ចាប់។ មុន ប៉ង់ ចាប់ មុនពេលចាប់ ខ្ញុំជួបប៉ង់ ជាហូរហែ។

[១០:៣១:៣២]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

តើនៅពេលដែលសួរចម្លើយនេះលោកមេធាវីអាចកែខ្ញុំ បើខ្ញុំយល់ច្រឡំ។ តើលោកបានទៅឯកសារមួយចំនួន គឺថាឯកសារនៃ យូ.អ៊ិន.អេច.ស៊ី.អ័រ ហើយនិងទៅការសួរចម្លើយនៅចំពោះមុខសហចៅក្រមស៊ើបអង្កេតនៃតុលាការយោធា ហើយនៅក្នុងសេចក្តីប្រកាសទាំងពីរនេះគឺប្រហែលជាមានភាពផ្ទុយគ្នា។ តើនេះជាអ្វីដែលលោកមេធាវីបានលើកឡើងកាលពីព្រឹកមិញនោះមែនទេ? គឺថាមានខុសគ្នារវាងអ្វីដែលបាននិយាយនេះ តើនេះច្បាស់ដែរឬទេ? តើលោកបានឃើញឯកសារហ្នឹង ហើយលោកបានកត់សម្គាល់ថា មានឈ្មោះ ប៉ង់ នៅក្នុងចំណោមឈ្មោះផ្សេងទៀត ឬក៏ឈ្មោះ ប៉ង់ ដែលធ្វើដោយសហចៅក្រមស៊ើបអង្កេតនៅក្នុងកំណត់ហេតុសហចៅក្រមស៊ើបអង្កេត។ ហើយនៅក្នុងករណីនេះតើលោកអាចពន្យល់បានទេថា តើមានភាពផ្ទុយគ្នាយ៉ាងម៉េច? ហេតុអីបានជាមានភាពផ្ទុយគ្នា? ឬក៏មិនមានភាពផ្ទុយគ្នា?

តើលោកយល់សំណួរខ្ញុំទេ ឬចង់ឲ្យខ្ញុំចោទសំណួរឡើងវិញលោកសាក្សី?

[១០:៣៣:១៦]

**លោក កាំង ហ្គេកអ៊ាវ៖**

ជម្រាបប្រសាសន៍លោកចៅក្រម លោកមេធាវីយកឯកសារខាងតុលាការយោធាយកមក

បង្ហាញ។ ខ្ញុំបានចាប់ផ្ដើមនិយាយថា ឯកសារនេះពាក់ព័ន្ធដល់មនុស្សច្រើននាក់។ ទីមួយៗ ជូ ជេត, ទីពីរ តូច ភឿន, ហើយទីបី ប៉ង់។ ហើយខ្ញុំបានប្រើពាក្យថា "មនុស្សទាំងបួននាក់នេះប្លែកគ្នា"។ តែតុលាការ យោធាបានសង្ខេបសរុប។ បានសង្ខេបសរុប ដោយប្រើកិរិយាស័ព្ទតែមួយ គុណស័ព្ទតែមួយ កិរិយា វិសេសតែមួយ។ ដែលខ្ញុំសូមអនុញ្ញាតញែកតាមករណីនីមួយៗដូចតទៅ៖

បានជាសំណួមពរចុងក្រោយបំផុតរបស់ខ្ញុំ ថាបើសិនជាគាត់ចង់សួរអំពីករណី ប៉ង់ កុំយោង ឯកសារនេះ។ បើលោកនៅតែយោងលើឯកសារនេះ ខ្ញុំនៅតែសុំអនុញ្ញាតអំពីតុលាការញែកបញ្ហាទាំង បួននេះដាច់ដោយឡែកពីគ្នា។

[១០:៣៦:០៩]

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវដល់ពេលសមល្មមនឹងសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក២០នាទី ចាប់ពី ពេលនេះតទៅ រហូតដល់ម៉ោងដប់មួយខ្វះប្រាំនាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការ សវនាការ។ អនុរក្សមន្ទីរឃុំឃាំង អញ្ជើញសាក្សីទៅកាន់បន្ទប់រង់ចាំសម្រាប់សាក្សី ហើយនិងឲ្យ អញ្ជើញគាត់មកកាន់កន្លែងផ្ដល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះ នៅវេលាម៉ោងដប់មួយខ្វះប្រាំនាទី។

សូមអញ្ជើញលោកមេធាវី!

[១០:៣៦:៣៥]

**លោក អាង ឧត្តម៖**

សូមគោរពលោកប្រធាន សូមគោរពលោក លោកស្រីចៅក្រម ដោយសារបញ្ហាមូលហេតុ សុខភាព ជាពិសេសបញ្ហាឈឺចង្កេះ ឆ្អឹង ខ្នង ឈឺជើង លោក អៀង សារី ស្នើសុំលះបង់សិទ្ធិក្នុងការ ចូលរួមដោយផ្ទាល់នៅបន្ទប់សវនាការសម្រាប់ថ្ងៃនេះពេញតែម្ដង ក៏ប៉ុន្តែសុំចូលរួមពីបន្ទប់សវនាការ រង់ចាំខាងក្រោមដោយប្រយោល។ អាស្រ័យហេតុនេះ សូមលោកប្រធានមេត្តាពិចារណា និងសម្រេច។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អង្គុយចុះលោកមេធាវី!

បានស្ដាប់សំណើសុំរបស់ជនជាប់ចោទ អៀង សារី ដែលបានធ្វើឡើងតាមរយៈមេធាវីការពារក្ដី របស់គាត់ ស្នើសុំលះបង់សិទ្ធិមិនចូលរួមតាមដានកិច្ចដំណើរការសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការ

នេះ ដោយទៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយតាមប្រព័ន្ធសោតទស្សន៍ពីបន្ទប់មួយខាងក្រោមបន្ទប់សវនាការនេះ សម្រាប់រយៈពេលពេញមួយថ្ងៃនេះ ដោយមូលហេតុសុខភាព។ អង្គជំនុំជម្រះសម្រេចយល់ព្រមតាមសំណើសុំរបស់ជនជាប់ចោទ អៀង សារី ដែលបានស្នើសុំតាមរយៈមេធាវីការពារក្ដីរបស់គាត់ សុំលះបង់សិទ្ធិមិនចូលរួមក្នុងកិច្ចដំណើរសវនាការដោយផ្ទាល់នៅក្នុងបន្ទប់សវនាការនេះ ដោយទៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់មួយស្ថិតនៅក្រោមបន្ទប់សវនាការនេះ តាមរយៈប្រព័ន្ធសោតទស្សន៍ពេញមួយថ្ងៃ។

[១០:៣៧:៥១]

អង្គជំនុំជម្រះតម្រូវឲ្យក្រុមមេធាវីការពារក្ដីជនជាប់ចោទ អៀង សារី ត្រូវប្រគល់មកអង្គជំនុំជម្រះភ្លាមនូវលិខិតលះបង់សិទ្ធិមិនចូលរួមផ្ទាល់ក្នុងសវនាការ ដោយមានចុះហត្ថលេខា ឬផ្ដិតស្នាមម្រាមដៃពីលោក អៀង សារី និងបង្គាប់ឲ្យផ្នែកសោតទស្សន៍តភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទរូបនេះ អាចតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ដែលបានរៀបចំសម្រាប់រូបគាត់។

បង្គាប់ឲ្យអនុរក្សមន្ទីឃុំឃាំងនាំខ្លួនជនជាប់ចោទ អៀង សារី ទៅកាន់បន្ទប់ខាងក្រោមដែលមានរៀបចំទុកជាស្រេចនូវឧបករណ៍សោតទស្សន៍សម្រាប់ជនជាប់ចោទរូបនេះអាចចូលរួមតាមដានកិច្ចសវនាការពីចម្ងាយ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:៣៨ នាទី ដល់ម៉ោង ១១:០៣ នាទី)*

[១១:០៣:០៤]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សូមៗអញ្ជើញលោក តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ!

**លោក វីល្លៀម ស្មីត៖**

សូមអរគុណលោកប្រធាន។ លោកប្រធាន ខ្ញុំចាំបាច់ឆ្លៀតឱកាសនេះ ធ្វើសេចក្តីថ្លែងការណ៍ពាក់ព័ន្ធទៅនឹងអាកប្បកិរិយា របស់ភាគីនៅចំពោះមុខអង្គជំនុំជម្រះនេះ។ តាមអនុវិធាន៤ នៃវិធាន២២ មេធាវីការពារក្តី ភាគីទាំងអស់ត្រូវតែគោរពនីតិវិធី ដែលមានភាពយុត្តិធម៌ និងប្រសិទ្ធភាព។ ខ្ញុំឃើញមេធាវីការពារក្តី១ អៀង សារី សំឡេងដែលគាត់និយាយ ភាសាដែលគាត់ប្រើប្រាស់លើកឡើងចំពោះសាក្សី គឺផ្ទុយទៅនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ។

[១១:០៤:០៩]

ខ្ញុំយល់អំពីបញ្ហារបស់មេធាវីការពារក្តី ដែលគាត់អន្ទះសាទៅលើបញ្ហាទាំងអស់នេះ។ ក៏ប៉ុន្តែយ៉ាងណាក៏ដោយភាគីទាំងអស់ត្រូវតែគោរពទៅតាមបទដ្ឋានទូទៅ ដែលយើងត្រូវគោរពទៅលើកិច្ចនីតិវិធីរបស់យើង ដើម្បីឲ្យកិច្ចដំណើរការនីតិវិធីរបស់យើងមានភាពយុត្តិធម៌។ ខ្ញុំឃើញថា ប្រសិនបើយើងធ្វើអ្វីដូចដែលមេធាវីការពារក្តី អៀង សារី នោះ ដំណើរការសវនាការរបស់យើងនឹងមិនមានប្រសិទ្ធភាពនោះឡើយ។ ខ្ញុំយល់អំពីភាពអន្ទះសាររបស់មេធាវី និងភាគី ក៏ប៉ុន្តែយ៉ាងណាក៏ដោយមេធាវីការពារក្តីភាគីទាំងអស់ត្រូវតែគោរពទៅលើគោលការណ៍ទូទៅនេះ។ មេធាវីការពារក្តី អៀង សារី គាត់គឺជាមេធាវីវិជ្ជាជីវៈ ដូច្នេះគាត់មិនត្រូវធ្វើអ្វីៗ ដែលធ្វើឲ្យមានការភ័យខ្លាចនោះទេ។ អាកប្បកិរិយារបស់គាត់គួរតែធ្វើយ៉ាងណាគោរពទៅតាមគោលការណ៍ទូទៅរបស់យើង។

អង្គជំនុំជម្រះ ខ្ញុំសូមស្នើឡើងថា ធ្វើយ៉ាងណាក៏ដោយឲ្យភាគីគោរពទៅតាមគោលការណ៍ទូទៅដូចដែលខ្ញុំបានលើកឡើងនេះ ហើយខ្ញុំសូមឲ្យគោរពទៅតាមគោលការណ៍ទាំងអស់នេះ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវី!

**លោក អាកទួរ វែកកែន៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមិនចង់ឆ្លើយតបទៅនឹងសហព្រះរាជអាជ្ញាទេ។ ខ្ញុំចង់បន្តការសួរសំណួរតទៅទៀត តើខ្ញុំអាចធ្វើបានទេលោកប្រធាន?

**ប្រធានអង្គជំនុំ៖**

បាន ប៉ុន្តែឥឡូវមុននឹងប្រគល់ឲ្យវេទិកាជូនទៅលោកបន្ត សូម-- អញ្ជើញលោកចៅក្រមហ្សង់ម៉ាក។

[១១:០៥:៥៨]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

សូមអរគុណលោកប្រធាន។ ខ្ញុំជាថ្មីម្តងទៀត ដើម្បីឲ្យបានច្បាស់ថា យើងយល់ឲ្យបានច្បាស់ ហើយសាក្សីក៏យល់ឲ្យច្បាស់អំពីខ្លឹមសារ នៃសំណួរដែលបានសួរកាលពីព្រឹកមិញនេះ។ ជាថ្មីម្តងទៀត ខ្ញុំចង់បញ្ជាក់ជូនសាក្សី នូវចំណុចដូចតទៅនេះ។ កាលពីព្រឹកមិញនេះ លោកបានបញ្ជាក់ថា លោកមានឱកាសក្នុងការជួបសន្ទនាជាមួយ ប៉ង់ អំពីបញ្ហាមួយចំនួន ជាពិសេសគឺ បញ្ហាពាក់ព័ន្ធទៅនឹងគណៈអចិន្ត្រៃយ៍ ហើយការសន្ទនាគ្នានេះ បានកើតឡើងនៅមុនពេលចាប់ខ្លួន ប៉ង់។ ដូច្នេះការសន្ទនានេះមិនមែននៅស-២១ នោះទេ ហើយមុនពេលឈប់សម្រាកលោកខាងមេធាវីការពារក្តី ខៀវ សំផន បានបង្ហាញអំពីសេចក្តីថ្លែងការណ៍របស់លោក ដែលធ្វើឡើងនៅចំពោះមុខចៅក្រមស៊ើបអង្កេត នៅតុលាការយោធា នៅថ្ងៃទី៩ ខែមិថុនា ឆ្នាំ៩៩ ហើយខ្ញុំនឹងអានមួយឃ្លានៅក្នុងសេចក្តីប្រកាសនោះ ឃ្លានោះដូចតទៅនេះ។ គេបានសួរសំណួរលោក "តើលោកមានដែលបានសួរចម្លើយអ្នកទោស ដោយខ្លួនឯងផ្ទាល់ដែរឬទេ? ហើយមានអ្នកណាខ្លះ?" លោកក៏បានឆ្លើយទៅវិញថា "មានពេលខ្លះ ខ្ញុំបានទៅសន្ទនាជាមួយអ្នកដែលបានសួរចម្លើយហើយ ដូចជា ឈ្មោះ តូច ភឿន, ឈឹម សំអោក ហៅ ប៉ង់, ជូ ជេត ហៅ ស៊ី និង វន វ៉េត"។ ហើយបន្តមកទៀត លោកបានពន្យល់ថា "លោកបានចូលរួមនៅក្នុងការសួរចម្លើយផ្ទាល់"។

[១១:០៨:០៤]

ប៉ុន្តែអាហ្នឹងជាចំណុចផ្សេង នេះខ្ញុំ-- អ្វីដែលខ្ញុំចង់និយាយនេះ គឺនិយាយអំពីកិច្ចសន្ទនា ដែលបានកើតឡើងនៅក្រោយពេលដែលអ្នកទាំងអស់នេះ ត្រូវបានសួរចម្លើយ។ បើសិនជាយើងអានឃ្លានេះទៅ យើងឃើញយល់-- យើងអាចយល់បានថា គឺការសន្ទនានេះ កើតឡើងនៅក្រោយពេលដែលពួកទាំងអស់នេះ ត្រូវបានសួរចម្លើយនៅស-២១។ ប្រសិនបើយើងភ្ជាប់ទំនាក់ទំនងទៅនឹងសេចក្តីថ្លែងការណ៍របស់លោក ជាមួយនឹងឃ្លានេះ គឺមានភាពផ្ទុយស្រឡះពីគ្នា។ តើអ្វីដែល-- តើលោកអាចពន្យល់បានទេ អំពីភាពផ្ទុយគ្នានេះ? ហើយហេតុអ្វីក៏មានភាពផ្ទុយគ្នានេះ ឬក៏តាមយោបល់លោក លោកគិតថាវាគ្មានអីផ្ទុយគ្នានោះទេ?

**លោក កាំង ហ្កេកអ៊ាវ៖**

ជម្រាបប្រសាសន៍លោកចៅក្រម។ បញ្ហានេះមើលទៅវាហាក់ដូចជាប្លែកគ្នាទំនាស់គ្នា ផ្ទុយគ្នា។

តែតាមពិតវាអត់ផ្ទុយទេ ខ្ញុំបានជម្រាបអង្គជំនុំជម្រះនៅនេះហើយថា កំណត់ហេតុនៃចៅក្រមស៊ើបអង្កេតយោធា គេសរុប គេសរុបទាំងបួននាក់ ហើយប្រើកិរិយាសព្ទតែមួយ ប្រើគុណសព្ទតែមួយ ប្រើកិរិយាពិសេសតែមួយ។ ហើយបើសិនជាសួរករណីមនុស្សណាម្នាក់ ដើម្បីឲ្យខ្ញុំបដិសេធឯកសារនេះ ខ្ញុំទទួលមិនបានទេ។ ឯកសារនេះ ខ្ញុំនៅតែទទួលស្គាល់ ក៏ប៉ុន្តែទទួលស្គាល់ថាគេសរុប។ មនុស្សដោយឡែកៗទាំងបួននេះ វាមានករណីពិសេសរបស់វា។ ឈឹម សំ--

[១១:១០:៤៥]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

សាក្សី ខ្ញុំនឹងអានឃ្លានេះឡើងវិញនេះ ហើយលោកបានសុំបញ្ជាក់ថាតើនេះជាឃ្លាអ្វីដែលលោកបាននិយាយនៅពេលនោះដែរឬទេ នៅពេលចំពោះមុខចៅក្រមស៊ើបអង្កេត? "មានពេលខ្លះ ខ្ញុំបានទៅសន្ទនាជាមួយអ្នកដែលបានសួរហើយ ដូចជាឈ្មោះ តូច ភឿន, ឈឹម សំអោក ហៅ ប៉ង់, ជូ ជេត ហៅស៊ី និង វន វ៉េត"។ តើនេះជាឃ្លាដែលលោកបាននិយាយដោយខ្លួនលោកផ្ទាល់ ឬក៏យ៉ាងណា? ឬក៏មានភាពខុសគ្នា?

**លោក កាំង ហ្គេកអ៊ាវ៖**

ជម្រាបប្រសាសន៍លោកចៅក្រម បញ្ហានេះ មិនមែនតាមចាំទេ គឺជាក់ស្តែងតែម្តង។ បង តូច ភឿន ខ្ញុំទៅជួបក្រោយ គេសួរចម្លើយគាត់មែន។ ជូ ជេត ហៅស៊ី ក៏ខ្ញុំទៅជួបក្រោយគេសួរចម្លើយគាត់ពេលដែលសុខភាពគាត់រឹងប៉ឹងអស់ហើយ។ ដោយឡែក វន វ៉េត ហើយនិង ឈឹម សំអោក ហៅ ប៉ង់។

[១១:១២:០៣]

ប៉ង់ គឺខ្ញុំជួបតាំងពីមុនគាត់ចាប់។ ដោយឡែកនៅពេលដែលគេចាប់គាត់ភ្លាម គាត់ស្តីឲ្យខ្ញុំមួយមាត់ ដែលខ្ញុំសូមមិនលើកយកមកនិយាយទេ។ ឯចំណែកជាមួយ វន វ៉េត ខ្ញុំបានបញ្ជាក់ហើយ ខ្ញុំបានទៅជួបគាត់ នៅពេលដែលមុននឹងគេសួរ។ នេះវាមានលក្ខណៈអ៊ីចឹង។ សរុបមក ក្រោយសួរពីរនាក់ មុនសួរពីរនាក់។

**សួរដោយលោក អាកទួរ វែកគែន៖**

**ស៖** លោកសាក្សី គេបានបកប្រែជាភាសាបារាំងឲ្យខ្ញុំ-- អ្វីដែលលោកបាននិយាយនេះ គឺថា ប៉ង់ មានការឆ្លើយដាក់លោកនៅក្នុងចម្លើយសារភាព។ តើនេះជាអ្វីដែលលោកបាននិយាយទេ?

[១១:១៣:៣០]

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** ប៉ង់ ត្រូវបានគេឆ្លើយដាក់ តាំងពីមុន-- ប៉ង់ ត្រូវបានគេឆ្លើយដាក់ ចាប់តាំងពីមុនថ្ងៃ១៥ សីហា ១៩៧៧។

**ស៖** ដូច្នេះ មានន័យថា យល់ច្រឡំហើយអ៊ីចឹង!

**ឆ៖** ខុសហើយ ១៥ សីហា។ ១៥ សីហា ១៩៧៧ ត្រូវបានគេឆ្លើយដាក់មុនថ្ងៃ១៥ សីហា ១៩៧៧។

**ស៖** សុំមើលទៅទំព័រចុងក្រោយ នៃកំណត់ហេតុសួរចម្លើយនៅថ្ងៃទី០៩ ខែមិថុនា ឆ្នាំ១៩៩៩ នៅចំពោះមុខតុលាការយោធា គឺទំព័រចុងក្រោយ។ សូមលោកពិនិត្យមើលទៅទំព័រទី៤។

[១១:១៥:៤៣]

**លោក អាកឡូរ វែកគែន៖**

លោកប្រធាន សូមមេត្តាអនុញ្ញាតបញ្ចាំងឃ្លាដែលខ្ញុំចង់និយាយនេះ នៅលើអេក្រង់ លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត សូមអញ្ជើញ!

**សួរដោយលោក អាកឡូរ វែកគែន៖**

**ស៖** នេះឃ្លាដែលខ្ញុំចង់អានឲ្យលោកស្តាប់ ដែលជាការបញ្ចប់សក្ខីកម្មរបស់លោក នៅថ្ងៃទី០៩ ខែមិថុនា ឆ្នាំ៩៩។ បើនិយាយ-- ក្នុងនោះមាននិយាយថា កំណត់ហេតុបានបញ្ចប់នៅវេលាម៉ោងបួនសែសិបប្រាំនាទីល្ងាចនៅថ្ងៃដដែល។ ហើយដោយបានអានខ្លឹមសារឡើងវិញឲ្យសាមីចម្លើយស្តាប់រួច យល់ព្រមផ្តិតមេដៃស្តាំទុកជាភស្តុតាងជាមួយយើងនៅខាងក្រោម។ ហើយបន្ទាប់មកទៀត នៅក្នុងឯកសារដដែលនេះ យើងឃើញនូវហត្ថលេខា ហើយនិងមេដៃ-- ស្នាមមេដៃរបស់មនុស្សបួននាក់ដែលមានមេធាវីរបស់លោក លោកខ្លួនឯងផ្ទាល់ ក្រឡាបញ្ជី ហើយនិងចៅក្រមស៊ើបអង្កេត។ សំណួររបស់ខ្ញុំដូចតទៅនេះ៖ ចៅក្រម ហើយនិងក្រឡាបញ្ជីបានបញ្ជាក់ច្បាស់ហើយថា បានអានខ្លឹមសារឡើងវិញឲ្យលោកស្តាប់នៅថ្ងៃដដែលនោះ ហើយយើងដឹងថាលោកជាអ្នកឯកទេស អ្នកជំនាញអំពីអ្វីដែលពាក់ព័ន្ធទៅនឹងការសួរចម្លើយ។ សេចក្តីប្រកាសរបស់លោកនៅថ្ងៃនេះ ចង់បញ្ជាក់ថាលោកបានបណ្តោយឲ្យមានកំហុសដែលបានប្រព្រឹត្តឡើងជាច្រើនលើក ជាច្រើនសានៅក្នុងសក្ខីកម្មរបស់លោកដោយមិនបាន

កែប្រែ តើអ៊ីចឹងមែនទេ?

[១១:១៦:៥៨]

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ភាសាដែលខ្ញុំពន្យល់ថា កំណត់ហេតុនេះជាសេចក្តីសរុប។ ខ្ញុំគិតថា និយាយប៉ុណ្ណេះ ទស្សនៈគោលជំហររបស់មនុស្សដែលមានវិចារណញ្ញាណទទួលបាន។ យល់បានការពិត ដែលជំនាន់នោះៗ យើងខ្ញុំបានឆ្លើយអ៊ីចឹង គេសរុបអ៊ីចឹង។ ដូច្នេះ បញ្ហានេះខ្ញុំពិតជាផ្តិតមេដៃមែន។ ខ្ញុំជឿថា បញ្ហានេះវាអត់ដាក់បន្ទុកអីលើខ្ញុំទេ។ បានជាខ្ញុំផ្តិតមេដៃ ដូច្នេះសរុបមកវិញ ខ្ញុំនៅតែរក្សាគោលជំហរថា ខ្ញុំពិតជាបានផ្តិតមេដៃ។ ខ្ញុំបានទទួលស្គាល់ ហើយបានអនុញ្ញាតឲ្យគេសរុបសង្ខេបអ៊ីចឹង។

**ស៖** លោក ឌុច តើលោកយល់ទេថា ខ្លឹមសារនៃកំណត់ហេតុមួយនេះ ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ៩៩ គឺលោកបានបញ្ជាក់ថា លោកបានចុះហត្ថលេខាដោយមិនបានកែប្រែ ពីព្រោះថាអ្វីទាំងអស់នេះ គឺថាមិនអាចដាក់ពិរុទ្ធភាពទៅលើបានទេ? តើលោកយល់ទេ ថាកំណត់ហេតុនេះគឺមានសារៈសំខាន់ខ្លាំងណាស់ នៅពេលដែលយើងពិនិត្យមើលដោយធៀបជាមួយនឹងប្រតិចារឹកនៃខ្សែអាត់ដែលលោកបានសម្ភាសជាមួយនឹងឧត្តមស្នងការនៃអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន នៅឆ្នាំដដែលជាមួយនឹងកំណត់ហេតុនេះ? ហើយនៅក្នុងកិច្ចសម្ភាសនោះលោកបានបញ្ជាក់ថា លោកបានជជែកពិភាក្សាជាមួយ ប៉ង់ នៅពេលដែលគាត់ត្រូវបានឃុំខ្លួននៅមន្ទីរស-២១។ តើលោកអាចពន្យល់បានទេថា ចំណុចនេះវាយ៉ាងម៉េច?

[១១:១៩:៥៣]

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន មុននឹងចៅក្រមស៊ើបអង្កេតតុលាការយោធា គេសរុបបញ្ហានេះ គេសួរខ្ញុំព្រឹត្តិការណ៍ច្រើន បានគេសរុបមកអ៊ីចឹង។ ពេលនោះៗទាំងខ្ញុំ ទាំងចៅក្រមស៊ើបអង្កេតអត់ទាន់ឃើញកំណត់ហេតុស្អីថ្ងៃប៉ុន្មានអីគេនេះទេ។ ខ្ញុំក៏ដូចជាចៅក្រមស៊ើបអង្កេតអត់ទាន់បានឃើញកំណត់ហេតុរបស់ យូ.អ៊ិន.អេច.ស៊ី.អេច.អ័រ ទេ។ ហើយទាំងអស់គ្នាក៏មិនបានឃើញខ្សែអាត់ថតសំឡេងពិតប្រាកដច្បាប់ដើមរបស់ខ្ញុំដែរ។

សូមលោកមេធាវីមេត្តាឲ្យខ្ញុំបញ្ចប់ឃ្លាខ្ញុំសិន។ បញ្ចប់បានទេ ខ្ញុំបញ្ចប់បានទេ? សូមសូមបញ្ចប់ឃ្លាខ្ញុំសិនបានទេ?

ឯចំណែកកំណត់ហេតុចុះថ្ងៃ៤, ៥, ៦ មេសា-- ឧសភា ១៩៩៩ នេះខ្ញុំបានប្រកាសរួចមក

ហើយ។ ហើយសហព្រះរាជអាជ្ញាក៏បានបញ្ជាក់ដែរថា អានេះវាជាសេចក្ដីកំណត់ហេតុ ឯចំណែកខ្សែអាត់វាទៅមួយផ្សេង។

[១១:២២:០៥]

ឯចំណែកខ្ញុំសម្អាសពិតប្រាដកជាមួយនឹង យូ.អ៊ិន.អេច.ស៊ី.អេច.អ័រ តាំងពីថ្ងៃ៣០, ថ្ងៃ១, ថ្ងៃ២ ហើយមកចប់ល្ងាចថ្ងៃ៣។ ដូច្នេះខ្ញុំបានបដិសេធកំណត់ហេតុនេះរបស់ យូ.អ៊ិន.អេច.ស៊ី.អេច.អ័រ រួចហើយ។ ឯចំណែកៗកំណត់ហេតុរបស់សហចៅក្រមស៊ើបអង្កេត ខ្ញុំនៅតែទទួលស្គាល់ ហើយសូមញែកបញ្ហាជាពីរដាក់ដោយឡែកគ្នាអ៊ីចឹង។

**ស៖** លោកសាក្សី ខ្ញុំយល់ពីបញ្ហានេះហើយ កាលពីព្រឹកមិញនេះ លោកបានបញ្ជាក់ជូនអង្គជំនុំជម្រះថា នៅសម័យដែលលោកបានជជែកពិភាក្សាជាមួយ ប៉ង់ នោះលោកមិនខ្លាចថាគេចាប់ខ្លួនលោកទេ។ តើលោកមានចាំថាលោកបាននិយាយបែបនេះទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ការសន្ទនារវាងខ្ញុំ ហើយនិង ប៉ង់ គឺការសន្ទនារវាងអ្នកត្រូវដឹកនាំ និងអ្នកដឹកនាំ។ គឺការសន្ទនារវាងអ្នកត្រូវគេដឹកនាំ ហើយនិងអ្នកដឹកនាំគេ។

**ស៖** ខ្ញុំចង់បង្ហាញជូនកិច្ចសួរ-- ការ-- កំណត់ហេតុសួរចម្លើយនៅចំពោះសហចៅក្រមស៊ើបអង្កេត អ.វ.ត.ក ដែលមានលេខកូដ D86/24 ខ្ញុំបានរៀបចំជាសំណៅគូសបន្ទាត់សម្រាប់លោកហើយខ្ញុំសូមសេចក្ដីអនុញ្ញាតពីអង្គជំនុំជម្រះមេត្តាបញ្ចាំងឯកសារនេះនៅលើអេក្រង់ ហើយនិងសូមជូនឯកសារក្រដាសជូនសាក្សី។

[១១:២៤:៥៥]

**ប្រធានអង្គជំនុំ៖**

មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារពីមេធាវីយកទៅជូនសាក្សីពិនិត្យ!

**សួរដោយលោក អាកទួរ វែកគែន៖**

**ស៖** សាក្សី ខ្ញុំបានគូសឃ្លានេះហើយ។ នៅពេលសួរចម្លើយនោះ លោកមានជំនួយពីមេធាវីរបស់លោក ហើយលោកបានបញ្ជាក់ជូនសហចៅក្រមស៊ើបអង្កេតដូចតទៅនេះ៖ សំណួររបស់សហចៅក្រមស៊ើបអង្កេត “ហេតុអីបានជាលោករក្សាទុកសំណៅដែលមិនទាន់បានកោសលុបដែលមានឈ្មោះ ហើយមានឈ្មោះដែលត្រូវបានដកចេញ?” ហើយលោកបានឆ្លើយថា “គឺនៅក្នុងក្របខ័ណ្ឌនៃបញ្ហាដែលថាមិន-- គេត្រូវចាប់ខ្លួនទាំងអស់។ ចំពោះអ្នកដែលត្រូវការពារនោះ ខ្ញុំនឹងកម្ទេចចោលនូវ

ចម្លើយសារភាព។ ឧទាហរណ៍ នៅពេលដែលខ្ញុំត្រូវបានរិះគន់ដោយ សុន សេន ដែលថាឲ្យមានឈ្មោះ ប៉ង់ នៅក្នុង ចម្លើយសារភាពនោះ ដែលជាប្រធានក្រុមការងារនៅគណៈមន្ទីរ៨៧០ របស់ ប៉ុល ពត។ ហើយរយៈ ពេលក្រោយមក គាត់បានបន្ទោសខ្ញុំផ្ទុយទៅវិញ។ ខ្ញុំបានដកឈ្មោះ ប៉ង់ ចេញ ហើយគាត់ក៏ចង់ឲ្យមានឈ្មោះ ប៉ង់ ទៅ វិញ"។ ដូច្នេះ នៅពេលនោះ លោក ហ្វ្រង់ស្វ័រ រូ ជាមេធាវីរបស់លោកបាន សួរលោកថា ដោយគិតពីអំពីបញ្ហាផ្ទុយគ្នាដែលលោកបានទាក់ទងទៅនឹងមនុស្សដែលគេបានឆ្លើយដាក់ភាគច្រើន និងការដែលប្រធាន ស-២១ របស់លោកពីមុន ត្រូវបានគេសម្លាប់នៅស-២១។ តើលោកមិនមានការភ័យខ្លាចទេថានឹងមកដល់ ថ្ងៃណាមួយនឹងមានដល់ពេលលោកនោះ? ហើយមានការឆ្លើយ "ខ្ញុំបានពន្យល់រួចហើយថា ខ្ញុំមានការភ័យខ្លាច ហើយប្រពន្ធខ្ញុំក៏មានការភ័យខ្លាចដែរ។ រៀងរាល់ពេលដែលមានការកោះហៅពីមេរបស់ខ្ញុំ ខ្ញុំកាន់តែភ័យទៅៗ"។

[១១:២៧:៤២]

លោកសាក្សី ការប្រកាសនេះ គឺវាផ្ទុយគ្នាទៅនឹងអ្វីដែលលោកទើបតែបាននិយាយពីព្រឹកមិញនេះ ដោយមានការស្បថផងដែរនៅចំពោះមុខអង្គសវនាការនេះ។ ម្តងលោកនិយាយថា លោកភ័យខ្លាចណាស់ ហើយម្តងទៀតនោះលោកបែរជានិយាយថា លោកមិនមានការភ័យខ្លាចអីទេ។ តើលោក អាចពន្យល់ពីភាពផ្ទុយគ្នានេះ ច្បាស់ក្រឡែកនេះបានទេ?

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន គ្មានការប្លែក គ្មានការខុស គ្មានការផ្ទុយអីទេ។ ការជួបអ្នកដឹកនាំ ទោះបីអ្នកនោះជាអ្វីក៏ដោយ ក៏ត្រូវតែសម្តែងការគ្រង់ កែសភាពការណ៍ជាទូទៅ។ មានព្រឹត្តិការណ៍ជាច្រើនដែលប្រពន្ធខ្ញុំគាត់ខ្លាច ហើយខ្ញុំផ្ទាល់ខ្លួនក៏មានព្រឹត្តិការណ៍ខ្លះដែលខ្លាច។ ចាប់ផ្តើមខ្លាចមែនទែននៅពេលដែលបក្ស បង នួន ជា នេះឯង បញ្ជាឲ្យគេចាប់ ង៉ែត យូ ហៅ ហុង, សួ ជា ហើយនិង សួ យក់។ សរុបមកវិញ ខ្ញុំភ័យរន្ធត់ដូចគេដូចឯងអ៊ីចឹង ចំពោះសភាពការណ៍រួម។ តែរឿងពិភាក្សាជាមួយនឹងខាងលើអត់មានបញ្ហាខ្លាចទេ ខាងក្រោមត្រូវតែរាយការណ៍ស្មោះត្រង់ជូនខាងលើ។

[១១:៣០:១២]

**សៈ** លោកមាននៅចាំទេថា សូមទោសផង ប្រហែលជាខ្ញុំអានមិនច្បាប់។ លោកប្រធាន គឺឈ្មោះ ង៉ែត យូ ហៅ ហុង បើខ្ញុំអានមិនច្បាស់សូមលោកអធ្យាស្រ័យ។ តើនៅពេលណាដែលគេចាប់ខ្លួនគាត់?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន មនុស្សទាំងបីនាក់នេះ ៗត្រូវចាប់ខ្លួនក្រោយថ្ងៃ១៥ សីហា ១៩៧៧។

**ស៖** តើលោកមានចាំទេថា តាម៉ុក បានរអ៊ូរទាំពី ជូ ជេត?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន តាម៉ុក គាត់មិនពេញចិត្តនឹង ជូ ជេត។ ខ្ញុំមើលឃើញ សង្កេតឃើញច្បាស់លាស់។

**ស៖** តើលោកចាំពីសេចក្ដីប្រកាស ដែលលោកបានធ្វើចំពោះមុខសហចៅក្រមស៊ើបអង្កេតនៅថ្ងៃទី២ ខែមេសា ឆ្នាំ២០០៨ ដែលមានលេខឯកសារ D86/24 គឺនៅចុះថ្ងៃទី២ មេសា ២០០៨ នៅទំព័របួន ERN ជាភាសាបារាំង 00195948, អង់គ្លេស 00178061, ជាភាសាខ្មែរ 00178048។ នៅក្នុងឯកសារនោះ លោកបាននិយាយថា មុននឹងចាប់ខ្លួន ជូ ជេត អ្នកនៅក្រោមបង្គាប់របស់គាត់ត្រូវបានចាប់ខ្លួនទាំងអស់ ដោយអនុវត្តតាមលទ្ធិឥណ្ឌូចិន។ ហើយលោកបាននិយាយថា គឺថា យើងត្រូវ យើងជីកស្មៅ ត្រូវជីកទាំងឫស។ តើលោកអាចចាំ តើលោកចាំនូវអ្វីដែលលោកបានបញ្ជាក់នេះបានទេ?

[១១:៣៣:៤៣]

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំនៅចាំ! ខ្ញុំនៅតែទទួលស្គាល់។

**ស៖** សេចក្ដីលម្អិតដែលលោកបានអះអាងនេះ បង្ហាញថាការចាប់ខ្លួន ជូ ជេត គឺជាការអនុវត្តផែនការតាំងពីយូរយារណាស់មកហើយ។ ហើយគឺជាការអនុវត្តទ្រឹស្ដីហូជីមិញ ដែលថា "មុននឹងកាប់ឫស្សី ត្រូវកាប់ឆ្ការបន្លាចេញសិន"។ តើលោកឯកភាពជាមួយនឹងការអាននេះទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ភាសាហ្នឹងខ្ញុំស្ដាប់មិនទាន់បានទេ។ សូមបញ្ជាក់ឲ្យស្រួលបន្តិចមក។ ខ្ញុំស្ដាប់អត់បានទេ ឆ្លើយមិនកើតទេ។

**ស៖** លោកបានបញ្ជាក់នៅក្នុងឯកសារនេះថា មុនពេលអង្គការចាប់ខ្លួន ជូ ជេត អ្នកនៅក្រោមបង្គាប់ ឬក៏កូនចៅរបស់គាត់ទាំងអស់ត្រូវចាប់ខ្លួន។ ហើយលោកបានបញ្ជាក់ថា គឺថា មានការចាប់ខ្លួនកូនចៅសិន បានចាប់ខ្លួនមេនោះ គឺជាការអនុវត្តទ្រឹស្ដីមួយរបស់ ហូ ជីមិញ។ ដែលទ្រឹស្ដីនេះមានន័យថា "មុននឹងកាប់ឫស្សីត្រូវឆ្ការបន្លាចេញសិន"។ ដូច្នេះខ្ញុំសួរសំណួរទៅកាន់លោក ដើម្បីចង់ដឹងថា តើលោកយល់ថាអ្វីដែលលោកបានប្រកាសនេះ គឺមានន័យថា ការចាប់ខ្លួន ជូ ជេត គឺត្រូវ-- គឺវាស៊ីគ្នាទៅនឹងផែនការដែលបានគិតទុកជាមុន។ គឺមានន័យថា "មុននឹងកាប់ឫស្សីត្រូវឆ្ការបន្លាចេញសិន"។

[១១:៣៦:០៩]

**ផ៖** ជម្រាបប្រសាសន៍លោកប្រធាន ខ្លឹមសារនៃការពន្យល់របស់ខ្ញុំជូនសហចៅក្រមស៊ើបអង្កេត គឺពិតជាអ៊ីចឹងមែន។

ជម្រាបបញ្ជាក់ម្តងទៀត បកប្រែហ្នឹងមិនត្រូវទេ។ ខ្ញុំបាននិយាយថា "ខ្ញុំបានពន្យល់សហចៅក្រមស៊ើបអង្កេតតាមខ្លឹមសារនៃសេចក្តីពិតទាំងអស់"។ គឺមុននឹងចាប់ ជូ ជេត គេប្រលេះអ្នកខាងក្រោម ជូ ជេត សិន។ ខ្ញុំនៅចាំបានថា នៅពេលនោះខ្ញុំបានជូន ឧទាហរណ៍ពីរនាក់ទៅសហចៅក្រមស៊ើបអង្កេតផង។

[១១:៣៧:៤៥]

**ស៖** ហេតុអ្វីបើតាមលោកដឹង ហេតុអ្វីបានជា ប៉ុល ពត គាត់មានភាពចាំបាច់ ហេតុអ្វីបានជា ប៉ុល ពត គាត់មានភាពចាំបាច់ក្នុងការជំនួស ខៀវ សំផន ទៅដោយ វន វ៉េត នៅពេលចុងក្រោយនោះ ប្រសិនបើវាជាផែនការដែលត្រូវបានសម្រេចហើយតាំងពីយូររួចមកហើយនោះ?

**ផ៖** ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំដូចមិនដែលបានជម្រាបសហចៅក្រមស៊ើបអង្កេតថា ប៉ុល ពត ជំនួស វន វ៉េត ដោយ ខៀវ សំផន ទេ។

ខ្ញុំគ្រាន់តែបានជម្រាបសហចៅក្រមស៊ើបអង្កេតថា បងខៀវ សំផន យក-- បាននាំយកបងថ្លៃរបស់បង នួន ជា នេះទៅដាក់នៅមន្ទីរពេទ្យ៧៥ មន្ទីរពេទ្យឧស្សាហកម្មជំនួសប្រពន្ធ វន វ៉េត។ ប្រពន្ធបង នួន ជា ហ្នឹង-- អ៊ូន៎! បងថ្លៃ នួន ជា ហ្នឹងបងថ្លៃស្រី មិនមែនបងថ្លៃប្រុសទេ។

[១១:៤០:០៩]

**ស៖** តើលោកមានបាននិយាយជូនអង្គជំនុំ--អ៊ំ! ចៅក្រមស៊ើបអង្កេតនៃ អ.វ.ត.ក ថា ខៀវ សំផន បានចូលរួមនៅក្នុងដំណើរការធ្វើសេចក្តីសម្រេចចក្នុងការចាប់ខ្លួន ជូ ជេត ដែរឬទេ?

**ផ៖** ជម្រាបប្រសាសន៍លោកប្រធាន រឿងនេះដដែលម្តងទៀតហើយ គឺខ្ញុំដឹងពី ប៉ង់ ថាបងហែម គាត់អញ្ជើញចូលទៅ។ បងហែម ត្រូវបានប៉ុល ពត អញ្ជើញចូលរួម--

**ស៖** តើចូលរួមដើម្បីធ្វើអី?

**ផ៖** ជម្រាបប្រសាសន៍លោកប្រធាន នេះជាបញ្ហាដដែលដែរ គឺដើម្បីពិភាក្សាក្នុងអចិន្ត្រៃយ៍ពីរឿងចាប់ខ្លួន ជូ ជេត។

**ស៖** តើលោកមានចាំទេ ថាលោកបានប្រកាសជូនសហចៅក្រមស៊ើបអង្កេតថា តាមពិត ខៀវ សំផន ត្រូវបានកោះហៅជំនួសឲ្យ វន វ៉េត ដើម្បីជម្រាបជូន ខៀវ សំផន អំពីដំណើរការនៃការបោស

សម្អាត។ តើលោកមានចាំទេ?

**ធ៖** ខ្ញុំមិនចាំទេ ខ្ញុំមិនដឹងទេ។

[១១:៤២:៤៧]

**ស៖** ដើម្បីជាប្រតិចារឹក គឺឯកសារលេខ D90-- D960 (សូមទោស) គឺ D96 អឺ--

**អ្នកបកប្រែ៖**

លោកប្រធាន សូមឲ្យមេធាវីអានលេខឯកសារ និង ERN ឡើងវិញលោកប្រធាន។

**លោក អាកទូរ វែកគែន៖**

លេខ 0019883 ខ្មែរ 00198875។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ!

**លោក វីល្លៀម ស្មីត៖**

សូមអរគុណលោកប្រធាន។ ប្រសិនបើមានសំណួរណាមួយសួរបន្ថែមទៅលើចំណុចហ្នឹង គឺយើងគួរតែបង្ហាញសាក្សីនូវអត្ថបទណាមួយឲ្យសាក្សីមើល ដើម្បីឲ្យសាក្សីហ្នឹងចងចាំឡើងវិញ។ សូមអរគុណ។

**លោក អាកទូរ វែកគែន៖**

ខ្ញុំអាចបង្ហាញបាន ក៏ប៉ុន្តែខ្ញុំមិនចង់បន្តចំពោះបញ្ហានេះទេ។ ប៉ុន្តែបើសិនបើ អង្គជំនុំជម្រះគិតថាចាំបាច់នោះ ខ្ញុំអាចបង្ហាញជូនបាន។

**ប្រធានអង្គជំនុំ៖**

មន្ត្រីរដ្ឋបាលតុលាការយកឯកសារពីមេធាវី យកទៅបង្ហាញជូនសាក្សីពិនិត្យ។

[១១:៤៥:០៧]

**ធ៖** ជម្រាបប្រសាសន៍លោកប្រធាន សូមលោកមេធាវីគូសកន្លែងណាដែលលោកឲ្យខ្ញុំអាន។ គូសឲ្យច្បាស់។

**ស៖** គឺឯកសារដែលបានគូសហើយ ហើយមានបញ្ជាក់ជាភាសាអង់គ្លេសទៀត។ ទំព័រទី៦។

**លោក អាកទូរ វែកគែន៖**

ប្រសិនបើអនុញ្ញាតលោកប្រធាន សូមមេត្តាដាក់បង្ហាញឯកសារនេះនៅលើអេក្រង់។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត! ហើយអនុញ្ញាតជាទូទៅតែម្តង នៅពេលដែលលោកដាក់ឯកសារ គឺអង្គជំនុំជម្រះអនុញ្ញាតជាទូទៅមួយ ឱ្យជំនួយការរបស់លោកដាក់បង្ហាញឯកសារ ដែលប៉ុនប៉ងក្នុងការសួរដេញដោលសាក្សី នៅលើអេក្រង់កុំព្យូទ័រនេះតែម្តងណ៎ា! សាក្សីរកឃើញនៅ? សាក្សីមើលឯកសារមានគូសទេ? មានរកឃើញអាកន្លែងគូសឃើញនៅ?

**លោក កាំង ហ្គេកអ៊ាវ៖**

ជម្រាបប្រសាសន៍លោកប្រធាន អត់ទាន់មានគូសទេ អ៊ីចឹងហើយបានជាខ្ញុំទាមទារ។

**ប្រធានអង្គជំនុំ៖**

មេធាវីអាចកំណត់នូវចំណុចទាំងណា ដែលលោកប៉ុនប៉ងក្នុងការសួរទេ ដើម្បីឱ្យការអានឯកសារការពិនិត្យឯកសាររបស់សាក្សីហ្នឹងបានលឿន ព្រោះឥឡូវគាត់ថា មិនដឹងថាអានពីកន្លែងណាទៅកន្លែងណាទេ។

[១១:៤៧:២៧]

**លោក អាកទួរ វែកកែន៖**

លោកប្រធាន ខ្ញុំត្រូវការមួយវិនាទីសិន ដើម្បីផ្ទៀងផ្ទាត់ថាតើឃ្លានេះ ត្រូវបានគូរបន្ទាត់ហើយឬនៅ សូមលោកប្រធានមេត្តាអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

អនុញ្ញាត!

មន្ត្រីរដ្ឋបាលតុលាការពិនិត្យមើល! ដកឯកសារចេញពីសាក្សីមក យកឱ្យមេធាវីគូរ មេធាវីខ្មែរហ្នឹងអាចគូរបានហើយ ចំណុចណាដែលគាត់ប៉ុនប៉ងហ្នឹង។

**លោក អាកទួរ វែកកែន៖**

លោកប្រធាន ត្រូវបានគូសរួចហើយឯកសារនេះ។

**សួរដោយលោក អាកទួរ វែកកែន៖**

**ស៖** លោកសាក្សីតើលោកឃើញទេកន្លែងដែលខ្ញុំចង់សួរហ្នឹង? សូមលោកអាន។

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំបានឃើញកំណាត់ដែលគេចង់សួរខ្ញុំហើយ ហើយខ្ញុំសូមអានដូចតទៅ។ ខ្ញុំសូមលោកមេធាវីភ្ជាប់ឃ្លាមួយកំណាត់ទៅខាងលើកុំចោល បើចោលខុសៗន័យ

ហើយ។ បើលោកលុបឃ្លាខាងដើមណ៎ា ន័យទៅផ្សេងណ៎ា ឥឡូវខ្ញុំសូមទាមទារឲ្យភ្ជាប់អាមួយកំណាត់ខាងដើមហ្នឹងមក។ នៅលើអេក្រង់លោកអត់ភ្ជាប់ឲ្យខ្ញុំទេ ដើម្បីឲ្យសាធារណជនលោកឃើញ។ ឥឡូវសូមលោកភ្ជាប់។

[១១:៥០:១០]

**ស៖** ចំពោះខ្លួនខ្ញុំផ្ទាល់ ខ្ញុំបានដាក់ឯកសារនេះជូនលោក ដោយសារតែសហព្រះរាជអាជ្ញាចង់ឲ្យដាក់ ហើយប្រសិនបើឲ្យដាក់គ្រប់ឯកសារនោះ ខ្ញុំមិនអាចបញ្ចប់ការសួរសំណួររបស់ខ្ញុំបានទេ។ ខ្ញុំបានសួរថា លោកចាំទេ អំពីការប្រកាសរបស់លោកពីចំណុចនេះ។ ខ្ញុំដាក់ឯកសារជូនលោកហើយ មានឃ្លាដែលខ្ញុំបានគូសបន្ទាត់រួចហើយ ហើយខ្ញុំបាននិយាយ-- ហើយលោកបាននិយាយថា បើតាមខ្ញុំ ខៀវ សំផន ត្រូវបានអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចប្រជុំ ដែលមានការសម្រេចចាប់ខ្លួន ជូ ជេត គឺមិនមែនដើម្បីចូលរួមក្នុងការធ្វើសេចក្តីសម្រេចនោះទេ ប៉ុន្តែដើម្បីដឹងអំពីនីតិវិធីនៃការសម្រិតសម្រាំង។ អ្វីដែលខ្ញុំចង់ដឹងនោះ គឺកម្មវត្ថុនៃការកោះហៅ ហើយអ្វីផ្សេងៗទៀតនោះ ខ្ញុំអត់ចាប់អារម្មណ៍ទេ។ តុលាការនឹងមានឱកាសក្នុងការអានចំណុចទាំងអស់នេះ។ ខ្ញុំចង់សួរទៅលើតែចំណុចជាក់លាក់នេះទេ។ ខ្ញុំចង់-- ឥឡូវនេះ ខ្ញុំចង់ឲ្យលោករំឮកការចងចាំថា លោកមានចាំទេថា លោកនិយាយនូវឃ្លាដែលខ្ញុំបានគូសបន្ទាត់នេះ។

[១១:៥១:១៣]

ខ្ញុំមិនចង់ឲ្យលោកពន្យល់អំពីខ្លឹមសារនៃឃ្លានេះទេ។ គ្រាន់តែចង់ដឹងថា លោកចាំ ឬមិនចាំ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន--

**ប្រធានអង្គជំនុំ៖**

អំមិញអាចមានការភ័ន្តច្រឡំបន្តិច ដោយសារយើងគូរបន្ទាត់ទៅវាបាត់ឃ្លាមួយកំណាត់ជាភាសាខ្មែរ។ វាពិបាកអាន មិនដឹងអានថាម៉េចទេ ព្រោះឃ្លាវាអត់ៗឲ្យអានតាំងពីដើមទេ។ ឥឡូវលោកឃើញទេ សាក្សីដាក់ហើយ ហើយអានត្រឹមតែ “ខណ្ឌ” ដូច្នេះ បើដូច្នេះតាមខ្ញុំហ្នឹងមក គឺឃ្លាហ្នឹងគ្រប់គ្រាន់ហើយនៅក្នុងន័យនេះ។ អាចយល់បានហើយជាភាសាខ្មែរ។

**លោក កាំង ហ្កេកអ៊ាវ៖**

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំសូមអានកំណាត់ដែលត្រូវការទាំងអស់គ្នា។ “ដូច្នេះបើតាមខ្ញុំ បើ ខៀវ សំផន ត្រូវបានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំ ដែលមានការសម្រេចចាប់ខ្លួន

ជួ ជេត គឺមិនមែនដើម្បីចូលរួមក្នុងការធ្វើសេចក្តីសម្រេចនោះទេ ប៉ុន្តែដើម្បីដឹងអំពីនីតិវិធីនៃការសម្រិតសម្រាំង"។

[១១:៥៣:០១]

**ស៖** សូមអរគុណចំពោះការអានទូរឃ្លានេះ។ ខ្ញុំចង់ឲ្យលោកបញ្ជាក់ជូនអង្គជំនុំជម្រះថា អ្វីដែលលោកបាននិយាយនៅថ្ងៃនោះ ដោយលោកបានប្រើប្រាស់ពាក្យថា "បើតាមខ្ញុំ"។ តើអ្វីដែលលោកទើបតែអាននេះ វាត្រូវគ្នានឹងព័ត៌មានដែលថា ប៉ង់ បានជូនលោកដែរឬទេ ឬក៏វាជាការបកស្រាយផ្ទាល់ខ្លួនរបស់លោកនៅពេលក្រោយ ដែលលោកបានផ្តល់ជូនដល់ចៅក្រមនៅថ្ងៃនោះនោះ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន នេះជាជំហររបស់ខ្ញុំ។ ជាការយល់ឃើញរបស់ខ្ញុំអំពីលោក ខៀវ សំផន តួនាទីរបស់លោក ខៀវ សំផន។

[១១:៥៤:១២]

**ស៖** នៅក្នុងការពិភាក្សាដែលលោកបាននិយាយថា លោកបាននិយាយជាមួយ ប៉ង់ នោះ តើ ប៉ង់ មានបានពន្យល់ប្រាប់លោកទេថា ហេតុអ្វីបានជាគេដក វន វ៉េត ចេញនោះ? ដកចេញពីកិច្ចប្រជុំដែលយើងនិយាយនេះ។

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន វន វ៉េត ត្រូវមិនបានគេអញ្ជើញចូលរួម ពីព្រោះបើតាម ប៉ង់ និយាយគឺ វន វ៉េត លំបាកធ្វើការណាស់។ តាមការដែល ប៉ង់ ពន្យល់ខ្ញុំ គឺ វន វ៉េត ជាមនុស្សលំបាកធ្វើការងារជាមួយខ្លាំងណាស់។ បកប្រែហ្នឹងឃ្លាតន័យដើមរបស់ខ្ញុំអស់ហើយ។ លោកបកប្រែហ្នឹងឃ្លាតន័យដើមរបស់ខ្ញុំអស់ហើយ។

**ស៖** យើងដឹងហើយថា វន វ៉េត នឹងត្រូវចាប់ខ្លួននៅដើមខែវិច្ឆិកា នៅឆ្នាំដដែលនោះ ហើយការជំទាស់ជាច្រើនលើកច្រើនសាមុនកិច្ចប្រជុំពាក់ព័ន្ធនឹង ជួ ជេត គឺជំទាស់នឹងបក្ស មុនកិច្ចប្រជុំចាប់ខ្លួន ជួ ជេត។ តើគាត់ វន វ៉េត នេះត្រូវបានគេតាមដានឃ្លាំមើលអីដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន លោកមេធាវីបានយកការបកប្រែដែលឃ្លាតចាកន័យដើមយកធ្វើជាមូលដ្ឋាននៃសំណួរថ្មី។

[១១:៥៦:២៥]

**ប្រធានអង្គជំនុំ៖**

ឥឡូវដើម្បីឲ្យច្បាស់ លោកមេធាវីកុំអាលទាន់សំណួរហ្នឹង ចាំស្តាប់ឆ្លើយចម្លើយរបស់សាក្សីលើ

សំណួរមុន ពីព្រោះសាក្សីយល់ថា ការបកប្រែភាសាទៅជាភាសាបរទេស អង់គ្លេស និងបារាំងហ្នឹងមិនត្រឹមត្រូវទេអម្បាញ់មិញនេះ។ ឥឡូវសូមសាក្សីឆ្លើយនឹងសំណួរចាស់ឡើងវិញ ហើយសុំអ្នកបកប្រែរៀបចំនូវការបកប្រែឲ្យបានត្រឹមត្រូវបំផុត ដើម្បីឲ្យដោះស្រាយបញ្ហាហ្នឹងឲ្យបានច្បាស់។

**លោក អាកទូរ វែកគែន៖**

**ស៖** តើលោកអាចនិយាយឡើងវិញអំពីមូលហេតុដែល វន វ៉េត មិនត្រូវបានគេកោះហៅឲ្យចូលរួមនៅក្នុងកិច្ចប្រជុំស្ដីពីការចាប់ខ្លួន ជូ ជេត?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ប៉ង់ ពន្យល់ខ្ញុំក្នុងន័យទូទៅថា វន វ៉េត លំបាកធ្វើការងារជាមួយខ្លាំងណាស់។ ដូច្នេះ ពេលណាមិនត្រូវចិត្តគាត់ៗអង្គុយស្ងៀមធ្វើមុខក្រម៉ូវ នេះ វន វ៉េត។ ដូច្នេះហើយៗបានជាពេលមួយចំនួននោះ គឺបង ប៉ុល មិនឲ្យគេអញ្ជើញ វន វ៉េត ចូលរួម។

**ស៖** ការមិនកោះហៅទៅក្នុងកិច្ចប្រជុំពាក់ព័ន្ធទៅនឹងការសម្រេចណាមួយនោះ គឺជារបៀបមួយនៅក្នុងការដកមនុស្សចេញ ឬក៏យ៉ាងណានៅក្នុងរបបនោះ?

[១១:៥៨:៥៩]

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន វិធានការនេះរបស់បង ប៉ុល ខ្ញុំភ្ញាក់ផ្អើលដែរ ពីព្រោះៗបង វន សមាជិកអចិន្ត្រៃយ៍មជ្ឈិម។ បង ហែម អត់មែនសមាជិកអចិន្ត្រៃយ៍មជ្ឈិមទេ។

**ស៖** តើយើងអាចនិយាយបានទេ ថាពាក់ព័ន្ធទៅនឹងប្រព័ន្ធដែលមាន ដែលអនុវត្តនៅសម័យនោះការដក វន វ៉េត ចេញពីកិច្ចប្រជុំ គឺជា យើងអាចនិយាយថាជាទណ្ឌកម្មដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំមិនហ៊ានសន្និដ្ឋានយ៉ាងម៉េចទេ ខ្ញុំគ្រាន់តែសូមព្រឹត្តិការណ៍ដោយឡែកមួយនេះ ដែលខ្ញុំភ្ញាក់ផ្អើល។

**ស៖** តើលោកមានចាំពីអ្វីដែលលោកបានជម្រាបជូនសហចៅក្រមស៊ើបអង្កេតដែរឬទេ ឬក៏លោកបានចាំទេ ថាតើនៅពេលចុងក្រោយនោះ ពេលណាដែលលោកបានឃើញ វន វ៉េត?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំឃើញ វន វ៉េត ចុងក្រោយបំផុតនៅថ្ងៃ៣ វិច្ឆិកា ១៩៧៨ (ស៊ីក)។

**ស៖** គឺថានៅពេលដែលគេឃុំខ្លួនលោកមែនទេ លោកសាក្សី?

**ឆ៖** សូមលោកសួរម្ដងទៀតមក ខ្ញុំស្ដាប់មិនទាន់ទេ។

[១២:០១:៣៧]

**ស៖** គឺជាកំហុសរបស់ខ្ញុំ ខ្ញុំសួរសំណួរមិនច្បាស់ ខ្ញុំសូមសួរឡើងវិញ។ សំណួរដែលខ្ញុំចង់សួរនោះគឺថា មុនពេលចាប់ខ្លួន តើ វន វ៉េត មានមកមន្ទីរស-២១ ដែរឬទេ?

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន នៅពេលដែលវិធានការចាប់ ប៉ង់, បងនួន គាត់ប្រើឲ្យ វន វ៉េត ទៅជួបខ្ញុំ ដោយមានកូនសំបុត្រមួយសន្លឹករបស់គាត់។ គាត់មានកូនសំបុត្រមួយសន្លឹករបស់គាត់ថា មិត្តឌុច ធ្វើការជាមួយមិត្ត វន។ ហើយគាត់ស៊ីញេ បួន។

[១២:០២:៤០]

**ស៖** តើលោកអាចនិយាយចម្លើយរបស់លោកឡើងវិញបានទេ មានបញ្ហាពាក់ព័ន្ធនឹងការបកប្រែ?

**ឆ៖** ខ្ញុំសូមនិយាយម្ដងទៀត។ ព្រោះខ្ញុំវាអត់ឮការបកប្រែដែរ។ នៅពេលចាប់ ប៉ង់ នេះ បងនួនប្រើបង វន ឲ្យទៅជួបខ្ញុំដោយមានសំបុត្រឧទ្ទេសនាមមួយច្បាប់ឲ្យខ្ញុំធ្វើការជាមួយ បងវន។

**ស៖** ក្នុងលិខិតនោះដូចជាមិនច្បាស់។ អ្នកណាធ្វើការជាមួយអ្នកណា?

**ឆ៖** គឺឲ្យខ្ញុំធ្វើការជាមួយបង វន។ សូមបញ្ជាក់បន្ថែមថា បើគ្មានសំបុត្រនេះទេ ខ្ញុំគ្មានសិទ្ធិទៅធ្វើការជាមួយ បងវន ទេ។

**ស៖** ពាក់ព័ន្ធនឹងការចាប់ខ្លួន ប៉ង់ ដែលបានកើតឡើងពីរខែក្រោយពីការចាប់ខ្លួន ជូ ជេត ហើយនិងអ្វីដែលលោកទើបតែនិយាយអម្បាញ់មិញនេះ គឺថា វន វ៉េត បានមកធ្វើការជាមួយនឹងលោក នៅពេលដែលគេចាប់ខ្លួន ប៉ង់។ តើលោកមិនយល់ឃើញថា វាចម្លែកអស្ចារ្យណាស់ណាទេឬ ចំពោះព័ត៌មានដែលលោកផ្ដល់ទៅឲ្យ-- ដែល ប៉ង់ បានប្រាប់លោកនោះ ថានៅពេលសម័យ-- នៅពេលនោះ វន វ៉េត កំពុងតែត្រូវបានគេតាមដាន ហើយនិងដកចេញអំពីដំណើរការនៃការធ្វើការសេចក្ដីសម្រេច?

[១២:០៥:១១]

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ព្រឹត្តិការណ៍ទាំងអស់នេះ បញ្ហាកាលបរិច្ឆេទគួរណាស់តែបានពិនិត្យ។ ទីពីរ បងវន ត្រូវគេកៀសចេញមិនឲ្យចូលប្រជុំអចិន្ត្រៃយ៍ ឬម្ដង ឬច្រើនដង យើងអត់ច្បាស់ ខ្ញុំអត់ច្បាស់។ ក៏ប៉ុន្តែរឿងដែលច្បាស់ គឺបងវន អញ្ជើញចូលទៅនៅពេលដែលមុនគេចាប់ បងភីម។ ដូច្នេះៗ រឿងអីក៏ដោយមុននឹងបក្សសម្រេចចាប់ ខាងលើដែលបក្សចាត់តាំងមកត្រូវតែគោរព ត្រូវតែរាយការណ៍ដោយស្មោះត្រង់ ត្រូវតែធ្វើការជាមួយ។

[១២:០៦:៣១]

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវនេះដល់ពេលសមល្មមនឹងសម្រាក ដើម្បីពិសាថ្ងៃត្រង់ហើយ។ អង្គជំនុំជម្រះប្រកាសសម្រាកដើម្បីពិសាថ្ងៃត្រង់ ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងមួយសាមសិបនាទី។

សូមអញ្ជើញ!

មួយសាមសិបនាទីសូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។ ហើយអនុរក្សមន្ទីរឃុំឃាំងអញ្ជើញសាក្សីទៅកាន់បន្ទប់សម្រាករបស់សាក្សី ហើយនិងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងសាលសវនាការនេះ នៅវេលាម៉ោងមួយសាមសិបនាទីរសៀលនេះ។

សូមអញ្ជើញលោកមេធាវី!

[១២:០៧:១៨]

**លោក ម៉ៃខល ផេសមិន៖**

សូមអរគុណលោកប្រធាន។ កូនក្តីរបស់ខ្ញុំមានបំណងចង់តាមដាននីតិវិធីសវនាការដែលនៅសល់នេះពីបន្ទប់ខាងក្រោម ដោយសារតែសុខភាពមិនអំណោយផលរបស់គាត់។ ដូច្នេះហើយយើងខ្ញុំនឹងផ្តល់ជូននូវលិខិតបោះបង់សិទ្ធិនេះជូនអង្គជំនុំជម្រះតាមក្រោយ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណមេធាវី។

អង្គុយចុះ!

បានស្តាប់សំណើសុំជនជាប់ចោទ នួន ជា ដែលបានធ្វើឡើងតាមរយៈមេធាវីការពារក្តីរបស់គាត់ស្នើសុំទៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយតាមប្រព័ន្ធសោតទស្សន៍ពីបន្ទប់មួយនៅខាងក្រោមបន្ទប់សវនាការនេះ សម្រាប់រយៈពេលកិច្ចដំណើរការសវនាការពេញមួយរសៀលនេះ។ ដោយលះបង់សិទ្ធិមិនចូលរួមតាមដានក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់ ដោយមូលហេតុបញ្ហាសុខភាព។

[១២:០៨:១២]

អង្គជំនុំជម្រះយល់ព្រមតាមសំណើសុំរបស់ជនជាប់ចោទ នួន ជា ដែលបានធ្វើឡើងតាមរយៈមេធាវីការពារក្តីរបស់គាត់ ដោយសុំបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនស្ថិតនៅក្រោមបន្ទប់សវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍ សម្រាប់រយៈពេលពេញមួយរសៀលនេះ។ ដោយគាត់លះបង់សិទ្ធិមិនចូលរួមតាមដាន ក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការ

នេះ។ អង្គជំនុំជម្រះតម្រូវឲ្យមេធាវីការពារក្ដី នួន ជា ប្រគល់មកឲ្យអង្គជំនុំជម្រះភ្លាមនូវពាក្យសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់នៅក្នុងបន្ទប់សវនាការ ដោយមានចុះហត្ថលេខា ឬផ្ដិតម្រាមដៃជាក់ច្បាស់ពីជនជាប់ចោទ នួន ជា ផង។

បង្គាប់ឲ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍ សម្រាប់ជនជាប់ចោទរូបនេះអាចតាមដានកិច្ចដំណើរការសវនាការពីចម្ងាយនៅក្នុងរយៈពេល នៃកិច្ចដំណើរការសវនាការសម្រាប់រសៀលនេះ។ បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូប នួន ជា និង ខៀវ សំផន ទៅកាន់បន្ទប់ឃុំខ្លួនខាងក្រោមបន្ទប់សវនាការនេះ។ ហើយនៅរសៀលនេះឲ្យអញ្ជើញតែលោក ខៀវ សំផន-- នាំតែលោក ខៀវ សំផន មកកាន់បន្ទប់សវនាការឲ្យបានមុនម៉ោងមួយសាមសិបនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១២:០៩ នាទី ដល់ម៉ោង ១៣:៣២ នាទី)*

[១៣:៣២:១៤]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការសវនាការ និងផ្ដល់វេទិកាជូនទៅក្រុមមេធាវីការពារក្ដីលោក ខៀវ សំផន ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។ សូមអញ្ជើញ!

**លោក អាកទួរ វែកគែន៖**

បាទ សូមអរគុណលោកប្រធាន។ ជម្រាបសួរអស់លោក លោកស្រីទាំងអស់គ្នា និងលោកសាក្សីផងដែរ។

**សួរដោយលោក អាកទួរ វែកគែន៖**

**ស៖** ពីរបីថ្ងៃមុននេះនៅទីនេះ លោកបានជម្រាបថា ខៀវ សំផន មានអង្គភាពមួយដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់គាត់។ ឧទាហរណ៍ដូចជា រោងម៉ាស៊ីនភ្លើងនៅចាក់អង្រែ។ តើព័ត៌មាននេះចេញពីប្រភពណាទាក់ទងនឹងរោងចក្រអគ្គិសនីនៅចាក់អង្រែនេះ?

[១៣:៣៣:២៩]

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន រឿងដែលខ្ញុំអះអាងថា បងហែម គ្រប់គ្រងអង្គភាពយ៉ាងតិចមួយ គឺរោងចក្រអគ្គិសនីចាក់អង្រែ មកពីមានហេតុផលដូចតទៅ៖ ប្រធានរោងចក្រអគ្គិសនីចាក់អង្រែនេះត្រូវចាប់មកស-២១ ឈ្មោះគាត់ មិត្ត-- ឈ្មោះគាត់ យក់ ដួង ហៅ ជន។ ឆ្លើយដាក់ថា បងហែម បង្រៀនគាត់ឲ្យធ្វើ សេ.អ៊ី.អា។ ហើយក្នុងគ្រប់កិច្ចការ សេ.អ៊ី.អា នៅចាក់អង្រែហ្នឹង បងហែម បង្គាប់ពេលណាត្រូវធ្វើល្អ ឲ្យត្រឹមត្រូវ ពេលណាត្រូវធ្វើក្បត់។

ដោយហេតុនេះហើយ បានជាខ្ញុំយករឿងនេះទៅសុំយោបល់ បងនួន ថាតើគួរឲ្យស្តាប់។ នេះហើយដែលខ្ញុំសន្និដ្ឋានថា ខ្ញុំជឿជាក់ថា ឬក៏ថានេះជាភស្តុតាងមួយដែលបញ្ជាក់ថា បងហែម គ្រប់គ្រងរោងចក្រអគ្គិសនីចាក់អង្រែ។

**ស៖** បាទ នេះគឺជាព័ត៌មានដែលលោកបានទទួលបាន នៅក្នុងចម្លើយសារភាពនៃមន្ទីរស-២១។ នេះបើសិនជាខ្ញុំយល់មិនច្រឡំទេ អ៊ីចឹងមែនទេ?

**ឆ៖** ត្រឹមត្រូវ។

[១៣:៣៦:១១]

**ស៖** ថ្ងៃទី២៨ មីនា ឆ្នាំ២០១២ នៅចំពោះមុខ អ.វ.ត.ក នេះលោកបានអះអាងថា នៅថ្ងៃទី៦ មករា ឆ្នាំ១៩៧៩ មុនពេលដែលវៀតណាមចូលមកដល់ប្រទេសកម្ពុជា លោកបានចូលរួមទៅនឹងកិច្ចប្រជុំមួយដែលមានវត្តមានលោក ខៀវ សំផន។ ហើយកិច្ចប្រជុំនេះ គឺធ្វើនៅពុទ្ធសាសបណ្ឌិតពុទ្ធិកវិទ្យាល័យ។ នេះជាអ្វីដែលលោកបានជម្រាបជូនមកអង្គជំនុំជម្រះ គឺក្នុងឯកសារ E2-- E1/55.1 ទំព័រ៩៥ ជាភាសាបារាំង ហើយលោកនិយាយថា លោកទទួលស្គាល់ប្រធានឃ្លាំងរដ្ឋ ហើយនៅថ្ងៃទី៦ មករា ឆ្នាំ១៩៧៩ នៅពេលដែលខ្ញុំឃើញប្រធានឃ្លាំងរដ្ឋនេះចូលរួមទៅនឹងកិច្ចប្រជុំនេះក្រោមអធិបតីភាពរបស់លោក បងហែម។ ខ្ញុំយល់ឃើញថា គាត់ជាប្រធាន ខ្ញុំ សំណួររបស់ខ្ញុំដូចតទៅនេះ។ នៅក្នុងកិច្ចប្រជុំនេះដែលលោកនិយាយថាប្រព្រឹត្តទៅមុនថ្ងៃវៀតណាមចូលមកដល់ម្តងនោះ មួយថ្ងៃនោះ តើឃ្លាំងរដ្ឋនោះជាប្រធានបទនៃកិច្ចប្រជុំមែនដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន បងហែមដឹកនាំប្រជុំនេះ អំពីសភាពការណ៍ដែលកងទ័ពយួនចូលមកដល់កម្ពុជា។ គាត់ថា “កុំភ្ញាក់ផ្អើល”ធ្វើការធម្មតាតទៅ ព្រោះ មិត្តរឿន ហើយនិង មិត្តសាន

ទប់ទល់ហើយ។

**ស៖** តើលោកនិយាយអំពីបញ្ហាអ្វីដែរ តើអ្នកណាដែលនៅក្រោមការត្រួតត្រារបស់ ហាង់ (ស៊ីក) ហើយនិង សាន នោះខ្ញុំមិនយល់នឹងអ្វីដែលលោកបានលើកឡើងនេះទេ?

**ផ៖** សភាពការណ៍ដែលខ្មាំងវ៉ៃលុកមក គឺមិត្តរឿន ហើយនិង សាន ទប់ទល់បានហើយ។ ម្ចាស់ការបាន។

[១៣:៣៩:៣៤]

**ស៖** ហើយសមមិត្តហុង ដែលលោកបាននិយាយនោះ ដែលលោកយល់ឃើញថា ខៀវ សំផន ត្រួតត្រាគាត់នៅឃ្លាំងរដ្ឋ ហើយឈ្មោះលោកហ្នឹង ឬក៏ឈ្មោះម្នាក់ផ្សេងទៀត ព្រោះខ្ញុំស្តាប់ទៅឮដូចឈ្មោះហ្នឹង?

**ផ៖** ជម្រាបប្រសាសន៍លោកប្រធាន មិត្តរឿន និង មិត្តសាន ជាលេខាកងពល។ ទាំងពីរនាក់ហ្នឹងជាលេខាកងពលពីរកងពលដាច់ដោយឡែក។

**ស៖** ខ្ញុំត្រូវយល់ឃើញថា បន្ទាប់ពីកិច្ចប្រជុំថ្ងៃទី៦ មករា ១៩៧៥ ហ្នឹងមិនបាន-- ក្នុងកិច្ចប្រជុំហ្នឹងមិនបាននិយាយអំពីឃ្លាំងរដ្ឋនោះទេ តើលោកអាចបញ្ជាក់បានដែរឬទេ?

**ផ៖** ត្រឹមត្រូវ។ គ្មាននិយាយអំពីបញ្ហាឃ្លាំងរដ្ឋទេ គឺនិយាយអំពីសភាពការណ៍យួនវ៉ៃលុក។

[១៣:៤១:០០]

**ស៖** នៅពេលដែលយើងគិតទៅហ្នឹងការប្រកាសរបស់លោក ការនិយាយរបស់លោកនៅទីនេះ ហើយនិងពេលខ្ញុំបានអានសេចក្តីប្រកាសរបស់លោកហ្នឹងឡើងវិញ ខ្ញុំមានអារម្មណ៍ថា វត្តមាន-- គ្រាន់តែវត្តមានរបស់លោក ខៀវ សំផន នៅឃ្លាំងរដ្ឋ គឺថា ធ្វើឲ្យលោកសន្និដ្ឋានបានថា គាត់ជាប្រធាន។ តើអ៊ីចឹងមែនឬទេ?

**ផ៖** ជម្រាបប្រសាសន៍លោកប្រធាន អ្នកដែលនៅប្រជុំពេលនោះច្រើន មិនមែនមានតែមិត្តរឿង ឃ្លាំងរដ្ឋមួយទេ។ ក៏ប៉ុន្តែខ្ញុំស្គាល់ មិត្តរឿង មួយខាងឃ្លាំងរដ្ឋ។ ដូច្នេះខ្ញុំសន្និដ្ឋានថា អាចបង ហែម គ្រប់គ្រងឃ្លាំងរដ្ឋមួយផងដែរ ពាក្យថា “អាច”។

**ស៖** ដូច្នេះគ្រាន់តែជាការសន្និដ្ឋានរបស់លោកនោះទេ ហើយឥឡូវនេះក៏លោកធ្វើការសន្និដ្ឋានផងដែរ តើអ៊ីចឹងមែនទេ?

**ផ៖** ខ្ញុំសន្និដ្ឋាននេះ ពេលនោះគឺ ខ្ញុំសន្និដ្ឋានអ៊ីចឹង។ ឥឡូវនេះ ខ្ញុំនៅតែសន្និដ្ឋានអ៊ីចឹង។

[១៣:៤៣:០១]

**ស៖** តើមូលដ្ឋាននៃការសន្និដ្ឋានរបស់លោកនោះ ស្ថិតនៅត្រង់វត្តមានរបស់លោក រឿង ដែលជាប្រធានឃ្លាំងរដ្ឋ ហើយនិងលោក ខៀវ សំផន ដែលមានអ្នកទាំងពីរហ្នឹងមានវត្តមាននៅក្នុងកិច្ចប្រជុំតែមួយហ្នឹង។ តើអ៊ីចឹងមែនទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ពួកអស់នេះទៅប្រជុំក្រោមអធិបតីភាពអ្នកណា? ក្រោមអធិបតីភាពអ្នកណា? អ្នកនុ៎ងជាមេពួកនុ៎ង ហើយពេលហ្នឹង បងហែម ណែនាំសភាពការណ៍តែម្នាក់ឯងគត់ គ្មានអ្នកណាតវ៉ាទេ គឺគាត់ជាអ្នកណែនាំសភាពការណ៍។

**ស៖** បើរូបលោកផ្ទាល់ លោកក៏បានចូលរួមទៅក្នុងកិច្ចប្រជុំនេះដែរ ហើយ ខៀវ សំផន មិនមែនជាប្រធានរបស់លោកដោយផ្ទាល់នោះទេ។ តើពិតជាត្រឹមត្រូវដែររទេ?

**ឆ៖** ត្រឹមត្រូវ ក៏ប៉ុន្តែខ្ញុំជឿថា លោកមេធាវីគប្បីមើលទៅខាងលើបន្តិច។ ដំបូង គឺមិត្តន៉ែ មិត្តលីន, មិត្តលីនទូរស័ព្ទមកខ្ញុំថា បងឌុច មកធ្វើការៗ ដល់ខ្ញុំជិះម៉ូតូទៅដល់មុខៗពុទ្ធកវិទ្យាល័យព្រះសុរាម្រិត ខ្ញុំឈប់ម៉ូតូ។ មិត្តលីន មកទះស្មាខ្ញុំ ទៅបងអញ្ជើញចូលទៅ! ខ្ញុំរារែកព្រោះ បងហែម មិនមែនមេខ្ញុំទេ។ តែ មិត្តរឿង រុញទៅថា ទៅៗបង! រឿង និង លីន តាមពិតខ្ញុំនិយាយ លីន នេះ អាចខ្ញុំច្រឡំ។ មិត្តលីន រុញស្មាខ្ញុំទៅ ទៅៗបងទៅធ្វើការ។ ខ្ញុំចូលទៅព្រោះខ្ញុំជឿថា មិត្តលីន មិនធ្វើផ្តេសផ្តាសទេ បើគ្មានបញ្ហា បងប៉ុល។

[១៣:៤៦:០២]

**ស៖** បាទសូមអរគុណដែលបានពន្យល់ លោកសាក្សី។ ក៏ប៉ុន្តែរឿងដែលលោករៀបរាប់នេះ លោកបានរៀបរាប់នៅក្នុងកំណត់ហេតុហ្នឹងដែរ លោកយល់ស្របជាមួយខ្ញុំដែរឬទេ? គឺថា ដែលថាវាមិនមានឥទ្ធិពលអ្វីទៅលើថា លោក ខៀវ សំផន មានទំនួលខុសត្រូវលើឃ្លាំងរដ្ឋនោះទេ។ តើលោកយល់ស្របនឹងខ្ញុំដែរឬទេ?

**ឆ៖** អរគុណ។ ហ្នឹងលោកសន្និដ្ឋានទៅម្ខាង ខ្ញុំសន្និដ្ឋានទៅម្ខាង។ ខ្ញុំមានហេតុផលរបស់ខ្ញុំ។ លោកមានហេតុផលរបស់លោក។ ខ្ញុំនៅតែតាំងចិត្តថា ខ្ញុំនៅតែមានហេតុផលថាខ្ញុំរក្សាសេចក្តីសន្និដ្ឋានរបស់ខ្ញុំ។ ព្រោះនៅក្នុងរបបណាក៏ដោយ មិនដែលអ្នកណាដែលមិនៗ-- មិនដែលអ្នកណាដែលទៅចុះភារកិច្ចអប់រំ ឬក៏ផ្សព្វផ្សាយព័ត៌មានអីទៅឲ្យក្រៅពីកូនចៅខ្លួនទេ។ ពេលហ្នឹងហើយដែលខ្ញុំចូលទៅហ្នឹង គេនៅហើយស្រេចជុំ ទុកសល់តែកៅតែមួយទេ។ ដែល មិត្តរឿង រុញមកឲ្យខ្ញុំអង្គុយ មិត្តរឿង ម្តងនេះ

គឺ មិត្តរឿង រុញមកឲ្យខ្ញុំអង្គុយ។

[១៣:៤៨:១៨]

**សះ** តើមានមូលហេតុផ្សេងមួយទៀតក្រៅពីអ្វីដែលលោកបានលើកឡើងនេះ ដែលអាចថា នាំឲ្យលោកចាត់ទុកថាមានទំនាក់ទំនងរវាងលោក ខៀវ សំផន នឹងឃ្លាំងរដ្ឋដែលៗ ហើយនិងថារឿងនេះជាអ្នកនៅក្រោមបង្គាប់របស់លោក ខៀវ សំផន។ តើមានអ្វីមួយដែលធ្វើឲ្យលោកគិតថា លោក ខៀវ សំផន មានទំនួលខុសត្រូវលើឃ្លាំងរដ្ឋដែរឬទេ? ឬក៏គ្រាន់តែជាអ្វីដែលលោកបានលើកឡើងអម្បាញ់មិញនេះទេ? ដែលថាលក្ខណៈទូទៅ ថាអាចឲ្យយើងចាត់ទុកថាគ្រប់អ្នកដែលមានវត្តមាននៅក្នុងកិច្ចប្រជុំហ្នឹងសុទ្ធតែជាកូនចៅរបស់លោក ខៀវ សំផន ទាំងអស់នោះ?

[១៣:៤៩:០៧]

**ឆះ** ត្រឹមត្រូវ។ ខ្ញុំនៅតែជឿថា អ្នកទាំងប៉ុន្មានដែលអង្គុយជុំវិញ បងហែម ជាកូនចៅរបស់បងហែម រួមទាំង មិត្តរឿង ផង។ សូមបញ្ជាក់ថា ពេលនុ៎ង បងហែម អត់និយាយរកខ្ញុំមួយម៉ាត់ទេណ៎ា។ ញញឹមដាក់ក៏អត់ដែរ។ នេះគាត់។

**សះ** តើវាអាចដែរឬទេ ដែលថាលោកបានទាញយកព័ត៌មាននេះដែលថា ទាញការសន្និដ្ឋានដែលថាលោក ខៀវ សំផន នេះជាប្រធានឃ្លាំងរដ្ឋនេះ ថាទាញយកសេចក្ដីសន្និដ្ឋាននេះចេញពីចម្លើយសារភាពពីមន្ទីរស-២១ តើអ៊ីចឹងមែនទេ?

**ឆះ** ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំអត់យកខ្លឹមសារនៃសេចក្ដីសារភាពទៅនិយាយទេ។

**សះ** ខ្ញុំយល់ ប៉ុន្តែនេះជាសំណួររបស់ខ្ញុំចោទទៅលោកអ៊ីចឹង។

**ឆះ** លោកមេធាវី ការបកប្រែដាច់ឃ្លាយើងមួយកំណាត់ម្នាក់ហើយ អស់ហើយណ៎ា។ លោកសួរខ្ញុំឡើងវិញ។

**អ្នកបកប្រែ៖**

លោកប្រធានអ្នកបកប្រែប្រាប់ថា កុំឲ្យសាក្សីចុចមីក្រូលឿនពេក ពីព្រោះថា អ៊ីចឹងខាងអ្នកបកប្រែទៅអង់គ្លេសនោះគាត់ស្ដាប់អត់បានទេ។

**លោក កាំង ហ្កេកអ៊ាវ៖**

បាទ។

[១៣:៥១:២៦]

**លោក អាកទួរ វែកគែន៖**

បើអ៊ីចឹងបើសិនជាចម្លើយរបស់លោកហ្នឹងទៅបកប្រែមិនល្អហ្នឹង។ អ៊ីចឹងសូមលោករៀបរាប់ចម្លើយហ្នឹងឡើងវិញ ដើម្បីឲ្យគេបកប្រែពេញបរិបូរ។

**ប្រធានអង្គជំនុំ៖**

សំណួរ អម្បាញ់មិញគាត់អត់ស្ដាប់សំណួរដាច់។ លោកតាំងសំណួរចុងក្រោយនេះឡើងវិញ ដើម្បីឲ្យគាត់បានស្ដាប់សំណួរច្បាស់ ពីព្រោះសំណួរអំមិញបកប្រែតែពាក់កណ្ដាលទេ អ៊ីចឹងវាអត់យល់សំណួរ។ លោកតាំងសាជា-- ចុងក្រោយនេះសាជាថ្មីម្ដងទៀតទៅ ដើម្បីឲ្យគាត់ស្ដាប់បាន ហើយសូមរម្លឹកដល់សាក្សី និងលោកមេធាវីផងដែរ ឲ្យមានគម្លាតគ្នាបន្តិច ដើម្បីឲ្យរង់ចាំឲ្យមានការបកប្រែចប់ ដើម្បីបន្តការសួរ ឬក៏និយាយ ហើយនៅក្នុងក៏នេះកត់សម្គាល់ផងដែរថា សូមលោកមេធាវីមានការបង្អង់បន្តិចពីព្រោះសាក្សីគាត់ស្ដាប់ជាភាសាបារាំង អ៊ីចឹងគាត់ នៅពេលគាត់ស្ដាប់ហ្នឹង គាត់ស្ដាប់ការបកប្រែភាសាហ្នឹងមិនទាន់ចប់ទេ។ អ៊ីចឹងហើយបានជាគាត់មិនអាចតបតទៀតបាន។ ដល់ពេលលោកមេធាវីចាប់ផ្ដើមទៅ គាត់ដាច់មួយកំណាត់។ អ៊ីចឹងសូមឲ្យអង់បន្តិច ដើម្បីឲ្យមានឱកាសក្នុងការនិយាយគ្នាហ្នឹងបានច្បាស់លាស់។ សូមអញ្ជើញ!

[១៣:៥២:៣៩]

**លោក អាកទួរ វែកគែន៖**

បាទ ខ្ញុំយល់លោកប្រធាន។

**សួរដោយលោក អាកទួរ វែកគែន៖**

**ស៖** បាទសំណួរខ្ញុំសាមញ្ញទេ។ តាមការសង្កេតរបស់លោកថ្ងៃទី៦ មករា ឆ្នាំ១៩៧៩ ដែលលោកទើបតែបានលើកឡើងនេះ តើមានព័ត៌មានដែលលោកបានទាញចេញពីចម្លើយសារភាពនៅមន្ទីរ ស-២១ ដែរឬទេ?

**លោក កាំង ហ្កេកអ៊ាវ៖**

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន បញ្ហាហ្នឹងពីរដាច់ដោយឡែកពីគ្នា។ ទីមួយការសង្កេតរបស់ខ្ញុំនៅថ្ងៃ០៦ មករា ១៩៧៩ នេះជាព្រឹត្តិការណ៍មួយដែលនាំឲ្យខ្ញុំសន្និដ្ឋានថា បងហែម អាចគ្រប់គ្រងឃ្លាំងរដ្ឋមួយអង្គភាពទៀតយ៉ាងតិច។ ឯចំណែករឿងទីពីរ សេចក្ដីសារភាពរបស់ មិត្តជន។ ជនឆ្លើយថា មេវាខាងដែលបក្សកុម្មុយនីស្ដកម្ពុជាចាត់តាំងទៅហ្នឹង គឺបងហែម បង្រៀនវាជា សេ.អ៊ី.អា

ហើយដឹកនាំវាធ្វើការងារ សេ.អ៊ី.អា។ ដូច្នេះរឿងដែល បងហែម គ្រប់គ្រងអគ្គិសនីចាក់អង្រែ ជារឿងដែលអ្នកផងដឹង។

[១៣:៥៥:០២]

អ៊ីចឹងហើយបានវាឆ្លើយដាក់ បងហែម មេវាខាងបក្សកុម្មុយនីស្តកម្ពុជាដែលបក្សកុម្មុយនីស្តកម្ពុជាចាត់តាំងទៅ។ ដូច្នេះ ខ្ញុំអត់និយាយដល់រឿងខ្លឹមសារនៃសេចក្តីសារភាពរបស់ ជន ទេ។ ខ្ញុំសូមបន្តបន្តិចទៅទៀត។ ពេលដែលខ្ញុំទៅរាយការណ៍ជម្រាប បងនួន។ អត់និយាយម៉េចទេ ពីរឿងមិត្ត ជន ឆ្លើយដាក់ បងហែម។ បានន័យថា គាត់ទទួលស្គាល់ថា បងហែម គ្រប់គ្រង មិត្តជន ខាងបក្សកុម្មុយនីស្តកម្ពុជាហើយ។ ដោយឡែក គាត់កំហែងខ្ញុំ តែរឿងខ្ញុំបណ្តោយឲ្យ មិត្តជន ឆ្លើយដាក់បង បងហែម។ បងនួន គាត់កំហែងខ្ញុំ។

[១៣:៥៦:២៦]

**ស៖** នៅពេលណា? បាទ ដើម្បីសង្ខេបលោកសាក្សី ព័ត៌មានទាំងអស់ដែលនាំឲ្យលោកសន្និដ្ឋានថា លោក ខៀវ សំផន មានទំនួលខុសត្រូវលើអង្គភាពមួយ គឺជាព័ត៌មាន។ ទីមួយ គឺថាការដែលថាលោកមិនព្រមចូលទៅក្នុងកិច្ចប្រជុំហ្នឹង។ ក៏ប៉ុន្តែដោយសារលោក ខៀវ សំផន នៅទីនោះ ហើយគេបង្ខំឲ្យលោកចូលទៅកិច្ចប្រជុំនោះ។ ហើយមូលហេតុទីពីរ គឺថាដោយសារថាកិច្ចប្រជុំនោះឋិតនៅក្នុងអធិបតីភាពរបស់លោក ខៀវ សំផន។ ហើយទីបី គឺថាដោយសារមានចម្លើយសារភាពនៅមន្ទីរស-២១ ដែល១ឆ្លើយដាក់លោក ខៀវ សំផន ថាគាត់មានទំនាក់ទំនងជាមួយនឹងប្រធានរោងចក្រអគ្គិសនី។ តើការសង្ខេបរបស់ខ្ញុំនេះ ត្រឹមត្រូវដែរឬទេ?

**ឆ៖** ត្រឹមត្រូវជាមូលដ្ឋាន។

[១៣:៥៧:៥៥]

**ស៖** សូមអរគុណ។ បាទ លោកនិយាយអម្បាញ់មិញថា លីន ជាអ្នកកោះហៅលោកទៅប្រជុំ។ ក៏ប៉ុន្តែខ្ញុំយល់ឃើញថា នៅពេលកិច្ចស៊ើបសួរលោកបាននិយាយអំពី លីន ដំបូងលោកនិយាយពី លីន ហើយពី ធន (ស៊ីក) ផងដែរ ដូចដែលបាន-- លោកបានរៀបរាប់នៅក្នុង-- ចំពោះមុខសវនាការនេះ។ តើលោកចាំទេ អំពីបុគ្គលផ្សេង១ដែលលោកបានលើកឡើងនេះ។

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន អាចពីរនាក់ណា? អាចខ្ញុំច្រឡំ១ ព្រោះពីរនាក់ហ្នឹងមានសិទ្ធិទូរស័ព្ទមកខ្ញុំដូចគ្នា។

**ស៖** តើគេបានទូរស័ព្ទទៅកោះហៅលោកឲ្យទៅចូលរួមកិច្ចប្រជុំហ្នឹងមែនទេ? តើលោកអាចនិយាយដោយបើកមីក្រូទេ ព្រោះថាយើងមិនបានស្តាប់លោកឮទេអម្បាញ់មិញនេះ?

**ឆ៖** ត្រឹមត្រូវ ពីរនាក់ហ្នឹងមានសិទ្ធិទូរស័ព្ទមកហៅខ្ញុំទៅធ្វើការដូចគ្នា។ ដោយឡែក មិត្តលីន មិនមែនមានសិទ្ធិទូរស័ព្ទមកខ្ញុំ-- ហៅខ្ញុំទៅធ្វើការទេ។ មិនមែនគ្រាន់តែៗ មានសិទ្ធិទូរស័ព្ទមកហៅខ្ញុំទៅធ្វើការទេ គាត់មានសិទ្ធិរហូតឲ្យខ្ញុំត្រៀមកម្លាំងចាំទទួលមនុស្សដែលគាត់យកមកឲ្យ។

[១៤:០០:១៦]

**ស៖** សូមអរគុណ។ នៅក្នុងដំណាក់កាលស៊ើបសួរនោះ លោកបានលើកឡើងជារៀបរាប់ជាច្រើនដង ថាលោករៀបរាប់អំពីសភាពភ័យខ្លាចរបស់លោកចាប់ពីថ្ងៃដែលលោក-- គឺថាលោកបានកំណត់ពីថ្ងៃទី០២ ទី០៣ មករា នៅពេលដែលលោក-- ដែលប្រធានមន្ទីរស-២១ បញ្ជាឲ្យលោកសម្លាប់អ្នកទោសជាចុងក្រោយ។ តើលោកចាំអំពីការពិពណ៌នាទាក់ទងទៅនឹងសភាពភ័យខ្លាចរបស់លោកដែរឬទេ? ឬក៏លោកចង់ឲ្យខ្ញុំរំឭកលោកឡើងវិញនូវពាក្យពេចន៍ដែលលោកបានរៀបរាប់នោះ?

**ឆ៖** ខ្ញុំនៅចាំ នៅចាំទាំងអស់។

**ស៖** តើលោកអាចនិយាយម្តងទៀតបានទេ?

[១៤:០១:១៦]

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ក្រោយពីខ្ញុំទទួលបានបញ្ជាពី បងឌួន មកឲ្យកម្ទេចអ្នកទោសដែលនៅសល់ទាំងប៉ុន្មានឲ្យអស់។ ខ្ញុំមកដល់ខ្ញុំប្រាប់ មិត្តហ៊ី តាមបញ្ជានេះ ឲ្យគេអនុវត្ត ព្រោះការងារអស់នេះគេទទួលភារៈផ្ទាល់។ ឯចំណែកខ្ញុំវិញ ខ្ញុំថា ឱ! កម្ទេចទាំងអស់ វន វ៉េត ទើបនឹងចាប់ហើយថ្មីៗ។ ដូច្នេះ ខ្ញុំទេដឹងដែលត្រូវចាប់។ ពេលហ្នឹងហើយដែលខ្ញុំតក់ស្លុតធ្វើអីមិនកើតទេ ខ្ញុំដេកនៅហ្នឹងផ្ទះ។ សម្លាធឈាម ដៃម្ខាងទៅផ្សេង ដៃម្ខាងទៅផ្សេង។ ប្រពន្ធខ្ញុំដាស់យ៉ាងម៉េច ក៏ខ្ញុំមិនងើប ងើបតែពេលបាយ ឌុបប្រពន្ធទៅហូបបាយ ត្រឡប់មកវិញដេកទៀត។ កន្លែងគូររូប ឆ្លាក់រូបដែលខ្ញុំធ្លាប់តែទៅរាល់ថ្ងៃ ក៏ខ្ញុំលែងទៅ គ្មានអ្នកណាឃើញខ្ញុំចេញពីផ្ទះទេ។

**ស៖** គឺថាលើកលែងតែថា ដើម្បីទៅកិច្ចប្រជុំនៅថ្ងៃទី០៦ មករា ដែលគេផ្តល់ព័ត៌មានសំខាន់នេះដែលថា ប្រាប់លោកថា អ្វីៗទាំងអស់ដំណើរការទៅល្អ ហើយភ្នំពេញហ្នឹងគេការពារបាន ហើយឲ្យលោកបន្តសកម្មភាព ហាក់ដូចជាពុំមានរឿងអ្វីកើតឡើងអីចឹង។ តើអីចឹងមែនដែរឬទេ លោកសាក្សី?

**ឆ៖** ត្រឹមត្រូវ។

[១៤:០៤:០៣]

**ស៖** ខ្ញុំសូមរំឭកលោកម្ដងទៀតនូវសេចក្ដីថ្លែងការណ៍របស់លោកនៅថ្ងៃទី០៤ កក្កដា ឆ្នាំ២០០២ នៅចំពោះមុខតុលាការយោធា។ គឺលេខ-- ឯកសារលេខ 288/6.52/4.43 ទំព័រទី៣ ERN ជាភាសាបារាំង 00327365, ជាភាសាអង់គ្លេស 00329135, ERN ជាភាសាខ្មែរ 00095691។ បាទ យើងនឹងដាក់ឯកសារនេះជូនដល់លោកជាភាសាខ្មែរ ជាមួយនឹងវគ្គដែលយើងបានគូសចំណាំនេះ គឺថានៅទំព័រចុងគេ ហើយសុំការអនុញ្ញាតពីតុលាការ សុំបញ្ចាំងឯកសារនេះ។

នៅពេលដែលលោកផ្ដល់សក្ខីកម្មនេះ តើគេបានសួរចម្លើយលោកទាក់ទងទៅនឹងការស្គាល់របស់លោក-- ការស្គាល់លោក ខៀវ សំផន របស់លោក រហូតដល់ពេលនេះ យើងមិនដែលបានជួបគ្នាទេ។ អានេះជាអ្វីដែលលោកបាននិយាយ សូម្បីតែម្ដងក៏មិនដែលដែរ។ តើលោកបានអានវគ្គនេះដែរឬទេ?

[១៤:០៦:១៤]

សំណួរខ្ញុំដូចតទៅនេះ តើលោកពន្យល់ពីភាពផ្ទុយគ្នានេះ ដោយច្បាស់ក្រឡែតនេះយ៉ាងម៉េច រវាងការផ្ដល់សក្ខីកម្មរបស់លោកនៅថ្ងៃទី០៤ កក្កដា ឆ្នាំ២០១២ និងអ្វី-- ២០០២ និងពាក្យសម្ដីដែលលោកបានរៀបរាប់នៅឥឡូវនេះ ដែលលោកបានស្បថរួចហើយនោះ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ក្នុងករណីនេះ សរុបមនុស្សពីរនាក់ទៀតៗ តុលាការយោធាសរុបមនុស្សពីរនាក់ទៀតហើយ។ ខ្ញុំអត់ដែលបាននៅស្ថិតនៅក្រោមការគ្រប់គ្រងជាផ្លូវការអំពី ខៀវ សំផន និងអំពី អៀង សារី។ វាន័យអ៊ីចឹង នេះរឿងសរុបនេះ វាទៅអ៊ីចឹង។

**ស៖** ដូច្នេះ ការពន្យល់របស់លោកនោះ គឺថានៅឆ្នាំ២០០២ លោកនិយាយថា លោកមិនដែលបានជួបលោក ខៀវ សំផន ទេ។ តាមពិតទេទៅ គឺលោកចង់និយាយថានៅពេលនោះ គឺលោកមិនមែនជាកូនចៅគាត់តែប៉ុណ្ណោះទេ។ តើនេះឬជាការពន្យល់របស់លោកនូវភាពផ្ទុយគ្នានេះ? តើលោកអាចឆ្លើយម្ដងទៀតបានទេ ព្រោះថាយើងអត់បានទទួលការបកប្រែជាភាសាបារាំងទេ?

**ឆ៖** ចម្លើយរបស់ខ្ញុំ គឺត្រឹមត្រូវ។

[១៤:០៨:២២]

**ស៖** បាទឥឡូវនេះ ខ្ញុំសូមនិយាយអំពីបញ្ហាលិខិតដែលផ្លាស់ទី បាទ លិខិតដើរផ្លូវ។ នៅថ្ងៃទី០១ មេសា ឆ្នាំ២០០៨ នៅពេលដែលគេសួរចម្លើយលោក ចៅក្រមស៊ើបអង្កេត សួរលោកថា “តើហេតុអ្វីបានជាលោកមិនព្រមរត់ដូចអ្នកដទៃទៀត?” ពេលនោះលោកឆ្លើយថា ខ្ញុំសូមរៀបរាប់ “ខ្ញុំនោះ ខ្ញុំមាន

លិខិតដើរផ្លូវសម្រាប់រយៈពេលបីខែ ដែលចុះហត្ថលេខាដោយលោក កង់ ហើយដែលខ្ញុំមិនដឹងថាលោក ហ្នឹងជាអ្នកណាទេ ឈ្មោះរហ្សសនាមនេះ ក៏ប៉ុន្តែនៅពេលដែលខ្ញុំឃើញអក្សររបស់លោក ខៀវ សំផន នេះ ខ្ញុំគិតថា នេះជាប្រហែលជាអក្សរលោក ខៀវ សំផន”។

ហើយឥឡូវ ដល់ពេលក្រោយមកនៅទីនេះ នៅថ្ងៃទី២៨ មីនា ឆ្នាំ២០១២ លោកបានជម្រាបថា “ប៉ង់ បានផ្តល់លិខិតដើរផ្លូវដល់លោក គឺថាសម្រាប់រយៈពេលបីខែ” គឺលេខឯកសារ E3/136 ហើយដែលស៊ីញេ ដោយលោក កង់-- កាង-- បាទ ឈ្មោះ ខាង។ លោកបានប្រាប់ថា នៅពេលនោះ លោកបានសុំឲ្យ លោកបានសួរ ប៉ង់ ថាតើ ខាង នេះជាអ្នកណា?” ខ្ញុំគិតថា ប្រហែលជាខ្ញុំអាននោះត្រឹមត្រូវ។ ហើយគាត់បានឆ្លើយថា “ខាង ហ្នឹង គឺបងហែម”។ ហើយនៅទីនេះដដែលនេះ លោកបាននិយាយថា “ខ្ញុំបានពិនិត្យមើលអក្សរហ្នឹង ហើយខ្ញុំប្រៀបធៀបឯកសារ ហើយខ្ញុំក៏ទាញការសន្និដ្ឋានថា ប្រហែលជាអក្សររបស់មនុស្សតែម្នាក់ទេ គឺប្រាកដជាគាត់ហ្នឹងហើយ ពីព្រោះថា ខ្ញុំឃើញអក្សរគាត់មួយដង” លោកនិយាយអំពី ខៀវ សំផន នៅពេលដែលគាត់បានផ្ញើលិខិតមួយទៅមិត្តភក្តិរបស់គាត់នៅក្នុងតំបន់ពិសេស។ អ៊ីចឹងសំណួររបស់ខ្ញុំគឺថា តើនៃលិខិតដើរផ្លូវហ្នឹងមានសុពលភាពរយៈប៉ុន្មានខែ បីខែ ឬប្រាំមួយខែ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតបហ្នឹងសំណួរ! សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

**លោក វីល្លៀម ស្មីត៖**

សូមអរគុណលោកប្រធាន។ សំណួរនេះ គឺទាក់ទងទៅនឹងអ្វីដែលមេធាវីការពារក្តីបានដាក់ចំពោះសាក្សី។ ខ្ញុំមិនទាន់ទទួលបានឯកសារ-- មិនទាន់ទទួលបានលេខឯកសារ ដែលគាត់បានដកស្រង់នូវសេចក្តីថ្លែងនេះ។ ដូច្នេះ ខ្ញុំគិតថា សង្ឃឹមថា គួរតែមានផ្តល់នូវលេខ ERN ហើយឯកសារនេះ គួរតែផ្តល់ទៅឲ្យសាក្សី ដើម្បីឲ្យសាក្សីគាត់មានការងាយស្រួលក្នុងការឆ្លើយ។ សូមអរគុណ។

[១៤:១១:៣៤]

**លោក អាកទួរ វែកកែន៖**

បាទលោកប្រធាន។ សហព្រះរាជអាជ្ញាត្រឹមត្រូវហើយ។ ខ្ញុំធ្វើនេះដោយសារ ខ្ញុំចង់ពន្លឿននីតិវិធី។ អ៊ីចឹង ខ្ញុំសូមផ្តល់ឯកសារនេះទៅលោកសាក្សី នៃការផ្តល់សក្ខីកម្មរបស់គាត់នេះ ឬក៏សួរចម្លើយរបស់គាត់ទេ នៅថ្ងៃទី០១ មេសា ឆ្នាំ២០០៨ គឺឯកសារ E3/106 ដែលលេខ ERN ជាភាសាបារាំងគឺ

00177646, អង់គ្លេស 00176535, ជាភាសាខ្មែរ 00177625។

**សួរដោយលោក អាកទូរ វែកគែន៖**

**ស៖** បាទ លោកសាក្សីអាចអានវគ្គដែលលោកត្រូវ-- ខ្ញុំជម្រាបឲ្យអាននេះ តើរយៈពេលសុពលភាពនោះប៉ុន្មាន ប្រាំមួយខែ ឬក៏បីខែ?

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ចាប់តាំងពីរយៈកាលដែលអនុវត្តរបប អុ!ន៉េ របបនៃសំបុត្រលិខិតដើរផ្លូវ រហូតមកដល់ថ្ងៃដែលសហចៅក្រមស៊ើបអង្កេតលោកសួរខ្ញុំ ដូចជា៣០ឆ្នាំហើយ។ ដូច្នេះ ខ្ញុំវង្វេងដែរ ត្រីមាស ឬក៏ឆមាសមិនច្បាស់ទេ។ ខ្ញុំលើកក្រោយនេះ ខ្ញុំនិយាយឆមាស ពីព្រោះ បងខៀវ ទៅមុខទៅៗអ្នកលឿងយូរណាស់ហើយ ទើបបាន ប៉ង់ ប្តូរលិខិតដើរផ្លូវឲ្យខ្ញុំម្តង។ ដូច្នេះ ខ្ញុំគិតដល់រយៈកាលហ្នឹង បានខ្ញុំឆ្លើយថា ឆមាស។

**ស៖** បាទ សំណួរតទៅនេះ--

[១៤:១៤:១៥]

**ប្រធានអង្គជំនុំ៖**

និយាយៗចុងក្រោយ និយាយអត់ស្តាប់បាន អត់បើកក្បាលមីក្រូទេដឹង?

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន អាយុសំបុត្រដើរផ្លូវ ខ្ញុំវង្វេង មិនដឹងជាបី ឬប្រាំមួយខែច្បាស់លាស់មែនទែនទេ។ ខ្ញុំគិតថា ចាប់តាំងពី បងខៀវ ទៅនៅអ្នកលឿងរហូតមកដល់ បងហែម-- ប៉ង់ យកទៅឲ្យ បងហែម ស៊ីញ៉េលិខិតដើរផ្លូវឲ្យខ្ញុំម្តងទៀត យូរដែរ។ លិខិតដើរផ្លូវដើរផ្លូវដែល បងហែម ស៊ីញ៉េមានតែម្តងគត់។ ដូច្នេះ ឈរនៅលើរយៈកាលលាតសន្ធឹងវែងយ៉ាងនេះ បានៗខ្ញុំថា ប្រាំមួយខែ។

**សួរដោយលោក អាកទូរ វែកគែន៖**

**ស៖** តើលោកច្បាស់ដែរឬទេ ថានេះជាហត្ថលេខារបស់លោក ខៀវ សំផន?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ជំនាន់នោះ គេមិនមានហត្ថលេខាទេ គេសរសេរអក្សររបៀបប្រញាប់តើ។ គេសរសេរអក្សររបៀបប្រញាប់ មិនមែនអក្សរខាងដើម អក្សររបៀបប្រញាប់។ ដូចឈ្មោះខ្ញុំអ៊ីចឹង សរសេរទៅមើលឃើញដាច់។ ឯចម្លើយដែលខ្ញុំថា ច្បាស់ហ្នឹងគឺអក្សរ បងហែម។

ខ្ញុំច្បាស់មែន។ មូលហេតុអីបានខ្ញុំច្បាស់?--

[១៤:១៦:២៣]

**ស៖** គឺថាតាមសម្គាល់ ដែលថាអក្សរដើមដែលយើងសរសេរខ្សៀកនោះ យ៉ាងម៉េច?

**ឆ៖** ដល់ប្រាប់ច្បាស់អ៊ីចឹងហើយ យើងទៅមើលអក្សរ យើងនឹកឃើញដល់អក្សរ បងហែម ដែលគាត់សរសេរទៅឲ្យមិត្តភក្តិគាត់កាលពីឆ្នាំ១៩៧៣ ឬ៧៤។ ដូច្នេះយើងមើលទៅឃើញ ជឿបាន។

**ប្រធានអង្គជំនុំ៖**

សាក្សីនិយាយចំណុចនេះ និយាយចំណុចនេះឡើងវិញ! អំមិញវាអត់មានបើកក្បាលមីក្រូ និយាយទៅដាច់មួយកំណត់។ ចាប់ផ្តើមអាចំណុចដែលចាប់ផ្តើមចុងក្រោយនេះឡើងវិញ ព្រោះអត់ៗ បើកក្បាលមីក្រូ អត់មានការបកប្រែ។

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន អក្សរនៅលើលិខិតដែលដើរផ្លូវនេះ ដែលខ្ញុំជឿជាក់សម្តី ប៉ង់ ថាជារបស់ បងហែម ពីព្រោះច្បាស់លាស់មែនទែន គឺ ប៉ង់ ប្រាប់ថា “អក្សរ ខាង នេះគឺរបស់ បង ហែម លិខិតដើរផ្លូវនេះ បងហែម សរសេរហើយស៊ីញ៉េ។ ដល់គេប្រាប់ច្បាស់អ៊ីចឹងនាំឲ្យខ្ញុំនឹកឃើញថា អ៊ូ! វាដូចអក្សររបស់គាត់មែន អក្សររបស់គាត់ដែលខ្ញុំឃើញកាលពីឆ្នាំ-- អក្សររបស់គាត់ដែលខ្ញុំឃើញ តាំងពីឆ្នាំ១៩៧៣ ឬ៧៤ ដើម ៧៤។

[១៤:១៨:១៧]

**សួរដោយលោក អាកទួរ វ៉ែកគែន៖**

**ស៖** បាទដើម្បីសង្ខេប គឺថាលោកឃើញអក្សររបស់គាត់ជាច្រើនឆ្នាំមកហើយលើ ក្នុងសំបុត្រ មួយ ហើយលោកបានប្រៀបធៀបអក្សរហ្នឹងទៅនឹង*ត្រឹស*នៅក្នុង-- នៅលើលិខិតដើរផ្លូវហ្នឹង។ តាម រយៈហ្នឹងគឺថា លោកទាញការសន្និដ្ឋានថា នេះជាអក្សររបស់បុគ្គលតែម្នាក់ទេ។ តើអ៊ីចឹងមែនទេ ការ សន្និដ្ឋានរបស់លោកនោះ?

**ឆ៖** បងហែម មិនមែនគ្រាន់តែសរសេរឈ្មោះគាត់មួយម៉ាត់ពីរហ្នឹងទេ សរសេរឈ្មោះខ្ញុំ សរសេរក្នុងលិខិតដើរផ្លូវពេញទាំងមូល សរសេរពេញទាំងមូលលិខិតដើរផ្លូវនេះ។

[១៤:១៩:០៥]

**ស៖** តើឈ្មោះពេញហ្នឹងឈ្មោះអ្វីទៅ?

**ឆ៖** ខ្លឹមសារដែលគាត់សរសេរពេញមួយលិខិតដើរផ្លូវហ្នឹង ខ្លឹមសារដែលគាត់សរសេរលើៗ លិខិតដើរផ្លូវហ្នឹង គឺអក្សរគាត់ទាំងអស់។

**ស៖** ខ្ញុំគិតថា គេធ្លាប់សួរសំណួរទៅលោកហើយសំណួរនេះហ្នឹង។ តើលោកមានសមត្ថភាព ឬការទទួលស្គាល់អ្វីក្នុងការវាយតម្លៃលើអក្សរនេះ? នៅពេលលោកទាញការសន្និដ្ឋានលើអក្សរនេះ ដែលលោកពុំមានឯកសារប្រៀបធៀបអីទេ ក៏ប៉ុន្តែលោកប្រៀបធៀបជាមួយការចងចាំផ្ទាល់ខ្លួនរបស់លោក គឺថាវាច្រើនឆ្នាំកន្លងផុតមកហើយ។ តើលោកមានសញ្ញាប័ត្រ ឬក៏បទពិសោធន៍ជាក់លាក់អីមួយទាក់ទងនឹងការប្រៀបធៀបអក្សរនៅក្នុងលក្ខខណ្ឌដ៏លំបាកនេះដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំសូមបញ្ជាក់ថា ប៉ង់ ទៅមានហេតុផលអីភរ ថាសំបុត្រដើរផ្លូវនេះមិនមែនអក្សរ បងហែម មិនមែន បងហែម សរសេរ។ នេះជាហេតុផលសំខាន់។ រឿងប៉ុណ្ណឹងមេមកភរកូនអាម៉េច? គ្រាន់តែរឿងសំបុត្រដើរផ្លូវ អ្នកណាស៊ីញេ, ខាង ហ្នឹងអ្នកណា? រឿងអីដែល ប៉ង់ មកភរខ្ញុំ អត់ភរទេ។ ដល់តែឃើញន៎--

[១៤:២១:០១]

**ស៖** លោក តើលោកយើងនិយាយអំពី ប៉ង់ ដែលត្រូវបានគេចាប់ហើយ យកទៅដាក់មន្ទីរ ស-២១ ធ្វើទារុណកម្ម សម្លាប់នោះមែនទេ?

**ប្រធានអង្គជំនុំ៖**

ឆ្លើយៗ! ព្រោះអំមិញអត់បានបកប្រែ និយាយជាប់គ្នាពេក។

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** បាទ ទាន! ខ្ញុំសំដៅ ប៉ង់ ហ្នឹងឯង។

**ស៖** សូមលោកពន្យល់ចំណុចមួយចុងក្រោយ។ តើប្រសិទ្ធភាពនៃលិខិតដើរផ្លូវដែលចុះហត្ថលេខាដោយឈ្មោះរហស្សនាមដែលយើងមិនស្គាល់នេះ តើវាមានប្រសិទ្ធភាពយ៉ាងម៉េច?

[១៤:២១:៥៧]

**ឆ៖** វាមិនដឹង តែអ្នកដែលមិនដឹងទេ អ្នកដែលដឹង គេដឹងគ្រប់គ្នាទៅហើយ។ កងទ័ពឲ្យឃើញសំបុត្រដើរផ្លូវស៊ីញេ ឃម គេដឹងថាស៊ីញេ បងខៀវ អក្សរគាត់ ស៊ីញេគាត់។ ឯចំណែកអ្នកផ្សេងទៀតឲ្យតែឃើញអក្សរហ្នឹង ហើយនិងឈ្មោះ "ខាង" គេដឹងថា អ្ហ៊ុំ សំបុត្រដើរផ្លូវជាផ្លូវការដែលបក្សកុម្មុយនីស្តកម្ពុជាសន្មតរួចហើយ គេស្គាល់។

**ស៖** តើលិខិតដើរផ្លូវដែលធ្វើដោយបុគ្គលណាមួយនោះ តើអាចឲ្យយើងចល័ត ផ្លាស់ទីបានដែរឬទេ?

**ឆ៖** ជំនាន់នោះកងទ័ព ឲ្យតែខុសអំពី ខៀវ-- អ៎! ឲ្យតែខុសអំពី ឃឹម គេចាប់ណ៎ា។

**ស៖** ឃឹម ហ្នឹងជាអ្នកណា?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ឃឹម នេះគឺជាឈ្មោះ ខៀវ សម្រាប់តែប្រើក្នុងការស៊ីញេលិខិតដើរផ្លូវ។

[១៤:២៣:៥៥]

**ស៖** តើមិនមែន ខៀវ សំផន ទេ មែនទេ?

**ឆ៖** ខៀវ ហ្នឹងគឺ សុន សេន។ ខៀវ សំផន គឺ ខាង។

**ស៖** ដូច្នេះ លិខិតដើរផ្លូវនេះមិនអាចឲ្យយើងដើរហើរទៅកន្លែងណាបានទេ ដែលថាអ្វីដែលបានលើកឡើងដោយលោក ប៉ង់ នេះ។

**ឆ៖** គ្មានលិខិតដើរផ្លូវណាស៊ីញេ ប៉ង់ ទេ!

**ស៖** ខ្ញុំសូមទោស អំមិញខ្ញុំនិយាយច្រឡំ អំមិញខ្ញុំត្រូវនិយាយ ខាង ប៉ុន្តែខ្ញុំច្រឡំនិយាយ ប៉ង់។ អ៊ីចឹងប្រសិនខ្ញុំយល់មិនខុសទេ គឺថាលិខិតឲ្យដើរផ្លូវរបស់លោក ខាង នេះ មិនអាចឲ្យយើងដើរហើរទៅណាបានទេ។ ព្រោះថាលិខិតដើរហើរនេះត្រូវតែចុះហត្ថលេខាដោយលោក ខៀវ តើអ៊ីចឹងមែនទេ?

**ឆ៖** មិនមែនទេៗ អង្កាល់ដែលៗ បងខៀវ គាត់នៅភ្នំពេញ សំបុត្រដើរផ្លូវរបស់ពួកខ្ញុំស៊ីញេ ឃឹម។ អ្នកណាផែក ខ្ញុំហុចអាហ្នឹងទៅ គេឲ្យទៅ។ ឯចំណែកដល់ក្រោយពី បងខៀវ គាត់អញ្ជើញទៅនៅអ្នកលឿងមួយរយៈ ខ្ញុំ កាន់កាប់លិខិតដើរផ្លូវ “ខាង” ខ្ញុំដើរតាំងពីបានសំបុត្រដើរផ្លូវ “ខាង” នេះមកមិនដែលមានអ្នកណាផែកខ្ញុំនៅឡើយទេ។

[១៤:២៦:១១]

**ស៖** ក៏ប៉ុន្តែឈ្មោះបដិវត្តន៍របស់លោក ខៀវ សំផន ដែលគេទាំងអស់គ្នាស្គាល់នោះគឺថា “ហែម” តើអ៊ីចឹងមែនទេ? ហើយមិនមែន “ខាង” នោះទេ ដែលថាលោកឡើង ចាប់យកមកនិយាយឈ្មោះ “ខាង” នេះភ្លាមអ៊ីចឹង។

**ឆ៖** យើងពីរនាក់ហ្នឹង នៅអង្គុយម្ខាងទូលម្នាក់។ យើងពីរនាក់នៅអង្គុយម្ខាងទូលម្នាក់ និយាយស្តាប់គ្នាអត់បានតែម្តង។ ឈ្មោះបងខៀវ នេះណាស់ច្រើនណាស់ ៨៩ ក៏ សុន សេន, ខៀវ ក៏ សុន

សេន, ៦២ ក៏ សុន សេន, សម្រាប់ ២១-- អឺ! ឯចំណែកដល់គាត់សរសេរលិខិតដើរផ្លូវគាត់សរសេរ "ឃឹម" ឈ្មោះហ្នឹងពិសេសសម្រាប់តែស៊ីញ៉េលិខិតដើរផ្លូវទេ។ ដោយឡែកបង ខៀវ សំផន ឈ្មោះគាត់ដែលអ្នកទូទៅស្គាល់ បងហែម ខ្ញុំក៏គាត់ ហែម អ្នកណាក៏ស្គាល់ ហែម។ ឯចំណែកដល់គាត់ស៊ីញ៉េលិខិតដើរផ្លូវ គាត់សរសេរលិខិតដើរផ្លូវគាត់ស៊ីញ៉េថា "ខាង" តាខាង, ខាង។

**ស៖** ហើយអង្គាលនុ៎ងអ្នកណាក៏ដឹងដែរ ឬក៏យ៉ាងម៉េច?

**ឆ៖** ប៉ុន្តែបើគេឆែក ខ្ញុំនៅតែទៅរួច ព្រោះវាជាលិខិតដើរផ្លូវដែលចេញមកជាផ្លូវការ។

[១៤:២៨:១៩]

**ស៖** លោកបានលើកឡើងថា សុន សេន ជាអ្នកចុះហត្ថលេខាលើលិខិតដើរផ្លូវជាធម្មតាសម្រាប់លោក។ តើនេះគាត់ធ្វើអ៊ីចឹង ដោយសារគាត់ជាប្រធានលោក ឬក៏យ៉ាងម៉េច?

**ឆ៖** ត្រឹមត្រូវ គាត់ជាមេរបស់ខ្ញុំ។

**ស៖** អ៊ីចឹងដោយមូលហេតុហ្នឹងហើយបានជាគាត់ចុះហត្ថលេខាលិខិតដើរផ្លូវនោះដែលទាក់ទងនឹងលោកនោះ សម្រាប់លោកនោះ?

**ឆ៖** ត្រឹមត្រូវ។

[១៤:២៩:០០]

**ស៖** តើតម្លៃលិខិតដើរផ្លូវដែលចុះហត្ថលេខាដោយលោក ខៀវ សំផន នោះមានតម្លៃយ៉ាងម៉េចទៅ បើគាត់មិនមែនជាមេរបស់លោកផងនោះ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ខៀវ សំផន នេះ ឈ្មោះនេះ ប្រើលិខិតដើរផ្លូវមិនដឹងជាប៉ុន្មានខែមុនខ្ញុំប្រើរួចទៅហើយ។ ដូច្នេះទូទាំងភ្នំពេញ គេណាត់គ្នារួចអស់ទៅហើយៗ។ ដូច្នេះ មានតម្លៃ ឬមិនមានតម្លៃស្រេចនឹងអ្នកឆែកតើ គេស្គាល់ គេដឹង។

**ស៖** តើលិខិតដើរផ្លូវនេះ នៅឯណា សព្វថ្ងៃនេះ?

**ឆ៖** ត្រឹមត្រូវ លោកសួរនេះ។ ខ្ញុំបានបញ្ជូនទៅឲ្យការិយាល័យសហព្រះរាជអាជ្ញាទៅរកនៅ ស-២១ ពីព្រោះរត់ទៅ ចោលលិខិតដើរផ្លូវនៅកន្លែង មិត្តធី លេខាធិការរបស់ ស-២១។

**ស៖** ហេតុអ្វីបានក៏មិនមែន នួន ជា ជាអ្នកស៊ីញ៉េ ចុះហត្ថលេខាលើលិខិតដើរផ្លូវនេះ ព្រោះថាលោកបានអះអាងថា លោក នួន ជា អ្នកជំនួសលោក សុន សេន?

**ឆ៖** ធំណាស់ ប៉ុល ពត និង នួន ជា នោះ ទៅឲ្យគាត់ស៊ីញ៉េលិខិតដើរផ្លូវម៉េច។

**សះ** ចុះ រីឯលោក ខៀវ សំផន វិញ គាត់-- លោកចង់និយាយថា ចំណែកលោក ខៀវ សំផន វិញ គាត់គ្រាន់តែជាប្រធានគណៈរដ្ឋ តែប៉ុណ្ណឹងទេ ឬក៏ម៉េច?

**ឆះ** ខៀវ សំផន មិនមែនធំប៉ប៉ុន ប៉ុល ពត និង នួន ជា ទេ តែក៏ធំល្មមសមរម្យនឹងអាចស៊ីញេលិខិតដើរផ្លូវបាន។ ក្នុងបក្ស គាត់ជាសមាជិកមជ្ឈិមបក្ស សមាជិកមជ្ឈិមពេញសិទ្ធិ។

**សះ** តើលោកមានធាតុផ្សំជាឯកសារ ជាអប្បបរមាដែលអាចបញ្ជាក់ពីការផ្តល់សក្ខីកម្មរបស់លោកទាក់ទងទៅនឹងលិខិតដើរផ្លូវនេះ ដែរឬទេ?

**ឆះ** ឆ្នាំនេះ វា ២០១២ គិតមកត្រឹម ១៩៧៩ វា៣៤ឆ្នាំ។ មនុស្សបែកខ្ញែកគ្នាអស់ ស្លាប់អស់រលីង។ រួចលោកទៅរកអ្នកណាមកឲ្យជួយដឹងឮ ចង់ចាប់គេប៉ុន្មាននាក់ទៀត? មកឲ្យជួយដឹងឮហ្នឹង។ កុំចាប់គេទៀត បើជឿខ្ញុំ ក៏ជឿទៅ មិនជឿក៏ហីទៅ។

[១៤:៣៣:៣៥]

**សះ** ខ្ញុំប្តូរប្រធានបទ។ ខ្ញុំសួរ ចោទសំណួរលោកទាក់ទងនឹងក្រសួងការបរទេស។ តើអ្នកដែលនាំ-- អ្នកទទួលបន្ទុកខាងនាំអ្នកទោសទៅមន្ទីរស-២១ នោះ ឈ្មោះអី?

**ឆះ** ជម្រាបប្រសាសន៍លោកប្រធាន មិនឆ្លើយទេ ខ្ញុំមិនឆ្លើយទេ។

**សះ** ចុះហេតុអីបានជាអ៊ីចឹង?

**ឆះ** ខ្ញុំជម្រាបពីលើកមុនហើយ ថាជាទូទៅគឺខាង មិត្តលីន បញ្ជូនយកមកឲ្យខ្ញុំ។ អ៎ ឥឡូវទៅឆ្កឹះកកើយរកឯណា ខាងស្អីឯណាមកទៀត។

**សះ** មិនមែនថាខ្ញុំមានចេតនាចង់ស្តីឲ្យនោះទេ។ ខ្ញុំចង់រំឭកអំពីសេចក្តីថ្លែងការណ៍របស់លោកនៅពេលដែលគេសួរលោកកាលពីឆ្នាំ២០០៨នោះ គឺលេខ E3/100-- (សូមទោស) /60 (E3/60) ERN ជាភាសាបារាំង 00195616 ទៅដល់ 17 ហើយជាភាសាបារាំង 00195606, ERN ជាភាសាខ្មែរ 00195598។ ខ្ញុំសូមអាន៖ "នៅក្នុងក្រសួងការបរទេស គឺមានអ្នកដែលទទួលបន្ទុកនាំអ្នកទោសទៅមន្ទីរស-២១ គឺមានឈ្មោះថា ជាម គឺមានអាយុប្រហែលប្រហាក់ប្រហែលខ្ញុំដែរ គឺថាអ្នកទោសទាំងអស់នោះមិនត្រូវបានឃុំខ្លួននៅក្រសួងការបរទេសទេ គឺពួកគេត្រូវបានបញ្ជូនមកមន្ទីរស-២១"។ ដូច្នេះ តើលោកអាចបញ្ជាក់បានទេ ពីឈ្មោះ ជាម ដែលលោកបាននិយាយបញ្ជាក់ជូនទៅសហចៅក្រមស៊ើបកាលពីឆ្នាំ២០១០ នោះ?

[១៤:៣៦:២៨]

**ស៖** ជម្រាបប្រសាសន៍លោកប្រធាន កំណត់ហេតុសួរចម្លើយនៅការិយាល័យសហចៅក្រមស៊ើបអង្កេត។

**ប្រធានអង្គជំនុំ៖**

យកឯកសារពីមេធាវីជូនទៅសាក្សីពិនិត្យ។ ហើយជំនួយការ បញ្ចាំងឯកសារនៅលើអេក្រង់កុំព្យូទ័រ។

**លោក អាកទូរ វែកគែន៖**

បាទ លោកប្រធាន បញ្ចាំងចេញរួចហើយ។

**សួរដោយលោក អាកទូរ វែកគែន៖**

**ស៖** ដូច្នេះតើលោកនៅតែរក្សាដដែល ចំពោះចម្លើយដែលលោកបានបញ្ជាក់ជូនសហចៅក្រមស៊ើបអង្កេតកាលពីថ្ងៃទី០៣ ខែ៦ ឆ្នាំ២០០៨ នោះ?

**លោក កាំង ហ្កេកអ៊ាវ៖**

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំមិនដែលបដិសេធកំណត់ហេតុសួរចម្លើយនៅសហចៅក្រមស៊ើបអង្កេតនៃ អ.វ.ត.ក ទេ។ ករណីនេះទៀត ក៏ខ្ញុំមិនបដិសេធដែរ ក៏ប៉ុន្តែគ្រាន់តែខ្ញុំមិនឆ្លើយនឹងសំណួររបស់មេធាវី។

**ស៖** លោកបានតម្កល់ទុកនូវចម្លើយរបស់លោកដដែល កាលពីលោកផ្តល់ជូនសហចៅក្រមស៊ើបអង្កេតនៅឆ្នាំ២០០៨ នោះ តើអ៊ីចឹងមែនទេ?

**ឆ៖** ខ្ញុំមិនឆ្លើយនឹងសំណួរលោក ដែលទៅសួររឿងអ្នកណា ខាងអីណានោះទៅទៀតទេ។

[១៤:៣៨:៥១]

**ប្រធានអង្គជំនុំ៖**

បាទឥឡូវដល់ពេលសមល្មមនឹងសម្រាកហើយ។ អង្គជំនុំជម្រះប្រកាសសម្រាក២០នាទី ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

អនុរក្សមន្ទីរឃុំឃាំងឲ្យអញ្ជើញសាក្សីទៅកាន់បន្ទប់រង់ចាំសម្រាប់សាក្សី ហើយនិងឲ្យអញ្ជើញគាត់មកបន្ទប់សវនាការកន្លែងផ្តល់សក្ខីកម្មនេះនៅម៉ោងបី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៣៩ នាទី ដល់ម៉ោង ១៥:០១ នាទី)*

[១៥:០១:១៨]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ! អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការពិភាក្សាដេញដោល។ មុននឹងផ្តល់វេទិកាជូនទៅមេធាវីការពារក្តីលោក ខៀវ សំផន ដើម្បីតាំងសំណួរដល់សាក្សី អង្គជំនុំជម្រះសូមធ្វើការរំឭកដល់សាក្សីថា អង្គជំនុំជម្រះកត់សម្គាល់ឃើញថា លោកពិតជាមានការហត់នឿយជាខ្លាំងនៅក្នុងអំឡុងពេលនៃការផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ ក្នុងរយៈពេលជាងដប់ថ្ងៃកន្លងមកនេះ។ នេះជាការពិត ប៉ុន្តែទន្ទឹមនឹងនេះ អង្គជំនុំជម្រះសង្ឃឹមថា នឹងបន្តកិច្ចប្រឹងប្រែងរបស់លោកនៅក្នុងការផ្តល់សក្ខីកម្មដែលនឹងមានពេលវេលាតែមួយម៉ោងទៀតប៉ុណ្ណោះ នៅក្នុងការផ្តល់សក្ខីកម្មនេះ ហើយនេះក៏ដូចជាអ្វីដែលអង្គជំនុំជម្រះបានជម្រាបជូនសាក្សីរួចហើយ អំពីករណីកិច្ចក្នុងនាមជាសាក្សី ត្រូវឆ្លើយតបទៅនឹងសំណួរដែលភាគី ទៅអង្គជំនុំជម្រះបានសួរចំពោះសាក្សី នូវអ្វីដែលសាក្សីបានដឹង បានឮ បានឃើញបានជួបប្រទះ មានបទពិសោធន៍ផ្ទាល់ផ្ទាល់ ឬក៏បានធ្វើការកត់សម្គាល់ ឬសង្កេតក្នុងអំឡុងពេលនៃអង្គហេតុ ឬក៏បញ្ហា ឬព្រឹត្តិហេតុដែលមានការពាក់ព័ន្ធទៅនឹងសំណួរ ហើយដើម្បីដូចអ្វីដែលលោកសាក្សីបានឆ្លើយបញ្ជាក់កាលពីម្សិលមិញហ្នឹង គឺថា ជាការជាក់ច្បាស់នៅក្នុងកិច្ចប្រឹងប្រែងនេះ គឺដើម្បីស្វែងរកការពិតនៅក្នុងរឿងហេតុដែលកើតមានឡើង ហើយត្រូវបានអង្គការសហប្រជាជាតិ និងរដ្ឋាភិបាលកម្ពុជាព្រមព្រៀងគ្នា បង្កើតតុលាការនេះឡើង។ ដូច្នេះ អង្គជំនុំជម្រះសង្ឃឹមថា សាក្សីនឹងបន្តខិតខំប្រឹងប្រែងនៅពេលចុងក្រោយនេះ ដើម្បីមាន-- ផ្តល់វិភាគទាននៅក្នុងការឲ្យអង្គជំនុំជម្រះមានមូលដ្ឋាន ក្នុងការពិចារណាដើម្បីស្វែងរកការពិតក្នុងរឿងក្តីនេះ។ តើអាចដំណើរការបានទេ លោកសាក្សី?

[១៥:០៣:៤៥]

**លោក កាំង ហ្គេកអ៊ាវ៖**

អរគុណ និងជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំស្ម័គ្រចិត្ត បន្តដោយស្ម័គ្រចិត្ត។

**ប្រធានអង្គជំនុំ៖**

អរគុណលោកសាក្សី។ សូមផ្តល់វេទិកាជូនទៅមេធាវី ដើម្បីមានឱកាសតាំងសំណួរដេញដោល ចំពោះសាក្សី។

**លោក អាកទួរ វែកកែន៖**

សូមអរគុណលោកប្រធាន។ ខ្ញុំនឹងបញ្ចប់នៅក្នុងរយៈពេលខាងមុខបន្តិចទៀតនេះទេ បន្តិចទៀតនេះ។ ដើម្បីឆ្លើយតបទៅនឹងការរំឭកទៅកាន់សាក្សីនេះ ខ្ញុំសូមរំឭកសំណួរឡើងវិញ ហើយដែលសាក្សីមិនទាន់បានឆ្លើយនៅឡើយទេ នៅមុនពេលយើងឈប់សម្រាកនោះ។

**សួរដោយលោក អាកទួរ វែកកែន៖**

**ស៖** ខ្ញុំសួរថា នៅក្រសួងការបរទេស តើអ្នកណាជាអ្នកទទួលបន្ទុកក្នុងការនាំអ្នកទោសទៅកាន់មន្ទីរស-២១ តើគាត់ឈ្មោះអ្វីដែរ?

[១៥:០៤:៥១]

**ឆ៖** អរគុណ។ មុននោះបន្តិច ខ្ញុំបានឆ្លើយថា ជាទូទៅគឺ មិត្តលីន បញ្ជូនទៅ នេះខ្ញុំនិយាយថាជាទូទៅ។ ហើយដល់ឥឡូវសួរចំបញ្ហា ខ្ញុំសុខចិត្តឆ្លើយតាមការណែនាំរបស់លោកប្រធាន។ កំណត់ហេតុទាំងអស់របស់ខ្ញុំនៅការិយាល័យសហចៅក្រមស៊ើបអង្កេត ខ្ញុំមិនបដិសេធអីទាំងអស់។ ដូច្នេះករណីមួយនេះ គឺ មិត្តជាម នាំទៅមែន។ បើតាមខ្ញុំចាំ មិត្តជាម នាំទៅតែម្តងគត់ គឺនាំ មិត្តទាញ យកទៅឲ្យស-២១ ចាប់។ នេះគឺប៉ុណ្ណឹង។

**ស៖** ឈ្មោះកម្មាភិ-- សមមិត្តដែលលោកនិយាយអម្បាញ់មិញនេះ គឺឈ្មោះថា ជាម តើអ៊ីចឹងមែនទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន នីរសាររបស់ក្រសួងការបរទេសឈ្មោះ ជាម។

[១៥:០៦:២៣]

**ស៖** សូមអរគុណលោកសាក្សី។ ខ្ញុំនៅសល់តែប៉ុន្មានសំណួរទៀតទេ។ ខ្ញុំគិតថាប្រហែលជាមានការស្តាប់គ្នាច្រឡំនៅក្នុងដំណើរការនៃការសួរសំណួររបស់ខ្ញុំ។ បើតាមអ្វីដែលខ្ញុំបានស្តាប់នោះ ថាលោកមិនបានឆ្លើយទៅនឹងសំណួរដោយត្រង់ទៅនឹងសំណួររបស់ខ្ញុំនោះទេ។ តើលោកដឹងថា រឿង នោះធ្វើការនៅឃ្លាំងរដ្ឋយ៉ាងម៉េច? ហើយហេតុអីបានជាលោកដឹង?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន មិត្តរឿង ធ្វើការនៅឃ្លាំងរដ្ឋធ្លាប់ជួបខ្ញុំនៅពេលរៀនសូត្រ

E1/62.1

វគ្គ-- អ៊ំ សូមទោស! នៅពេលបុណ្យ ១៧ មេសា ឬក៏បុណ្យ ៣០ កញ្ញា នៅបុរីកីឡា។ មិត្តរឿង នេះធ្វើសកម្មភាពមុនឆ្នាំ១៩៧៥ នៅនែ៎ ភូមិភាគពិសេស ភាគខាងត្បូង។ ដូច្នេះពួកអាភូមិភាគពិសេសវាស្គាល់គ្នា រាប់អានគ្នា។ ខ្ញុំស្គាល់ រឿង យូរហើយ។

[១៥:០៧:៣៦]

**លោក អាកទូរ វែកគែន៖**

លោកប្រធាន ខ្ញុំអស់សំណួរហើយ។ ខ្ញុំសូមបញ្ចប់ការសួរសំណួរទៅកាន់សាក្សីរូបនេះ។ គឺខ្ញុំខាងក្រុមមេធាវីការពារក្តី ខៀវ សំផន សូមបញ្ចប់ការសួរសំណួរតែត្រឹមនេះ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។

*(ចៅក្រមពិភាក្សាគ្នា)*

បាទ ឥឡូវ ដោយមានពេលវេលា ហើយម្សិលមិញបានជម្រាបជូនខាងមេធាវីជាតិការពារក្តីលោក នួន ជា ថាប្រសិនបើកិច្ចដំណើរការសួរដេញដោលដោយក្រុមមេធាវីការពារក្តី ខៀវ សំផន ប្រព្រឹត្តទៅនៅសល់ពេល អង្គជំនុំជម្រះនឹងផ្តល់វេទិកាជូន។ ឥឡូវហ្នឹង គឺសល់ពេល អ៊ីចឹងអង្គជំនុំជម្រះផ្តល់វេទិកាជូនទៅមេធាវីជាតិការពារក្តីលោក នួន ជា ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះសាក្សី។

សូមអញ្ជើញ!

[១៥:០៨:៥២]

**លោក សុន អរុណ៖**

សូមគោរពអង្គសវនាការ សូមគោរពប្រធាន។ សូមអរគុណសាជាថ្មីម្តងទៀតដោយសារខ្ញុំមានឱកាសនឹងសាកសួរលោក ឌុច លោកជាសាក្សី ជាលើកទីពីរ។

**សួរដោយលោក សុន អរុណ៖**

**ស៖** ខ្ញុំទីមួយ គឺខ្ញុំសូមសួរសាក្សីបញ្ជាក់ ដែលលោកបានបញ្ជាក់ព្រឹកមិញប្រាប់ទៅខាងមេធាវីលោក ខៀវ សំផន ថាមានលិខិតមួយពី នួន ជា មានហត្ថលេខា បួន ថាឲ្យខ្ញុំធ្វើការជាមួយ បងវន។ ខ្ញុំសួរថា លិខិតនោះមាននៅសល់ទេមកដល់សព្វថ្ងៃ? ហើយបើមាន តើលោកឲ្យទៅចៅក្រមស៊ើបអង្កេត ឬទៅព្រះរាជអាជ្ញារួចទៅហើយ? ហ្នឹងមួយ។ តើលោកសាក្សីមានជំនឿថា នេះជាបញ្ជារបស់ ប៉ុល ពត

ឬបញ្ហាអន្តរាគមន៍របស់លោក នួន ជា?

[១៥:០៩:៥៨]

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំសូមបញ្ជាក់ជូនអង្គជំនុំជម្រះថា បទបញ្ហានេះសរសេរថា "ឧទ្ទេសនាម មិត្តវន មកធ្វើជាការជាមួយមិត្ត ហើយដល់ហត្ថលេខា បួន"។ បួន ហ្នឹងជាឈ្មោះសម្ងាត់របស់ បងនួន ហ្នឹងឯងសម្រាប់សរសេរទៅខ្ញុំ សរសេរទៅណាទៀតមិនដឹងទេ ប៉ុន្តែសរសេរទៅខ្ញុំ គាត់-- ឈ្មោះគាត់ ឈ្មោះ បួន, បងបួន។ សំបុត្រនេះ បើតាមខ្ញុំចាំ ខ្ញុំមិនបានទុក ខ្ញុំកម្ទេចចោលបាត់ទៅហើយ។ សំបុត្រផ្សេងទៀតរបស់ បងនួន មែន ខ្ញុំបានរក្សាទុកមួយដុំ ហើយខ្ញុំរត់ទៅខ្ញុំអត់មានបានយកទៅទេ។ ដូច្នេះការិយាល័យសហចៅក្រមស៊ើបអង្កេត-- (សូមទោស) ការិយាល័យសហព្រះរាជ-អាជ្ញារកឃើញមិនដឹង មិនឃើញមិនដឹង ខ្ញុំមិនដឹងច្បាស់ទេ។ ប៉ុន្តែខ្ញុំអត់បានប្រគល់អីជូនអ្នកណាទេ ខ្ញុំរត់ចោលស្រុក។ នេះជម្រាបបញ្ជាក់ប៉ុណ្ណេះ ហើយសំណួរតទៅទៀតយ៉ាងម៉េច សូមសួរម្តងទៀតមកខ្ញុំវង្វេងហើយ។

[១៥:១១:១៨]

**ស៖** ខ្ញុំមាន អំមិញមានសំណួរពីរ លិខិតនោះមាននៅសល់ទេ? អាហ្នឹងលោកឆ្លើយហើយ។ សំណួរទីពីរ តើលោកសាក្សីមានជំនឿថា នេះជាបញ្ហារបស់ ប៉ុល ពត ឬក៏ជាបញ្ហាអន្តរាគមន៍របស់លោក នួន ជា ផ្ទាល់?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ជាគោលការណ៍ដែលមានជាហូរហែមក គឺបងប៉ុល អ្នកសម្រេច បងនួន ជាអ្នកតាមដានការអនុវត្ត។ ដូច្នេះបញ្ហានេះផ្ទាល់ខ្ញុំជឿថា បងប៉ុល សម្រេច ទើបបងនួន សរសេរសំបុត្រនេះមកបញ្ជាខ្ញុំ ព្រោះ បងប៉ុល មិនដែលចេញមុខគិតគូរបញ្ហានេះដោយផ្ទាល់ទេ។ នេះខ្ញុំសូមបញ្ជាក់ប៉ុណ្ណេះ។

[១៥:១២:២០]

**ស៖** សូមអរគុណ។ សំណួរបន្ទាប់ នៅក្នុងលក្ខន្តិកៈរបស់បក្ស ភាគច្រើនអនុលេខាធ្វើតាមលេខា បើតាមលោកនិយាយអំមិញ។ បើដូច្នេះ នួន ជា គ្មានអ្វីអាចសម្រេចបានទេ ទោះការងាររបស់គាត់ផ្ទាល់ដូចជា កិច្ចការរដ្ឋសភា អប់រំក្តី ។ល។ បើដូច្នេះបញ្ហាអ្វីៗទាំងអស់ខុស ឬត្រូវ ស្លាប់ ឬរស់ គឺប៉ុល ពត ជាអ្នកបញ្ជា។ ពីព្រោះទោះបីប្រជុំហើយ សម្រេចយកសមូហភាព ហើយៗតែ ប៉ុល ពត ជា

អ្នកសម្រេចចុងក្រោយបំផុត។ តើអ៊ីចឹង ឬយ៉ាងម៉េច?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ក្នុងឋានៈជាអ្នកដឹកនាំរួម គឺអ៊ីចឹងមែន។ គេសរុប តែសរុបហើយ គឺអនុវត្ត នេះជាមាគ៌ាបក្ស នេះជាគោលការណ៍។ ដូច្នេះតែកាលណាគេសម្រេចហើយត្រូវតែធ្វើ។ ដូច្នេះអ្នកក្រោមបង្គាប់ធ្វើ ឯចំណែកអនុលេខាតាមដានការអនុវត្ត។ គោលការណ៍នេះមានចែងលម្អិតនៅក្នុងឯកសារថ្ងៃ០៩ តុលា សាជាថ្មីម្តងទៀត ០៩ តុលា ១៩៧៥។ យើងទាំងអស់គ្នាសុទ្ធតែបានអានបញ្ហានេះហើយ ខ្ញុំជឿ។

[១៥:១៣:៥០]

ដោយឡែកនៅពេលដែល បងប៉ុល មិននៅ បងនួន សម្រេចកិច្ចការ នេះជាបញ្ហាមួយទៀត។ សម្រេចកិច្ចការជំនួស បងប៉ុល នេះជាកិច្ចការមួយទៀត។ ដោយឡែកតាមការវិភាគលើឯកសារស-២១ គឺក្រោយថ្ងៃ២៥ ខែវិច្ឆិកា ១៩៧៨ ខ្ញុំឃើញអត់មាន បងនួន សរសេរស្នើទៅសុំយោបល់ បងប៉ុល ទេ ឃើញគាត់តែចារខ្ពីៗ របៀបជាអ្នកសម្រេច ហើយបញ្ហា។ ឧទាហរណ៍ ឯកសារដែលគាត់-- ដែល កង ចាប ហៅ សែ ផ្ញើមកពីខាងព្រះវិហារនោះ។ ដូច្នេះវាចូលទៅក្នុងការអនុវត្តគោល-- ថាបើលេខាមិននៅ អនុលេខាជាអ្នកធ្វើ។ ក៏ប៉ុន្តែមួយទៀត វាចូលនៅក្នុងលក្ខន្តិកៈបក្សដែរ អនុលេខាកាន់កាប់ការងារបក្ស។ ការងារបក្ស គឺស្អី? សរុបមក គឺក្តាប់ប្រវត្តិរូប ក្តាប់ជីវទស្សន៍។

ហើយនៅក្នុងឯកសារថ្ងៃ០៩ តុលា ដដែលនេះ យើងឃើញហើយ បើលោកមេធាវីបើកឲ្យជ្រៅទៅ ខ្ញុំជឿលោកមេធាវីឃើញ។ "កុំជឿតាមខ្សែខ្លាំង វាផ្តើយបត់បែន ឲ្យជឿតាមខ្សែយើងវិញល្អជាង"។ ខ្សែយើងគឺនរណា? គឺបងនួន ដែលក្តាប់ប្រវត្តិរូបបានច្បាស់លាស់ ហើយនៅក្នុងសវនាការនេះដែរ ខ្ញុំបានរាយការណ៍ជូនអង្គប្រជុំថា បងនួន ក្តាប់ប្រវត្តិរូប ឡុង នរិន្ទ បានច្បាស់ជាងអៀង សារី ទៅទៀត។ នេះខ្ញុំជូនភស្តុតាងប៉ុណ្ណោះ។ សរុបមក ខ្ញុំនៅតែរក្សានូវគោលគំនិតដដែលថាបងនួន នៅមានអំណាច ជាពិសេសពេលបងប៉ុល មិននៅ។ ហើយពេលដែលបងប៉ុល សម្រេចហើយបងនួន តាមដានការអនុវត្ត ហើយមាគ៌ាអីៗអត់មានបងនួន បង្កើតទេ គឺបងប៉ុល។ អ៊ីចឹង ខ្ញុំសូមបញ្ចប់ប៉ុណ្ណោះ ជូនលោកមេធាវី។

[១៥:១៥:៤៩]

**សៈ** អរគុណ។ លោកសាក្សីមានមុខងារជាប្រធានស-២១ ដែលមានឋានៈស្មើនឹងគណៈកម្មាធិការ វរសេនាធំ ស្មើនឹងចៅហ្វាយស្រុក នេះតាមចម្លើយរបស់លោកទៅជាមួយនឹងសហព្រះរាជអាជ្ញា នៅថ្ងៃទី២៦ ខែបី ២០១២។ ខ្ញុំសួរថា បើលោកមានឋានៈស្មើនឹងស្រុក និងកងវរសេនាធំ ពេលលោក

បានអប់រំ សិក្សាក្តី ក៏ត្រឹមតែថ្នាក់គណៈកម្មាធិការវរសេនាធំ ចុះហេតុអ្វីបានលោកដឹងរឿងធំៗដល់ទៅរឿងមជ្ឈិម រឿងអចិន្ត្រៃយ៍ អីធំៗខ្លាំងម្ល៉េះ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន យើងខ្ញុំរស់នៅក្នុងបក្សកុម្មុយនីស្តកម្ពុជាតាំងពីឆ្នាំ១៩៧១ ហើយបើយើងខ្ញុំនិយាយពីរឿង ការដែលខ្ញុំបានរៀនសូត្រលក្ខន្តិកៈបក្ស ខ្ញុំរៀនសូត្រលក្ខន្តិកៈបក្សតាំងពីឆ្នាំ១៩៦៧ ដឹងថាបក្សមានចាត់តាំងថ្នាក់ដឹកនាំ ជាស្នូលដឹកនាំមួយ ហៅថា "គណៈមជ្ឈិម"។ នេះជាជំហានទីពីរនៃការយល់ដឹងរបស់ខ្ញុំទៅហើយ។ ជំហានទីមួយនៃការយល់ដឹងរបស់ខ្ញុំ គឺខ្ញុំបានមើលសៀវភៅចិន។ គេនិយាយអំពីការបដិវត្តនៅប្រទេសចិន បក្សកុម្មុយនីស្តចិនយ៉ាងម៉េចខ្លះ ខ្ញុំយល់បន្តិចៗតាំងពីនោះមក ហើយចេះតែពន្យល់បន្តៗមក។ ដូច្នេះវាមិនមែនលេខាស្រុក លេខាវរសេនាធំ វាអត់ដឹងអីពីខាងនោះសោះទេ។ យើងដឹង យើងស្គាល់អ្នកណាដែលយើងត្រូវតែគោរពដោយខានមិនបានគោរពយ៉ាងម៉េចក៏យើងដឹង លក្ខន្តិកៈបក្សវាចែងមកយ៉ាងម៉េច ឲ្យយើងគោរពយ៉ាងម៉េចក៏យើងដឹង។ សតិអារម្មណ៍អង្គការវិន័យយើងខ្ញុំរៀនតាំងពីឆ្នាំ១៩៦៧ ហើយមោទនភាព ខុស និងត្រូវ ក៏យើងខ្ញុំរៀននៅឆ្នាំ១៩៦៧។ លក្ខន្តិកៈបក្សក៏យើងខ្ញុំរៀននៅពេលនុ៎ង។

[១៥:១៨:០៧]

**ស៖** ខ្ញុំអរគុណហើយ។ ចម្លើយនេះដូចជាវែង ខ្ញុំមិនបានសួរដល់ប៉ុណ្ណឹងទេ ខ្ញុំអត់សួរដល់រឿងស្រុកចិន ស្រុកអីណាទេ។ ខ្ញុំសួរត្រឹមថា ហេតុអ្វីបានលោកមានឋានៈប៉ុណ្ណឹង លោកដឹងរឿងរ៉ាវធំៗរបស់បក្ស។ លោកដឹងដោយសារឮគេថា លោកដឹងដោយសារលោកមានឯកសារមកថ្នាក់លើជូនចម្លងជូនមកលោកឲ្យដឹងដែរ។ អានេះសំណួររបស់ខ្ញុំ។

**ឆ៖** លោកមេធាវី ជម្រាបប្រសាសន៍លោកប្រធាន ក្នុងលក្ខន្តិកៈវាចែងច្បាស់ហើយ ថ្នាក់ដឹកនាំទូទាំងប្រទេស គឺមជ្ឈិមបក្ស។ នៅក្នុងវិន័យវាចែងថា "ភាគតិច គោរពភាគច្រើន ថ្នាក់ក្រោមគោរពថ្នាក់លើ ទូទាំងប្រទេសគោរពមជ្ឈិមបក្ស" ដូច្នេះ វាចែងហើយ។ រួចហើយមជ្ឈិមបក្សគឺអី? ក៏វាមានចែងនៅក្នុងលក្ខន្តិកៈឆ្នាំដែលខ្ញុំរៀននៅឆ្នាំ១៩៦៧ មកដែរ គឺលក្ខន្តិកៈដែលគេកសាងឡើងនៅឆ្នាំ១៩៦០។ នេះគឺរៀន បានរៀនច្បាស់តែម្តង។ រួចត្រៀមខ្លួន នឹងគោរពមជ្ឈិមបក្ស នេះគឺច្បាស់។ ហើយចូលមក ម-១៣ គេប្រាប់ថា "គោរពមជ្ឈិមបក្ស គោរពសេចក្តីសម្រេចរបស់បក្សក្នុងការចាប់មនុស្ស"។ បក្សបានប្រគល់មកឲ្យលេខាភូមិភាគជាអ្នកសម្រេច។ ទាំងអស់នេះ គឺវាអ៊ីចឹង វាដំណើរមកសឹមៗ រហូតមកដល់ពេលនេះ។

[១៥:១៩:៤៥]

**ស៖** អរគុណ។ មុខងាររបស់លោកជាសាក្សី លោកមុខងាររបស់លោក សូមទោស មុខងាររបស់លោកសាក្សីនៅស-២១ តាំងពីលោកនៅជាអនុប្រធានមក លោកកាន់មុខងារជាអ្នកសួរចម្លើយពិនិត្យរបាយការណ៍ និងក្រោយមក កាន់ការងារទាំងអស់ ពេលឡើងជាប្រធាននៅស-២១។ សូមបញ្ជាក់ថា-- សូមបញ្ជាក់សាជាថ្មីថា ពេលលោកបានលើកឡើងជាលេខាបក្ស ឬប្រធានស-២១ តើលោកមានមុខងារធ្វើអ្វីខ្លះ? ហើយសម្រេចអ្វីមួយ លោកសម្រេចៗទាំងអនុប្រធានរបស់លោក ដែលមានទាំងប៉ុន្មានដែរ ដូចលោកថា ប៉ុល ពត និង នួន ជា អ្វីៗក៏ប៉ុល ពត និង នួន ជា ដែរ។ អ៊ីចឹងដូចគ្នាឬក៏ខុសគ្នាយ៉ាងម៉េច ថ្នាក់លើ ហើយនិងថ្នាក់ក្រោម?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំនឹងឆ្លើយ។ ខ្ញុំបានបញ្ជាក់ហើយ នៅក្នុងសវនាការសំណុំរឿងលេខ០០១ ខ្ញុំបញ្ជាក់ម្តងហើយម្តងទៀត។ អង្គជំនុំជម្រះនេះជាសាក្សី ថាស-២១ មិនមែន ឌុច ហើយ ម៉ម ណៃ ទេ។ បើមិត្តហ៊ នៅរស់ ក៏មិនមែន ឌុច ហើយ ហ៊ ទៀតដែរ។ គឺ ឌុច ម្នាក់ទទួលខុសត្រូវទាំងអស់។ នេះបញ្ហាធំ។ ដោយឡែក កិច្ចការទាំងអស់ ចំពោះមុខប្រវត្តិសាស្ត្ររបស់បក្សកុម្មុយនីស្តកម្ពុជា ទាំងពីរនាក់នេះ ទទួលខុសត្រូវដោយពិតប្រាកដ។ ប៉ុល ពត ជាអ្នកបង្កើតមាគ៌ា ប៉ុល ពត ជាអ្នកសម្រេច នួន ជា ជាអ្នកតាមដានការអនុវត្ត។ នេះ លេខាបក្សដែលមានលក្ខណៈទូទាំងប្រទេស វាមានការបែងចែកអ៊ីចឹង។ ក៏ប៉ុន្តែដោយឡែក ពេលបងប៉ុល មិននៅ គឺបងនួន ជាអ្នកសម្រេចគ្រប់កិច្ចការ។

[១៥:២២:០១]

**ស៖** លោកសំអាងនៅលើអ្វី ដែលលោកជម្រាបទៅតុលាការថា ប៉ុល ពត មិននៅ ត្រូវតែ នួន ជា សម្រេចជាផ្លូវការ? ហើយពេលដែល ប៉ុល ពត នៅ ប៉ុល ពត អ្នកសម្រេច ហើយ នួន ជា ជាអ្នកអនុវត្ត។ សំអាងទៅលើអ្វី?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ទីមួយ គឺយើងទាំងអស់គ្នាពិនិត្យឯកសារ ថ្ងៃ០៩ តុលា ១៩៧៥ ឡើងវិញ។ ខ្លឹមសារដែលខ្ញុំនិយាយទាំងប៉ុន្មាននៅក្នុងឯកសារនុ៎ង។ បើម្នាក់មិននៅ ម្នាក់ទៀតសម្រេច។ ម្នាក់អ្នកអនុម័ត ម្នាក់ទៀតជាអ្នកតាមដានការអនុវត្ត។ យើងពិនិត្យមើលបញ្ហានេះទៅ យើងឃើញហើយ។ បើមិនម្នាក់នៅ ម្នាក់ទៀតសម្រេច ម្នាក់ទៀតធ្វើ យើងមើលភស្តុតាង។ ទីពីរ ខ្ញុំសូមនិយាយពីមើលភស្តុតាង។ ភស្តុតាងខ្ញុំបានចង្អុលទៅភស្តុតាងដែលមានចេញពីស-២១ គឺចម្លើយរបស់

គង់ គៀន ហៅ អ៊ឹង វ៉េត។ ព្រឹកមិញខ្ញុំបានយកឯកសារ ម្សិលមិញខ្ញុំបានយកឯកសារមក ខ្ញុំនិយាយលេខឯកសារហ្នឹងហើយ ប៉ុន្តែម៉្យោណោះ ព្រះរាជអាជ្ញាលោកឆ្លើយដែលថា ឯកសារ គង់ គៀន ហៅ អ៊ឹង វ៉េត លេខប៉ុន្មាន? លោកដឹងលេខកូដអស់ហើយ។ ដូច្នេះ ឯកសារនុ៎ង ខ្ញុំរាយការណ៍ទៅជូនបងខៀវ ទៅជូន សុន សេន។ ចំណារ សុន សេន ជូនបងនួន ផ្ទាល់។ ហ្នឹងវាជាភស្តុតាងមួយទៀត ជាក់ស្តែង ដែល បងប៉ុល មិននៅ បងនួន ជាអ្នកសម្រេច។ ហើយខ្ញុំបានវិភាគជូនសហចៅក្រមស៊ើបអង្កេតលទ្ធភាព គឺនៅពេលដែល បងប៉ុល សុំសម្រាក នៅពេលដែលប្រកាសថាខ្លួនគាត់ឈឺនុ៎ង។

[១៥:២៣:៥៨]

ចៅក្រមស៊ើបអង្កេតសុខចិត្តទទួលថា អ្ហឺ! គឺនៅពេលហ្នឹងហើយ។ គាត់អ្នកដឹងថ្ងៃខែច្បាស់ជាងខ្ញុំ។ គាត់ចាំ។ ដូច្នេះហើយ បានៗជាយើងលើកបញ្ហានេះ មកធ្វើជាភស្តុតាង ពីព្រោះវាមានទាំងអក្សរខ្ញុំ វាមានទាំងអក្សរបង សុន សេន វាមានទាំងអក្សរ បងនួន នៅនុ៎ង ហើយមានទាំងឈ្មោះ បងនួន ដែលបងខៀវ គាត់សរសេរទៅរកទៀត។ នេះជាភស្តុតាង។ ដូច្នេះ ឯកសារក៏មាន ភស្តុតាងមាន ដែលខ្ញុំលើកឡើងជូនអង្គជំនុំជម្រះ។

**ស៖** អរគុណ។ ពេលដែលលោក សុន សេន គាត់ទៅបូព៌ា ទៅបំពេញបេសកកម្មនៅបូព៌ា។ ពេលនោះ លោកមានដឹងទេ ថាតើសុន សេន-- អឺ! នួន ជា-- អឺ! សុន សេន ទៅបូព៌ានោះ ទៅរយៈប៉ុន្មានថ្ងៃ? ប៉ុន្មានខែ? ហើយមកវិញនៅថ្ងៃណា? ខែណា?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន បង សុន សេន បែកពីខ្ញុំ។ មុនដំបូង ខ្ញុំមិនដឹងគាត់ទៅនៅត្រង់ណាផង។ ដល់ក្រោយមក ប្អូនពៅខ្ញុំ វានៅធ្វើពេទ្យសេនាធិការ ដូចវាមកលេងម្តង វាថា បង អ៊ំនៅហ្នឹងន៎អ្នកលឿង វាក៏នៅអ្នកលឿងដែរ។ នេះជាបញ្ហាដែលច្បាស់លាស់។ សរុបមក និយាយពីពេលវេលាបង សុន សេន បែកខ្ញុំតាំងពីថ្ងៃ១៥ សីហា ១៩៧៧ ហើយខ្ញុំខានឃើញមុខគាត់រហូតៗ រហូតដល់ថ្ងៃ២៥ មិថុនា ១៩៨៦ ដែលគាត់ហៅខ្ញុំទៅជួប ដើម្បីប្រើប្រាស់ខ្ញុំឡើងវិញ។ ដូច្នេះ ខ្ញុំបែកមុខពីបងខៀវ រហូតយូរណាស់ ពីថ្ងៃ១៥ សីហា ១៩៧៧ រហូតដល់ថ្ងៃ២៥, ២៦ មិថុនា ១៩៨៦។

[១៥:២៦:២១]

**ស៖** បើអ៊ីចឹង ចាប់ពីថ្ងៃ១៥ សីហា ១៩៧៧ទៅ លោក សុន សេន ទៅបំពេញបេសកកម្មនៅខាងបូព៌ា។ លោកបាននិយាយថា លោក នួន ជា ទទួលខុសត្រូវសន្តិសុខជំនួស សុន សេន អ៊ីចឹងណា! ខ្ញុំចង់បញ្ជាក់ថា ពេលដែលលោកមកវិញនោះ អ៊ីចឹងបានន័យថា លោក បើអំមិញបានបញ្ជាក់ថាមកវិញ

នៅថ្ងៃ២៦ មិថុនា ១៩៨៦។ អ៊ីចឹងអ្ហេ៎ បើខ្ញុំមិនខុស បើមិនច្រឡំទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន យើងខ្ញុំពីរនាក់ស្ដាប់សម្ដីគ្នាមិនបានទេ។ ខ្ញុំបញ្ជាក់ថា ខ្ញុំបែកមុខពីលោក សុន សេន នៅថ្ងៃ១៥ ខែសីហា ១៩៧៧។ ដល់ជួបគាត់ឡើងវិញ នៅថ្ងៃ២៦ មិថុនា ១៩៨៦ សូមទោស! ២៥ ឬ២៦ ខ្ញុំវង្វេងទៀតហើយ ៨៦ នៅពេលដែលគាត់ហៅខ្ញុំទៅប្រើសាជាថ្មីម្ដងទៀត។ ដូច្នេះ ខ្ញុំនិយាយពីរឿងជួបមុខ។

[១៥:២៧:២៨]

**ស៖** បើអ៊ីចឹងរយៈពេលដែលលោកបែកពី សុន សេន ច្រើនយូរ អស់ពេលយូរ ប៉ុន្តែនៅចន្លោះពេលហ្នឹង ពេលដែលគាត់ត្រឡប់មកវិញ ឧទាហរណ៍ថា មិនមានឯកសារណាបញ្ជាក់ថាគាត់មកវិញថ្ងៃណាទេ ក៏ប៉ុន្តែបើសិនជាគាត់ចូលមកវិញក្នុងរយៈពេលដែលបេសកកម្មបានមួយខែ ពីរខែ ឬបីខែ យើងត្រឡប់មកវិញ គាត់អត់ដែលបានទំនាក់ទំនងជាមួយលោកទៀតទេ ក្នុងនាមលោកជារដ្ឋមន្ត្រីក្រសួងសន្តិសុខ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំជាមួយនឹងបង សុន សេន តាំងពីបែកមុខពីគាត់ ខ្ញុំនៅទាក់ទងជាមួយនឹងគាត់តាមរលកអាកាស កន្លះខែ មួយខែម្ដង រហូតដល់ថ្ងៃចុងក្រោយ គឺក្រោយពេលដែល អ្ហេ!ក្រោយពេលដែលចាប់ សោ ភឹម-- មុនៗពេលដែលចាប់ សោ ភឹម។ នេះគឺខ្ញុំដាច់ការទាក់ទងរវាងខ្ញុំ ហើយនឹងបង សុន សេន ពីពេលហ្នឹងមក។

[១៥:២៨:៤០]

**ស៖** អរគុណ។ ខ្ញុំគ្រាន់ចង់បញ្ជាក់ថា ពេលដែលលោក សុន សេន ត្រឡប់មកវិញនោះ ខ្ញុំជឿថា ហើយខ្ញុំមិនមានឯកសារអីបញ្ជាក់ ដូចខ្ញុំជម្រាបអំមិញអ៊ីចឹង ថាលោក សុន សេន មកវិញថ្ងៃណា។ ប៉ុន្តែបេសកកម្មនេះ បើតាមខ្ញុំដឹងទៅមិនយូរទេ ហើយនិងត្រឡប់មកវិញ។ អ៊ីចឹងបានខ្ញុំសូមសួរបញ្ជាក់ ពីព្រោះអីខ្សែបណ្ដោយរបស់លោកសាក្សីខាងមន្ទីរស-២១ ហ្នឹងគឺជាខ្សែបណ្ដោយទៅរដ្ឋមន្ត្រីក្រសួងសន្តិសុខ។ បើសិនគាត់ត្រឡប់មកវិញ គាត់នៅធ្វើក្រសួងសន្តិសុខទៀតទេ បើនៅធ្វើក្រសួងសន្តិសុខ ហេតុអីបានលោកមិនបានជួបគាត់?

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក វីល្លៀម ស្មីត៖**

ខ្ញុំសូមជំទាស់ទៅលើសំណួរនេះ ដោយសារតែវាផ្អែកទៅលើព័ត៌មានដែលមេធាវីការពារក្តី បាននិយាយថា គាត់មិនមាន ឬក៏គាត់មិនដឹង។ ដូច្នេះ ខ្ញុំគិតថាវាជាសំណួរនាំមុខ ហើយសំណួរនេះមិនផ្អែកទៅលើខ្លឹមសារ ឬក៏អង្គសេចក្តីដែលយើងអាចចោទសួរបាននោះទេ។ សូមអរគុណ។ ហើយខ្ញុំគិតថាគាត់អាចចោទសួរសំណួរថា តើ សុន សេន មានត្រឡប់មកវិញដែរឬទេ? ឬក៏ប្រសិនបើគាត់លើកអំពី-- គាត់មិនគួរលើកអំពីអង្គហេតុដែលគាត់ខ្លួនគាត់ គាត់អត់ដឹងខ្លួនឯងនោះទេ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ ម៉េចដែរមេធាវីមានអីតបទៅនឹងការជំទាស់នេះទេ?

**លោក សុន អរុណ៖**

ខ្ញុំសូមឆ្លើយតបជាមួយនឹងសហព្រះរាជអាជ្ញា ពីព្រោះអីលោកសាក្សីគាត់ឆ្លើយថា ពេលដែល សុន សេន ត្រឡប់មកវិញ រយៈពេល ដែលទៅហើយនិងត្រឡប់មកវិញវាឆ្ងាយពេក ហើយដែលលោកមិនអាចដូចថា យករឿងនេះមកដើម្បីចោទប្រកាន់មកលោក នួន ជា កូនក្តីខ្ញុំ-- ឆ្លើយដាក់លោក នួន ជា រហូតអ៊ីចឹងទេ។ ការពិតរដ្ឋមន្ត្រីក្រសួងរដ្ឋ-- អ៎! ក្រសួងសន្តិសុខ នៅតែធ្វើការហ្នឹងដដែលពេលក្រោយពេលដែលរដ្ឋមន្ត្រីនោះត្រឡប់មកភ្នំពេញវិញ។ ហើយបើសិនថាទេ ដល់ជួបលោកសាក្សីនៅថ្ងៃ២៥ ឬ ២៦ មិថុនា ១៩៨៦ វាឆ្ងាយពេក ហើយដល់អ៊ីចឹងការងាររបស់រដ្ឋមន្ត្រីក្រសួងសន្តិសុខ ជាមួយនឹងមន្ទីរឃុំឃាំងទាំងប៉ុន្មាន ធ្វើការជាមួយនឹងប្រធានរដ្ឋសភាលោក នួន ជា។ អានេះវាដូចជាមិនសូវជា-- ខ្ញុំមិនសន្និដ្ឋានទេ ប៉ុន្តែវាដូចជាមិនសូវសមរម្យ។

[១៥:៣១:២៨]

**ប្រធានអង្គជំនុំ៖**

ជំទាស់របស់តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ការតាំងសំណួរចុងក្រោយរបស់មេធាវីអម្បាញ់មិញនេះ មានប្រសិទ្ធភាព។ មេធាវីអាចកែសម្រួលនូវតាំងសំណួរឲ្យបានត្រឹមត្រូវ ហើយគប្បីជៀសវាងឲ្យផុតនូវការយល់ដឹងអត្តនោម័តិខ្លួនឯង យកទៅតាំងសំណួរចំពោះសាក្សី។ វាត្រូវតែយល់ដឹងអំពីហេតុការណ៍ទាំងឡាយ ដែលពាក់ព័ន្ធនៅក្នុងសំណុំរឿង ភស្តុតាង ឯកសារអង្គហេតុនៅក្នុងសំណុំរឿងយកទៅដេញដោល។

[១៥:៣២:០៧]

**លោក សុន អរុណ៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក សុន អរុណ៖**

**ស៖** ខ្ញុំសូមសួរសំណួរបន្តទៅទៀត បើតាមចម្លើយរបស់លោកទៅព្រះរាជអាជ្ញានៅថ្ងៃទី២៦ ខែ៣ ឆ្នាំ២០១២ ថា "ថ្នាក់ក្រោមត្រូវរាយការណ៍ អំពីកិច្ចការដែលខ្លួនបានធ្វើ ឧទាហរណ៍ថា ដូច អនុសេនាធំត្រូវរាយការណ៍ទៅអនុសេនាធំ-- អំ អនុសេនាតូចត្រូវរាយការណ៍ទៅអនុសេនាធំ ពីវរសេនាតូចទៅវរសេនាធំ។" ចុះហេតុអ្វីបានជាលោករាយការណ៍ នួន ជា ពេលដែល សុន សេន មិននៅទៅវិញ នោះបញ្ជាក់ថា តាម-- មិនតាមឋានានុក្រមដែលលោកបានឆ្លើយ ទៅសហព្រះរាជអាជ្ញា វាបញ្ជាក់ថា ផ្ទុយនឹងចម្លើយរបស់លោកទៅសហព្រះរាជអាជ្ញា ហើយផ្ទុយទៅនឹងលក្ខន្តិកៈរបស់បក្ស ត្រង់ជំពូក៣ មាត្រា៦ ឃ្លាទី៥ នោះដែរ។ តើលោកសាក្សីយល់បែបម៉េច?

[១៥:៣៣:០៦]

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ក្នុងឋានៈជាវរសេនាធំឯករាជ្យ ស-២១ វាចំណុះគណៈកម្មាធិការសេនាធិការ វាពិតជាចំណុះ។ ខាងភស្តុភារ ខាងយន្តយុទ្ធ អាវុធយុទ្ធភ័ណ្ឌ ខាងទៅពេទ្យ ព្យាបាលរោគអីៗ ថ្នាំពេទ្យ ខោអាវបើកពីខាងពីខាងសេនាធិការទាំងអស់។ មុនពេលដែល សុន សេន ទៅជាប់ដៃសមរភូមិខ្លាំងពេក វគ្គសិក្សារៀនសូត្រប្រចាំឆ្នាំ ក៏គណៈកម្មាធិការស-២១ វាទៅរៀនជាមួយ នឹង សុន សេន។ ដោយឡែក ក្រោយថ្ងៃ១៥ សីហា ១៩៧៧ ខ្ញុំបែកមុខពី សុន សេន។ ខ្ញុំប្រើពាក្យ បែកមុខអីចឹងរហូត។

ឯចំណែក សុន សេន ខ្ញុំបានបញ្ជាក់រួចហើយថាគាត់ បានត្រូវតែងតាំងជារដ្ឋមន្ត្រីក្រសួងការពារប្រទេស គេមិនហៅក្រសួងការពារជាតិទេ ជំនាន់នោះ គេហៅក្រសួងការពារប្រទេស។ អត់ទាំងមានលើកស្លាកផង តែឃោសនាជាចំហគាត់ជារដ្ឋមន្ត្រីក្រសួងការពារប្រទេស។ តួនាទីរបស់គាត់គឺជានាយអគ្គសេនាធិការ។ នេះតួនាទីពិតប្រាកដរបស់គាត់ គាត់ធ្វើសកម្មភាពជានាយអគ្គសេនាធិការរហូត។ នៅពេលដែលប្រទេសជាតិត្រូវការចាំបាច់ អគ្គបញ្ជាការនៃកងទ័ពបដិវត្តន៍កម្ពុជាហ្នឹងវាបញ្ជានាយសេនាធិការឲ្យទៅនៅអ្នកលឿង។ ដូច្នេះ អគ្គបញ្ជាការវាហៅនាយអគ្គសេនាធិការមកប៉ុន្មានថ្ងៃម្តងជួបថ្ងៃណា? ស្រេចនឹងអគ្គសេនាធិការ ខ្ញុំអត់ដឹងទេ។ នេះបញ្ហាមួយខាងសេនាធិការ។

[១៥:៣៥:០៨]

ឯចំណែកមួយទៀតស-២១ វាស្ថិតនៅក្រោមការគ្រប់គ្រងរបស់ សុន សេន។ សុន សេន គាត់បញ្ជាក់ហើយ។ គាត់ថា "មិត្តរាយការណ៍ឯកសារស-២១ មកខ្ញុំ ក្នុងឋានៈខ្ញុំជាតំណាងសេនា-- មិនមែនទេ! ក្នុងឋានៈខ្ញុំជាតំណាងអង្គការ មិនមែនតំណាងសេនាធិការទេ"។ នេះជាសម្ដី សុន សេន។ ហើយការអនុវត្តមកទៀត ខ្ញុំមិនដែលរាយការណ៍ទៅអ្នកណាក្រៅពី សុន សេន ទេ។ ឥឡូវយើងមកងាកមើលលក្ខន្តិកៈបក្ស ត្រឹមត្រូវហើយ លោកមេធាវីលើកបញ្ហានេះ។ ថ្នាក់ក្រោមគោរពថ្នាក់លើ ស្អីៗ ដូច្នេះវរសេនាធំវាត្រូវរាយការណ៍ទៅកងពល ប៉ុន្តែវរសេនាធំឯករាជ្យវារាយការណ៍ផ្ដោះទៅសេនាធិការ។ ក៏ប៉ុន្តែដោយឡែកស-២១ នេះវាចាត់តាំងឡើងតាមស្មារតីមាត្រា៨ នៃលក្ខន្តិកៈបក្ស។ គឺវាចាត់តាំងឡើងដោយក្រោមការគ្រប់គ្រងរបស់អចិន្ត្រៃយ៍ផ្ទាល់។ ខ្ញុំអត់មានឯកសារនេះនៅហ្នឹងនេះទេ បើសិនជាលោកមេធាវីចង់ជ្រាប ខ្ញុំសូមអនុញ្ញាតលោកប្រធានបញ្ចាំងមាត្រា៨ នៃលក្ខន្តិកៈនេះ។

[១៥:៣៦:២៥]

**ស៖** ខ្ញុំបានឃើញ។ ខ្ញុំសូមអរគុណហើយ។ ខ្ញុំសូម-- ខ្ញុំមានពេលតិចណាស់ សំណួរខ្ញុំនៅសល់ច្រើនដែរ ម៉្លោះហើយសូមលោក អឺ លោកសាក្សីមេត្តាឆ្លើយឲ្យបានខ្លីជាងហ្នឹង ហ្នឹងជាការល្អបាទ។ លោកបានឆ្លើយប្រាប់ព្រះរាជអាជ្ញា "នៅថ្ងៃទី០៣ ខែមករា ឆ្នាំ១៩៧៩ ថាបងនួន បានបញ្ជាឲ្យខ្ញុំសម្លាប់អ្នកជាប់ឃុំទាំងអស់នៅស-២១"។ សូមលោកសាក្សីបញ្ជាក់ម្ដងទៀតថា បញ្ជារបស់ៗ បងនួន នេះប្រាកដជារបស់ នួន ជា មែន ឬអ្នកផ្សេង? នេះសំណួរទីមួយ។ ចុះ សុន សេន ទៅណា ដើមខែមករា ឆ្នាំ១៩៧៩ មុននឹងកងទ័ពវៀតណាមចូលមកដល់ភ្នំពេញ? តើបញ្ជារបៀបណា? ដោយមាត់ទទេ? ដោយលាយលក្ខណ៍អក្សរ? ដោយមានហត្ថលេខា និងត្រាច្បាស់លាស់ទេ? បើមិនមានទេ តើលោកជឿថាជឿដែរថាជាបញ្ជារបស់ នួន ជា នៅពេលនោះ?

**ឆ៖** អរគុណ។ ខ្ញុំសូមបញ្ជាក់ថាបង សុន សេន អាចជាប់នៅសមរភូមិជាក់ស្ដែង។ ចាប់តាំងពីថ្ងៃ២៥ ខែវិច្ឆិកា ឆ្នាំ១៩៧៨ អំ សូមទោស! ៧៧។ ព្រោះហត្ថលេខារបស់គាត់នៅលើឯកសារដែលជូនទៅស-២១ ដែលបង្ហាញនៅក្នុងរយៈកាលសវនាការលេខ-- សំណុំរឿងលេខ ០០១ ឃើញហត្ថលេខាចុងក្រោយបំផុតរបស់គាត់ គឺនៅថ្ងៃ២៥ ខែ១១ ឆ្នាំ១៩៧៧។ ដូច្នេះ ខ្ញុំជឿថាបង សុន សេន ជាប់នឹងការងារសមរភូមិចាប់តាំងពីពេលនោះមករហូត។ ឯចំណែកការទាក់ទងនឹងខ្ញុំតាមរលកអាកាស យូរៗម្ដង។ ដូច្នេះបង សុន សេន អត់បានមកជួបខ្ញុំផ្ទាល់ទេ។ នេះទីមួយ។

[១៥:៣៩:០០]

ទីពីរ បញ្ហាឲ្យកម្ទេចអ្នកទោសឲ្យអស់នៅស-២១ ខ្ញុំវង្វេងកាលបរិច្ឆេទបន្តិច ឬគាត់បញ្ជានៅថ្ងៃ០១ មករា ១៩៧៩ ឬក៏គាត់បញ្ជានៅថ្ងៃ០៣ ខ្ញុំវង្វេងហើយ ប៉ុន្តែតាមចាំដូចជាគេបង្ហើយរឿងអស់នុំងនៅថ្ងៃ០៣ មករា ១៩៧៩។ នេះបើតាមខ្ញុំចាំ បញ្ជាហ្នឹងខ្ញុំទទួលដូចជាតាំងពីថ្ងៃ០១ មករា ម្ល៉េះ។ បងនួន បញ្ជាមកខ្ញុំផ្ទាល់។ ហើយសូមលើកព្រឹត្តិការណ៍ពាក្យសម្ដីខ្លះ ដើម្បីឲ្យឃើញថា យើងខ្ញុំបានជួបគ្នាមែន។ គាត់ថា "អ្នកទោសទាំងប៉ុន្មានមិត្តកម្ទេចឲ្យអស់ទៅ បញ្ចេញឲ្យអស់"។ ខ្ញុំសួរគាត់ ខ្ញុំថា "អ៊ីចឹងអ្នកទោសយួនកម្ទេចដែរ? ក្រែងយើងជាប់ធ្វើអត្ថបទផ្សាយវិទ្យុ?" គាត់ថា "ចាំរក គង់តែរកបានទៀតទេ កម្ទេចឲ្យអស់"។ ហើយខ្ញុំសួរគាត់ទៀតថា "ចុះពួក យ-៨ បួននាក់ ខ្ញុំចង់សុំទុកដើម្បីសួរចម្លើយពួកហ្នឹងឲ្យច្បាស់ ពីរឿងសម្លាប់ជនបរទេស"។ គាត់ថា "អើ! មិត្តម្ចាស់ការ"។ នេះការពិភាក្សានិយាយគ្នា។ ដូច្នេះបែបបទបញ្ជានេះ គឺចេញពីសម្ដី បងនួន បញ្ជាខ្ញុំ។

[១៥:៤០:០០]

**ស៖** អរគុណ។ សំណួរមួយទៀត អចិន្ត្រៃយ៍ភូមិភាគ លោកបានជម្រាបតុលាការកាលពីម្សិលមិញថា អចិន្ត្រៃយ៍ភូមិភាគសម្រេចហើយ ត្រូវតែអនុវត្តដូចជាចាប់មនុស្ស គឺសិទ្ធិសម្រេចរបស់គណៈកម្មការភូមិភាគ។ ចុះៗក្រោមទៀត ដូចជាតំបន់ ដូចជាស្រុក ដូចជាសហករណ៍ គេមានលេខារបស់គេដែរ គេធ្វើអនុវត្តដូចគេគ្នាអ៊ីចឹង ឬក៏សុំសេចក្ដីសម្រេចពីថ្នាក់លើអី ពីណាសិនដែរ ឬយ៉ាងម៉េច?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន--

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតបនឹងសំណួរ។

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញាតិ!

[១៥:៤១:២៥]

**លោក វីល្លៀម ស្មីត៖**

លោកប្រធាន ខ្ញុំចង់ឲ្យមានការបញ្ជាក់ ព្រោះថា តើមេធាវីការពារក្ដីនិយាយអំពី សេចក្ដីសម្រេចក្នុងការសម្លាប់ៗ នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ៧៦ ឬមួយក៏គាត់និយាយយោងទៅលើសេចក្ដីសម្រេចផ្សេងៗដែលមិនទាក់ទងទៅនឹងការសម្លាប់? ធ្វើដូច្នេះដើម្បីឲ្យយើងអាចដឹង ក៏ដូចជាសាក្សីក៏ដឹង ថាតើយើងនិយាយយោងទៅលើឯកសារណាមួយ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ មេធាវីសូមកែសម្រួលនូវសំណួររបស់លោកឲ្យបានជាក់ច្បាស់ ដើម្បីឲ្យសាក្សីស្ដាប់យល់ ហើយនិងងាយក្នុងការឆ្លើយតប។ ពីព្រោះនៅទីនេះយើង ជាទូទៅយើងផ្អែកលើឯកសារ ហើយទន្ទឹមនឹងនេះក៏យើងអាចពាក់ព័ន្ធនឹងសំណួរទូទៅផងដែរ ដោយយោងលើឯកសារ គឺយើងអាចតាំងសំណួរមានលក្ខណៈទូទៅបាន។

**លោក សុន អរុណ៖**

ខ្ញុំមិនឆ្លើយតបទៅនឹងព្រះរាជអាជ្ញាទេ ខ្ញុំនឹងបន្តទៅសំណួរមួយតទៅទៀត។

[១៥:៤២:៣៤]

**សួរដោយលោក សុន អរុណ៖**

**ស៖** "ពេលវាយចូលភ្នំពេញ គឺក្រោមបង្គាប់របស់លេខា ឬអនុលេខា" ហ្នឹងបើតាមសម្ដីលោកឆ្លើយប្រាប់តុលាការ។ ហេតុអ្វីបានលោកដឹង? លោកដឹងដោយសារអ្វី បើលោកជាប្រធានស-២១?

**លោក កាំង ហ្កេកអ៊ាវ៖**

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន កងទ័ពនេះវាកសាងតាំងពីឆ្នាំ១៩៥៦ តាមរូបភាពកងការពារសម្ងាត់។ កងការពារសម្ងាត់បង្កើតឡើងដោយភូមិភាគនីមួយៗ គ្រប់ភូមិភាគ តែវាស្ថិតនៅក្រោមការគ្រប់គ្រងរបស់បក្ស។ និយាយអំពីបក្ស គឺនិយាយអំពីលេខា និងអនុលេខា។ ដល់ឆ្នាំ១៩៧៤ កងទ័ពនេះ ភូមិភាគគេកសាងបានទៅជាកងពល ក៏វានៅក្រោមការគ្រប់គ្រងពីលើរបស់លេខា និងអនុលេខា។ នេះវាដំណើរអ៊ីចឹង។ ហើយលក្ខន្តិកៈបក្សឆ្នាំ១៩៧១ វាសរសេរខុសពីនេះបន្តិច។ វាសរសេរថា "កងទ័ព គឺជាកូនបង្កើតដ៏ជំនិតបំផុតរបស់បក្ស"។

[១៥:៤៤:០៨]

**ស៖** សូមអរគុណ។ "នៅតួនាទីរបស់ស-២១ ធ្វើយ៉ាងណាឲ្យបានចម្លើយសារភាព ហើយឆ្លើយដាក់អ្នកដទៃ" ហ្នឹងបើតាមចម្លើយរបស់លោកឆ្លើយប្រាប់តុលាការ។ ហើយខាងលើគេចាត់ចែងខាងលើគឺគណបក្ស-- គណៈកម្មាធិការរបស់អគ្គលេខាធិការ ខ្ញុំចង់បញ្ជាក់ថា តើអនុវត្តរបស់លោកបែបយ៉ាងនេះ លោកអនុវត្តរបៀបអ៊ីចឹង ឬយ៉ាងម៉េច?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន គឺពិតជាអនុវត្តរបៀបហ្នឹង។ ហើយខ្ញុំសូមបញ្ជាក់បន្ថែមមួយម៉ាត់ របៀបហ្នឹងបក្សកុម្មុយនីស្តកម្ពុជាអនុវត្តតាំងពីសម័យឥស្សរៈមករហូត។

**ស៖** ពេលដែលសុន សេន បានទៅបូព៌ា បេសកកម្ម-- បំពេញបេសកកម្មនៅបូព៌ា ពេលដែល-- ពេលនុ៎ង លោកបានប្រាប់ទៅតុលាការថា នួន ជា ជាអ្នកទទួលខុសត្រូវជំនួសសុន សេន។ លោកដែលបានឃើញជាលិខិតអីជាផ្លូវការតែងតាំងលោក នួន ជា ជា-- ទទួលខុសត្រូវលើសន្តិសុខហ្នឹងទេ ហើយអ្នកណាជាអ្នកតែងតាំងលោកនួន ជា ធ្វើជា-- ទទួលខុសត្រូវលើសន្តិសុខលើមន្ទីរស-២១ អីចឹង?

[១៥:៤៦:២៣]

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន តាំងពីខ្ញុំទៅជួបបង សុន សេន នៅក្រោមការគ្រប់គ្រងរបស់គាត់ បង សុន សេន តែងតែដំណាលថាបងនួន ធ្វើអីចេះ បងនួន ប្រាប់មកឲ្យធ្វើអីចុះ។ ខ្ញុំមិននិយាយអស់នេះហូរហែទេ ទាំងនេះសឲ្យឃើញថានៅពីលើបង សុន សេន វាមានបងនួន មួយទៀតទើបបានដល់ បងប៉ុល។ នេះវាដឹងហូរហែមក។ នៅថ្ងៃ១៥ ខែសីហា ឆ្នាំ១៩៧៧ គេមកហៅខ្ញុំ ដូចជាមិត្តលីន ឬមិត្តណាទេ។ មកហៅខ្ញុំឲ្យទៅធ្វើការ ដល់ទៅធ្វើការម្តងនេះមិនធ្វើការនៅកន្លែង*បេ* ខាងជើងបុរីកីឡាដូចធម្មតាដូចរបស់បង សុន សេន ទេ គឺទៅធ្វើការនៅពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត។ ខ្ញុំឡើងទៅជាន់ទីពីរ ខ្មែរយើងហៅថា "ជាន់ទីពីរ" ទៅដល់ជួបបងនួន នៅនុ៎ង គាត់ថាឥឡូវ មិត្តខៀវ ទៅសមរភូមិបាត់ហើយ ខ្ញុំចុះមកដឹកនាំមិត្តជំនួស ហើយមានអ្នកចុះឡើងទៅហ្នឹង គឺមាន មិត្តប៉ង់ ហើយនិង មិត្តលីន។ មិត្តប៉ង់ មិត្តស្គាល់ស្រាប់ហើយ មិត្តលីន ក៏មិត្តស្គាល់ស្រាប់ដែរ។ ហ្នឹង បងនួន មានប្រសាសន៍អីចឹង។ ដូច្នេះក្នុងឋានៈគាត់ជាអនុលេខានរណាមិនស្គាល់ ហើយខ្ញុំដឹងថា បងនួន ហ្នឹងធំជាងបងខៀវ តាំងពីយូរមកហើយ ត្រួតត្រាពីលើ បងខៀវ ទៅទៀត។ ដូច្នេះ រឿងវាអីចឹងឲ្យរកលិខិតផ្ទេរតំណែង មានត្រា មានហត្ថលេខាអី គ្មានទេក្នុងរបបបក្សកុម្មុយនីស្តកម្ពុជា គ្មានសោះ។

[១៥:៤៨:២១]

**ស៖** កាលពីអាទិត្យមុន ថ្ងៃប្រាំ ខ្ញុំបានសួរម្តង ប៉ុន្តែពេលវាខ្លីពេក ខ្ញុំសួរទៅលោកឆ្លើយមក ខ្ញុំដូចមិនទាន់អស់ចិត្ត ខ្ញុំសូមសួរសាថ្មី ប៉ុន្តែខ្ញុំមានបន្ថែមសំណួរខ្លះ។ នៅពេលដែលព្រះរាជអាជ្ញាបានសួរថា លោកសាក្សីអាចជឿថាឯកសារទង់បដិវត្តអាចថតចម្លងបានទេ? លោកឆ្លើយពេលនោះថា "ខ្ញុំជឿជាក់ថា ឯកសារនេះប្រាកដជាថតចម្លង"។ ខ្ញុំសូមសួរថា ហេតុអ្វីបានជាលោកជឿថា ថតចម្លងប្រាកដមែន? តើលោកសំអាងទៅអ្វីបានជាថាប្រាកដជាថតចម្លង? សំណួរទីពីរ ហើយលោកដឹងថា សំណៅដើមនៅឯណាទេ ទង់បដិវត្តហ្នឹង? នៅពេលលោកបានទទួលនោះ ហើយពេលនេះលោកដឹងថា នៅឯណាដែរឬទេ សំណៅដើម ខ្ញុំចង់បញ្ជាក់រឿងសំណៅដើម?

[១៥:៤៩:២៩]

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន អំពីបញ្ហាទង់បដិវត្ត។ អំពីបញ្ហាទង់បដិវត្តនេះ ខ្ញុំធ្លាប់ប្រើ ធ្លាប់អានទង់បដិវត្តនេះហូរហែមក តាំងពីចុង៧១ ឬដើម៧២ រហូតអត់ដែលដាច់ទេ។ ដូច្នេះ ទង់បដិវត្ត ប្រែប្រួលយ៉ាងម៉េចក៏ខ្ញុំដឹង។ នេះទីមួយ។ ទីពីរ រឿងដែលខ្ញុំទទួលស្គាល់ថា ទង់បដិវត្តដែលថត យកមក ប្រើនេះ ខ្ញុំបានបញ្ជាក់ជូនសហព្រះរាជអាជ្ញាហើយ ថាខ្ញុំមិនបានឃើញគេថតទេ ក៏ប៉ុន្តែខ្ញុំជឿថាច្បាប់ ដែលយកមកប្រើនេះ គឺពិតជាច្បាប់ថតចម្លងពីច្បាប់ដើម។ ហើយបើនិយាយពីច្បាប់ដើមនៅឯណា? ខ្ញុំជឿថាច្បាប់ដើមដែលគេប្រមូលហ្នឹង ក៏មានមួយចំនួនចេញពីស-២១ដែរ។ ក៏ប៉ុន្តែច្បាប់ដើមឥឡូវនៅ លើ ឆាំង យុ គេថែរក្សារបស់គេ។ រឿងទាំងអស់នេះ ខ្ញុំដឹង ពីព្រោះខ្ញុំស្តាប់សវនាការនេះដែរ។

**ស៖** ខ្ញុំមានសំណួរមួយទៀតសួរថា ឯកសារដែលលោកសរសេរជាដៃនោះ គឺគេហៅថា "ឯកសារ E180" ដែលសរសេរចំណងជើងថា "មេរៀនដកស្រង់ពីពិសោធន៍នៃចាស់ជំនាន់-- ចាស់ទុំ ជំនាន់មុន" នៅក្នុងភាសាខ្មែរ លេខERN 00787939 ភាសាអង់គ្លេស 00791979 លោកសរសេរថា ហូជីមិញ បានសម្រេចដក សឺង ង៉ុកមិញ ឲ្យទៅហាណូយ ទុក ស៊ីវ ហេង ឲ្យទទួលខុសត្រូវក្នុង ប្រទេស។ តើគោលនយោបាយរបស់ហូជីមិញពិតប្រាកដយ៉ាងម្តេច? ហើយលោកសាក្សីមានឯកសារអ្វី សំអាងនៅលើគោលនយោបាយរបស់ហូជីមិញនោះទេ ដើម្បីជូនប្រជាជនខ្មែរយើងឲ្យបានដឹងទៅ អនាគតផង នេះជាប្រវត្តិសាស្ត្រ។

[១៥:៥២:១១]

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ឯកសារនេះ នៅក្នុងបក្សកុម្មុយនីស្តកម្ពុជា ដូចមាន និយាយហូរហែដែរ។ ក្រោយសន្និសីទនៅហ្សឺណែវ ក្នុងការអនុវត្តកិច្ចព្រមព្រៀងនៅហ្សឺណែវ ហូជីមិញ គាត់ដក សឺង ង៉ុកមិញ យកទៅនៅហាណូយជាមួយនឹងខ្មែរ យុវជន និងកម្មាភិបាលខ្មែរ ១.៧០០នាក់ យកទៅរៀននៅភាគខាងជើងវៀតណាម មិនមែនត្រឹមតែភាគខាងជើងទេ ខាងជើងក្រុងព្រៃនគរទៀត នៅក្នុងតំបន់មួយ ដែលគេហៅថា "ហ្វ៊ងហ្វ័រថាំ"។ នេះជារឿងពិត។ ឯចំណែកពាក្យថា "ហ្វ៊ងហ្វ័រថាំ" អីនេះ គ្មានផ្សាយនៅក្នុងនេះទេ។ គឺខ្ញុំដឹងពីពួកហាណូយដែលទៅរៀងនុំង គេប្រាប់ខ្ញុំ។ ហើយដែលទុក ស៊ីវ ហេង ជំនួសនេះ ឯកសារបក្សកុម្មុយនីស្តកម្ពុជាមាននិយាយជាហូរហែ។ ទុក ស៊ីវ ហេង ជាជំនួស ជាលេខាបក្ស។ ដំបូងនេះ ឈ្មោះ "បក្សប្រជាជនបដិវត្តន៍ប្រជាជនកម្ពុជា"។

[១៥:៥៣:២២]

**សៈ** ខ្ញុំនឹងចោទសួរបន្តទៅទៀត មានសំណួរមួយទៀត។ នៅក្នុងសំណេររបស់លោក E180 ដដែល ក្នុង ERN ខ្មែរ 00787952 ភាសាអង់គ្លេស 00791999 បន្ទាប់ពីរដ្ឋប្រហារ លោកបានលើកឡើងពីវត្តមានរបស់វៀតណាម ដែលនៅតែមាននៅក្នុងស្រុកខ្មែរ។ ខ្ញុំសូមដកស្រង់ដូចតទៅនេះ៖ "កងទ័ពវៀតណាមដែលជ្រកអាស្រ័យនៅកម្ពុជា បានវាយរំលំរដ្ឋប្រហារលន់ នល់ តាមស្រុក ហើយកសាងរដ្ឋអំណាចឆ្លង។ រដ្ឋអំណាងឆ្លងនេះ ជារបស់បក្សពលករវៀតណាម តែមានរូបភាពជាខ្មែរ។ ដោយសារតែគណៈកម្មាធិការបក្សតំបន់ បក្សស្រុកសុទ្ធតែជាកម្មាភិបាលវៀតណាម ដែលប្រែឈ្មោះជាខ្មែរ។ កងទ័ពដែលវៀតណាមកសាងបានជារបស់បក្សវៀតណាមគ្រប់គ្រង ដោយគណៈកម្មាធិការអនុសេនាធំវៀតណាម យុទ្ធភ័ណ្ឌ ជ័យភ័ណ្ឌ ដែលរឹបអូសយកបានជារបស់បក្សវៀតណាម លុយកាក់ពន្ធដារ ជាកម្មសិទ្ធិរបស់វៀតណាម"។ សូមចប់ការ-- ខ្ញុំសូមបញ្ចប់ការដកស្រង់។ លោកថារដ្ឋអំណាចឆ្លងនេះ ជារដ្ឋអំណាចបណ្តោះអាសន្ន ដែលពេលអង្គការខ្មែរទៅដល់ ត្រូវប្រគល់មកឲ្យអង្គការខ្មែរវិញ។

[១៥:៥៥:០៤]

ខ្ញុំសូមសួរថា តើការប្រគល់នេះមានដែលកើតឡើងដែរឬទេ បើមានសូមលោកជួយលើកយកព្រឹត្តិការណ៍នោះមកបញ្ជាក់ជូនអង្គជំនុំជម្រះ ដើម្បីពិចារណា?

**ឆៈ** ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំលើកឧទាហរណ៍មួយពីរ។ នេះជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រជាក់ស្តែង។ ស្រុកកំណើតរបស់ខ្ញុំ គឺស្រុកស្មោង។ វៀតណាមចូលទៅរំដោះស្មោង ប្រហែលជាថ្ងៃ១៦ ខែមិថុនា ប៉ុន្តែខ្ញុំសូមនិយាយថាក្នុងថ្ងៃ-- នែ៎ក្នុងខែមិថុនាទៅចុះ។ ទៅដល់ហ្នឹងចាត់តាំងកសិករមានម្នាក់នៅភូមិចក ឃុំកំពង់ចិនខាងជើង ឲ្យធ្វើប្រធានរណៈសិរ្សស្រុក ឈ្មោះ ពូព្រឹម ឈ្មោះ មាសព្រឹម។ រួចដល់ក្រោយមក ពេលដែលអង្គការខ្មែរទៅដល់ ពេលហ្នឹង មិត្តនឿន, មិត្តនឿ នេះស្លាប់នៅស-២១ ខ្ញុំឃើញប្អូនមកតវ៉ាជាដើមបណ្តឹងរដ្ឋប្បវេណីដែរ គាត់ទៅធ្វើលេខាបក្សស្រុកនៅនុ៎ង។ ប៉ុន្តែនេះការប្តូរ ការផ្លាស់នៅនែ៎ស្រុកស្មោង វាអ៊ីចឹង។

[១៥:៥៦:២៣]

ដោយឡែកនៅខាងស្អាង កោះធំ លើកដែក កៀនស្វាយ។ ពួកខេត្តអាងយ៉ាង វាចូលមកកាន់កាប់រំដោះ ដេញពួកទាហានលន់ នល់ វាចូលមកកាន់នៅខេត្តនុ៎ង វាចាត់តាំងគណៈកម្មាធិការរណៈសិរ្ស វាចាត់តាំងគណៈកម្មាធិការស្រុក បក្សស្រុក គណៈកម្មាធិការ នែ៎! សូមទោស ខ្ញុំនិយាយច្របូកច្របល់

ហើយ វាចាត់តាំងគណៈកម្មាធិការបក្សតំបន់ ចាត់តាំងគណៈកម្មាធិការបក្សស្រុក ចាត់តាំងកងទ័ព ចាត់រណសិរ្សតំបន់ ចាត់តាំងរណសិរ្សស្រុក ចាត់តាំងរណសិរ្សឃុំ ចាត់តាំងរណសិរ្សភូមិរបស់វាអ៊ីចឹង។ ក៏ប៉ុន្តែសំខាន់ គឺវាមកវៃបន្ទាយដីឥដ្ឋនេះបានម្តង។ ជ័យភណ្ឌយកទៅស្រុកក្រោមអស់រលីង យកទៅខេត្តអាងយ៉ាងអស់រលីង គ្មានសល់អីឲ្យខ្មែរមួយគ្រាប់ទេ។

[១៥:៥៧:១៤]

ឯចំណែកលុយពន្ធដារ សម្បូរលុយពន្ធដារខ្លាំងណាស់នៅនុ៎ង។ បក្សខេត្តអាងយ៉ាងក្តោបទាំងអស់ ខ្មែរអត់មានបានអីមួយគ្រាប់ទេ។ ខែ ដូចជាខែប្រាំពីរ ខែប្រាំបី បូព៌ាចាត់តាំងគណៈកម្មាធិការបក្សមួយប្រចាំតំបន់២៥នេះ តស៊ូតវ៉ាគ្នាតាំងពីខែប្រាំពីរ ប្រាំបីហ្នឹងរហូតមក រហូតដល់មានសម្លាប់។ វៀតណាមហ្នឹងសម្លាប់អ្នកទារពន្ធដារខ្មែរម្នាក់នៅតាមដងទន្លេបាសាក់ខាក្រោមព្រែកស្តីបន្តិច ភូមិព្រែកស្តីបន្តិច។ នេះដោយសារទំនាស់រឿងពន្ធដារ។ រហូតដល់ខែ១២ ទើបបានផ្ទេររដ្ឋអំណាចពីតំបន់៦២ របស់អាងយ៉ាង មកជាតំបន់២៥របស់ភូមិភាគបូព៌ា។ ខែ១២ ឆ្នាំ១៩៧០ នេះខ្ញុំសូមនិយាយពីការផ្ទេរពេលខ្លះយូរ ពេលខ្លះឆាប់អ៊ីចឹង។ នៅស្មោងឆាប់ នៅស្អាង កោះធំ លើកដែក កៀនស្វាយយូរ។

[១៥:៥៨:២៣]

**ស៖** អរគុណណាស់។ នៅក្នុងអត្ថន័យនៃអត្ថបទដែលខ្ញុំបានអានជូនអំមិញហ្នឹង ខ្ញុំមានសំណួរទាំងអស់ប្រាំ ប៉ុន្តែអំមិញខ្ញុំសួរមួយសំណួរទេ។ កាលណាអស់សំណួរហ្នឹង ខ្ញុំអស់សំណួរតទៅទៀតហើយ។ សំណួរទីពីរក្នុងអត្ថបទដដែលហ្នឹង តើមូលហេតុអ្វីបានជាបក្សរបស់វៀតណាមបង្កើតរចនាសម្ព័ន្ធគ្រប់គ្រងការងារនៅក្នុងស្រុកខ្មែររបៀបនេះ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន បញ្ហានេះវាចូលសន្និដ្ឋានបន្តិច។ វិភាគសភាពការណ៍ហើយសន្និដ្ឋាន វៀតណាម កងទ័ពវៀតណាមមកស្នាក់អាស្រ័យនៅក្នុងទឹកដីខ្មែរ បំប៉នកម្លាំងនៅក្នុងទឹកដីខ្មែរយូរហើយ។ ដល់ពេលរដ្ឋប្រហារនេះ លន់ នល់ គាត់បានជំនួយពី សេ.អា.តូ អាវុធយុទ្ធភណ្ឌថ្មីមួយកប៉ាល់សមុទ្រ នេះម្យ៉ាង។ ម្យ៉ាងទៀត គាត់ចាប់អាណិកជនវៀតណាមបញ្ជូនទៅស្រុក យកមកឃុំទុកនៅនឹងសាលាប្រូវីដង់ សាលាមីស របស់បារាំង យកមកឃុំទុកនៅសាលាឯកជនចិនទួនហ្វា ខាងលិចផ្សារកណ្តាល ខាងលិចឆៀងខាងជើងផ្សារកណ្តាលពេញនៅនុ៎ង ស្អុយតែអាចម៍។ ហើយក៏បញ្ជូនតាមរយៈកាកបាទក្រហម ឬតាមរយៈអង្គការអៀសខ្លួនមិនដឹងទេ ទៅស្រុកយួនអស់ទៅ។

[១៦:០០:០៦]

នៅពេលនុ៎ងហើយកងទ័ពរបស់វៀតណាមខាងត្បូងលើកទង់ សីហនុ លើកទង់រណសិរ្សរួបរួមជាតិ វៃរដ្ឋអំណាចរបស់ លន់ នល់ កាន់កាប់រដ្ឋអំណាចនេះវិញ។ ដូច្នេះតើធ្វើនេះដើម្បីអី? អត្តនោម័តិ ឬយើងពឹង? វៀតណាមគេថា យើងពឹងគេ តែតាមពិតអត់ទេ គឺវៀតណាមឆក់ឱកាសហ្នឹង ដើម្បីកាន់កាប់រដ្ឋអំណាចនៅស្រុកខ្មែរ ប៉ុន្តែកាន់វាអត់បាន គោលការណ៍អន្តរជាតិនិយម គេមិនអនុញ្ញាតឲ្យធ្វើអ៊ីចឹង។ ម្ល៉ោះហើយកន្លែងណាដែលមានខ្លាញ់ គេក្រាញនៅរហូតដល់ខែ១២ទៅ កន្លែងណាដែលអត់ខ្លាញ់គេបង្វិលឲ្យខែ៧។

[១៦:០០:៥៥]

**សះ** អរគុណណាស់។ នេះសំណួរទីពីរ ខ្ញុំនៅតែបីសំណួរខ្លីៗទៀតទេ នឹងចប់។ តើគណៈកម្មាធិការអនុសេនាធំវៀតណាម នៅស្រុកខ្មែរហ្នឹងមានប៉ុន្មាននាក់ ហើយនៅឯណា? លោកអាចជម្រាបតុលាការបានទេ?

**ធះ** ជម្រាបប្រសាសន៍លោកប្រធាន គណៈកម្មាធិការអនុសេនាធំវៀតណាម ដែលមកគ្រប់គ្រងកងទ័ព ដេលវៀតណាមកសាងបាននៅដីខ្មែរ ក្រោយឆ្នាំ១៩៧០ ក្រោយរដ្ឋប្រហារឆ្នាំ១៩៧០ គេទៅស្រុកយួនវិញអស់ហើយ។ ក្នុងនោះ ខ្ញុំស្គាល់តែអនុសេនាធំកាន់កាប់ស្រុកកៀនស្វាយទេ អ-២។ អនុសេនាធំកាន់កាប់ស្រុកកៀនស្វាយ ឈ្មោះវា អា ទី ធឿង ពីដើមមិញធ្លាក់គ្រានៅភ្នំពេញនេះ។ ឯចំណែកគណៈកម្មាធិការគ្រប់គ្រង អនុសេនាធំប្រចាំស្រុកកោះធំ ឈ្មោះវា ណាំ ដូ ប្រវត្តិដើមមិនដឹង។ នេះឥឡូវវាទៅស្រុកវៀតណាមវិញអស់ហើយ។

[១៦:០២:០៧]

**សះ** សូមអរគុណ។ នេះជាសំណួរចុងក្រោយបំផុត។ តើលោកអាចបកស្រាយយ៉ាងដូចម្ដេចចំពោះយុទ្ធសាស្ត្ររបស់វៀតណាមនៅលើទឹកដីខ្មែរយើងនេះ?

**ធះ** ខ្ញុំសូមនិយាយដោយឡែក ត្រឹមតែរឿងក្រោយរដ្ឋប្រហារថ្ងៃ១៨ មីនា ១៩៧០។ ខ្ញុំមិននិយាយវែងទេ។ បញ្ហានេះយើងអត់មានពឹងគេទេ គេនៅហ្នឹងស្រាប់ គេលើកអាវុធដេញរដ្ឋប្រហារ--ដេញរដ្ឋអំណាច លន់ នល់ ដើម្បីអី? ម៉្យាងទៀត ក្នុងឋានៈជាអន្តរជាតិនិយមវណ្ណៈអធន ក៏យើងអាចពន្យល់បាន។ ក៏ប៉ុន្តែដើម្បីគោលបំណងជាជំហានមួយរៀបចំសហព័ន្ធឥណ្ឌូចិនឲ្យទៅជាមានកម្លាំងជាក់ស្ដែង ក៏យើងសឹងតែថាបាន។ ដូច្នេះយើងវាពិបាកនិយាយណាស់ ព្រោះវាជារឿងដែលមិនមានអ្នកណាពន្យល់ឲ្យច្បាស់លាស់។

**ស៖** សូមអរគុណ។

**លោក សុន អរុណ៖**

សូមអរគុណលោកប្រធានដែល-- ខ្ញុំអស់សំណួរហើយ សូមអរគុណសាជាថ្មី ព្រោះអីលើសប្រាំនាទី។ សូមអរគុណ។ ចប់។

[១៦:០៣:៤៥]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកមេធាវី។ អរគុណសាក្សី ឥឡូវនេះដល់ពេលសមល្មមនឹងសម្រាកហើយនូវកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។ ប៉ុន្តែមុននឹងសម្រាក អង្គជំនុំជម្រះសូមសួរទៅមេធាវីជនជាប់ចោទទាំងបីក្រុមថា តើលោកដឹងទេថាតើជនជាប់ចោទ ដែលជាកូនក្តីរបស់លោកហ្នឹង មានបំណងនៅក្នុងការសួរតទល់ជាមួយនឹងសាក្សីនេះដែរឬទេ?

សូមអញ្ជើញពីលោកមេធាវី ក្រុមមេធាវីការពារ នួន ជា!

[១៦:០៤:២៩]

**លោក ម៉ៃខល ផេសមិន៖**

សូមអរគុណលោកប្រធាន។ ដូចដែលខ្ញុំប្រកាសកាលពីសប្តាហ៍មុន គឺថាកូនក្តីរបស់ខ្ញុំចង់អាននូវសេចក្តីថ្លែងការណ៍ដើម្បីឆ្លើយតបទៅនឹងសាក្សី-- ដើម្បីឆ្លើយតបទៅនឹងសក្ខីកម្មរបស់សាក្សីរូបនេះ។ ដូច្នេះហើយខ្ញុំនៅពេលនេះ ខ្ញុំលើកឡើង-- ងើបឡើងក៏ចង់ឲ្យមាននូវនីតិវិធីសម្រាប់សប្តាហ៍ក្រោយដែរ ខ្ញុំគិតថា យើងត្រូវតែទទួលយកនូវព័ត៌មានចំពោះអ្វីដែលបានកើតឡើង គឺការពិនិត្យទៅលើសាក្សីនេះ។ ដូច្នេះ ខ្ញុំគិតថា យើងត្រូវពិនិត្យមើលទៅលើសេចក្តីសម្រេចចំនួនពីរនៅក្នុងពេលដែលយើងធ្វើការសួរដេញដោលទៅលើសាក្សីរូបនេះ។ ហើយម្យ៉ាងទៀត វាជាការរំលោភ-- ហើយម្យ៉ាងទៀតមានការរំលោភសិទ្ធិទៅលើមេធាវីការពារក្តី។ ដូច្នេះហើយទើបកូនក្តីរបស់ខ្ញុំមានចេតនាដើម្បីធ្វើការឆ្លើយតបចំពោះសាក្សីរូបនេះ។ ខ្ញុំគិតថា ខ្ញុំប្រហែលជាមិនចំណាយពេលលើសពីដប់ទៅដប់ប្រាំនាទីនោះទេ។

[១៦:០៥:៤៩]

**ប្រធានអង្គជំនុំ៖**

កម្មវិធីដែលសួរហ្នឹង គឺសួរតែជនជាប់ចោទទេ។ មេធាវីមិនអនុញ្ញាតទៀតទេ។ ពេលវេលាសួរដេញដោលសាក្សីរូបនេះអស់ហើយ។ បញ្ហាគឺកូនក្តីរបស់ខ្លួន ថាតើមានបញ្ហាអីត្រូវតទល់ ឬក៏ស្អីទេ?

**លោក ម៉ៃខល ផេសមិន៖**

អ្វីដែលខ្ញុំចង់និយាយគឺថា ក្រៅពីសេចក្ដីថ្លែងការណ៍ដែលកូនក្ដីរបស់ខ្ញុំចង់លើកឡើងហ្នឹងគឺគាត់មានសំណួរពីរបីដើម្បីចោទសួរទៅសាក្សីរូបនេះផងដែរ។

*(ចៅក្រមពិភាក្សាគ្នា)*

[១៦:០៨:២៨]

**ប្រធានអង្គជំនុំ៖**

ចុះមេធាវីការពារក្ដីលោក អៀង សារី យ៉ាងម៉េចដែរ?

**លោក អាង ឧត្ដម៖**

សូមគោរព សូមទោស! សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម សូមគោរពអង្គសវនាការ សាធារណជនទាំងអស់ ហើយសួស្ដីលោក កាំង ហ្គេកអ៊ាវ។ លោក អៀង សារី បានប្រកាសពីសិទ្ធិនៅស្ងៀមមិនឆ្លើយឆ្លងតាំងពីថ្ងៃដំបូងរបស់គាត់មកម្ល៉េះ។ សិទ្ធិនេះ គឺគាត់ប្រកាន់រហូតមកទល់នឹងថ្ងៃនេះនិងតទៅទៀត។ ហើយដោយឡែកចំពោះសាក្សីលោក កាំង ហ្គេកអ៊ាវ ក៏លោកសូមរក្សាសិទ្ធិនេះដែរ។ សូមអរគុណ។

[១៦:០៩:១០]

**ប្រធានអង្គជំនុំ៖**

បាទអរគុណនូវការបញ្ជាក់ជំហរយ៉ាងជាក់ច្បាស់ដូច្នេះ។

ហើយចុះមេធាវីការពារលោក ខៀវ សំផន?

**លោក គង់ សំអុន៖**

សូមអរគុណលោកប្រធាន។ លោក ខៀវ សំផន មិនមានបំណងតាំងសំណួរដោយផ្ទាល់ចំពោះសាក្សីលោក ឌុច នេះទេបាទ។ សូមអរគុណ។

*(ចៅក្រមពិភាក្សាគ្នា)*

[១៦:១២:០៣]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណច្រើន ហើយបន្ទាប់ពីបានស្ដាប់នូវសេចក្ដីតបរបស់មេធាវីទាំងបីក្រុម អង្គជំនុំជម្រះសូមជម្រាបថា មេធាវីការពារក្ដីលោក នួន ជា ប្រសិនបើលោកមានបំណងធ្វើការសង្កេត ឬក៏កត់

សម្គាល់អ្វីអំពីនីតិវិធីប្រព្រឹត្តក្នុងការពិភាក្សាដេញដោលចំពោះសាក្សីរូបនេះ សូមមេធាវីរៀបចំជាលាយលក្ខណ៍អក្សរមកឱ្យអង្គជំនុំជម្រះ។ ហើយភាគីផ្សេងទៀត ដែលពាក់ព័ន្ធនឹងក៏មានសិទ្ធិនៅក្នុងការធ្វើសេចក្តីតបទៅនឹងឯកសារ ដែលលាយលក្ខណ៍អក្សរដែលរៀបចំឡើងដោយក្រុមមេធាវីការពារក្តី នួនជាផងដែរ។ ដោយឡែកអង្គជំនុំជម្រះបានទទួលព័ត៌មាន គឺលោក នួន ជា ដែលបានស្នើសុំ គឺសុំធ្វើសេចក្តីថ្លែងការណ៍ ដោយចំណាយពេលប្រាំមីនុត ឬដប់មីនុតប៉ុណ្ណោះ។ ហើយពីរក្រុមទៀត គឺបានបញ្ជាក់ជំហរច្បាស់លាស់ហើយ គឺមិនមានអ្វីតទល់ជាមួយនឹងសាក្សីរូបនេះទេ។

[១៦:១៣:១១]

ឥឡូវនេះដល់ពេលសមល្មមនឹងសម្រាកហើយ ហើយមុននឹងសម្រាកអង្គជំនុំជម្រះសូមថ្លែងអំណរគុណសាជាថ្មីម្តងទៀតចំពោះសាក្សី កាំង ហ្គេកអ៊ាវ ហៅ ឌុច ដែលបានខិតខំប្រឹងប្រែងឆ្លើយនឹងសំណួរជាច្រើន រាប់រយរាប់ពាន់សំណួរនៅក្នុងអំឡុងពេលជាងដប់ថ្ងៃកន្លងមកនេះ ហើយប្រកបដោយភាពអត់ធ្មត់ និងខិតខំអស់ពីលទ្ធក្នុងការផ្តល់សក្ខីកម្ម។ ហើយឥឡូវនេះអង្គជំនុំជម្រះអស់សំណួរអ្វីដែលត្រូវតាំងសំណួរចំពោះលោកទៀតហើយ នៅក្នុងកិច្ចដំណើរការនាពេលនេះ។

ដូច្នេះ អនុរក្សមន្ទីរឃុំឃាំងឱ្យនាំលោក កាំង ហ្គេកអ៊ាវ ហៅ ឌុច ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ។

បាទ សូមអញ្ជើញលោកស្រីមេធាវី! គេមានបញ្ហាច្រើនហើយ លោកស្រីដូចអត់មានលើកអីសោះ ដល់ពេលតុលាការចាប់ផ្តើមរៀបបិទហើយ បានទើបមកជ្រៀតជ្រែក ជ្រៀតដូច្នេះវាដូចជាអត់ទំនងទេ។ លើកក្រោយគប្បីប្រើប្រាស់ពេលវេលាឱ្យដូចៗ ស្របគ្នាទៅ ចៀសវាងតុលាការបង្គាប់បញ្ជារៀបប្រកាសបិទ ផ្អាកកិច្ចដំណើរការសវនាការហើយ លោកស្រីទើបនឹងលើកបញ្ហាមក។

[១៥:១៤:៣៥]

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

លោកប្រធានសូមអភ័យទោសដែលបាននិយាយនៅពេលចុងក្រោយនេះ ប៉ុន្តែខ្ញុំមិននិយាយវែងនោះទេ។ ខ្ញុំមានអារម្មណ៍ថា អង្គជំនុំជម្រះបានសេចក្តីសម្រេចពាក់ព័ន្ធទៅនឹងសេចក្តីថ្លែងការណ៍របស់លោក នួន ជា។ ប្រសិនបើមិនអ៊ីចឹង តើលោក នួន ជា-- បើសិនជាគាត់អាចនិយាយ-- ធ្វើសេចក្តីថ្លែងការណ៍បាននោះ យើងសូមពន្យល់អំពីគោលបំណងរបស់យើង។ ដូច្នេះប្រហែលជាថ្ងៃពុធ សប្តាហ៍ក្រោយ យើងចង់ពន្យល់អំពីអ្វីដែលយើងគិត។ ដូច្នេះ ខ្ញុំគិតថាមិនមានការជជែកពិភាក្សាអីលើបញ្ហានេះ

ម្តងទៀតនោះទេ។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ សវនាការនឹងលើកបន្តធ្វើនៅថ្ងៃពុធ ទី១៨ ខែមេសា ឆ្នាំ២០១២ គឺក្រោយចូលឆ្នាំខ្មែរ ដោយចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។ អនុរក្សមន្ទីរឃុំឃាំងឲ្យនាំខ្លួនជនជាប់ចោទទាំងបីរូបទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ ហើយនិងបង្គាប់ឲ្យនាំខ្លួនពួកគាត់ទាំងបីរូបមកកាន់បន្ទប់សវនាការនេះនៅព្រឹកថ្ងៃទី១៨ ខែមេសា ឆ្នាំ ២០១២ ឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៦:១៦ នាទី)*